ការប្រឡងវាយតម្លៃ

សមត្ថភាពជំនាញជាក់

លាក់ផ្នែកមើលថៃទាំ

សៀវភៅសិក្សា

~ជំនាញមើលថៃទាំនិងភាសាជប៉ុន
ទាក់ទងនឹងការមើលថៃទាំ~

ជាភាសាខ្មែរ

សមាគមសហប្រតិបត្តិការប្រយោជន៍សាធារណៈ សមាគមមើលថៃទាំ និងសុខុមាលភាពជប៉ុន
ខែមីនា ឆ្នាំ 2024

はじめに

本書は、厚生労働省の補助事業（介護の日本語学習支援等事業）を活用して、介護分野の特定技能１号の評価試験に対応する初めての学習用テキストとして策定したものです。

2019 年４月に施行された在留資格「特定技能」の制度は、深刻化する人手不足に対応するため、生産性向上や国内人材の確保のための取組を行ってもなお人材を確保することが困難な状況にある産業上の分野において、一定の専門性・技能を有する外国人材を受け入れる制度です。

介護分野において特定技能の在留資格で入国するためには、国際交流基金が実施する日本語基礎テスト等の日本語試験のほか、厚生労働省が実施する介護技能評価試験と介護日本語評価試験を受験し、合格することが基本となります。

今後、試験の実施国は拡大されていく予定ですので、介護分野で特定技能により入国される方は、さらに増えていくことが見込まれます。そこで本書は、介護技能評価試験と介護日本語評価試験に対応できるようにしつつ、介護現場で働く上で、最初に習得しておいていただきたい内容を中心に作成いたしました。

本書は、介護技能評価試験と介護日本語評価試験の受験対策として活用されることに加え、特定技能の在留資格で入国して介護現場で働かれる皆様が、引き続き本書を手元に置き、ご活用いただけるような構成にしています。

本書が、「日本の介護」を知る契機となり、その魅力を存分に感じていただくものになること、さらに、介護分野の特定技能により入国して介護現場でご活躍いただく際の一助となることを切に願っております。

公益社団法人 日本介護福祉士会
特定技能評価試験対応テキスト検討会

របៀបប្រើប្រាស់សៀវភៅនេះ

សៀវភៅ『ការប្រឡងវាយតម្លៃសមត្ថភាពជំនាញជាក់លាក់ផ្នែកមើលថែទាំ សៀវភៅសិក្សា~ជំនាញផ្នែកមើលថែទាំនិងភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ~』 នេះ គឺជាសៀវភៅសិក្សាដែលឆ្លើយតបទៅនឹងការប្រឡងវាយតម្លៃសមត្ថភាពជំនាញផ្នែកមើលថែទាំ និងការប្រឡងវាយតម្លៃភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ។

- សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយបែងចែកចេញជាពីរផ្នែកគឺ "ជំនាញផ្នែកមើលថែទាំ" និង "ភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ" ឲ្យស្របទៅនឹងស្តង់ដានៃការប្រឡងវាយតម្លៃសមត្ថភាពជំនាញជាក់លាក់វិស័យមើលថែទាំ។
- ដោយសារតែការប្រឡងវាយតម្លៃសមត្ថភាពភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ ធ្វើឡើងជាភាសាជប៉ុន ដូច្នេះហើយ ផ្នែក"ភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ" នឹងត្រូវធ្វើឡើងជាភាសាជប៉ុន ដោយមិនមានការបកប្រែទេ។

"ជំនាញផ្នែកមើលថែទាំ"ត្រូវបានបែងចែកជា4ផ្នែក ឲ្យស្របទៅតាមសំណួរនៃការប្រឡង។

PART 1 មូលដ្ឋាននៃការមើលថែទាំ
PART 2 ប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្ត
PART 3 បច្ចេកទេសក្នុងការប្រាស្រ័យទាក់ទង
PART 4 បច្ចេកទេសផ្តល់ជំនួយនៅក្នុងការរស់នៅ

⊙ រូបភាពជាច្រើនត្រូវបានដាក់បញ្ចូល ដើម្បីឲ្យងាយស្រួលក្នុងការស្រមៃមើលទិដ្ឋភាពនៃការមើលថែទាំ ទោះបីជាមិនធ្លាប់ធ្វើការនៅកន្លែងមើលថែទាំក៏ដោយ។

⊙ ជាពិសេស ចំពោះចំណុចសំខាន់ៗ ត្រូវបានបង្ហាញដោយនិមិត្តសញ្ញាផ្សេងៗ។

ប្រសិនបើប្រើប្រាស់រាងកាយទាំងមូល ការធ្វើចលនាគឺមានលក្ខណៈងាយស្រួល។

⊙ ចំពោះពាក្យបច្ចេកទេសដែលពិបាកៗ គឺមានបញ្ចូលនូវការពន្យល់។

ការពន្យល់

ផ្ទៃទម្រ

គឺសំដៅលើវិសាលភាពដែលភ្ជាប់ផ្នែកប៉ះទៅនឹងផ្នែកម្រាលឥដ្ឋដើម្បីគាំទ្ររាងកាយ។ ផ្ទៃដែលព័ទ្ធជុំវិញបាតជើងទាំងសងខាង នៅពេលឈរដោយកន្នែកជើងទាំងសងខាង។

ផ្នែក"ភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ" នឹងធ្វើឲ្យយល់ស៊ីជម្រៅពីភាសាជប៉ុនតាមរយៈការឆ្លើយសំណួរ។

ការប្រឡងវាយតម្លៃសមត្ថភាពភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ ត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ថាតើចេះជប៉ុនដែលគេប្រើប្រាស់ជាក់ស្តែងនៅកន្លែងមើលថែទាំដែរឬក៏អត់។ ដើម្បីចេះភាសាជប៉ុនដែលចាំបាច់សម្រាប់ការធ្វើការងារនៅកន្លែងមើលថែទាំ ការរៀនភាសាជប៉ុនទាក់ទងនឹងការមើលថែទាំរួមផ្សំនឹងការរៀនដើម្បីប្រឡងសមត្ថភាពភាសាជប៉ុន ឬប្រឡងមូលដ្ឋានគ្រឹះភាសាជប៉ុនរបស់មូលនិធិជប៉ុន គឺនឹងធ្វើឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

- ដើម្បីឲ្យស្របទៅនឹងសំណួរនៃការប្រឡង ផ្នែកនេះត្រូវបានរួមផ្សំដោយ "ពាក្យ" (វាក្យស័ព្ទ) "ការសន្ទនានិងការនិយាយស្តី" (សំណួរ) និង "អត្ថបទ" (សំណួរ) ដែលប្រើប្រាស់ញឹកញាប់នៅក្នុងទិដ្ឋភាពនៃការមើលថែទាំ។

- ចំពោះ"ការសន្ទនានិងការនិយាយស្តី" "អត្ថបទ" យើងនឹងបង្កើតសំណួរដោយប្រើប្រាស់សំនួនវោហាស័ព្ទដែលគេប្រើប្រាស់ញឹកញាប់នៅកន្លែងមើលថែទាំ។

មាតិកា

はじめに 1

របៀបប្រើប្រាស់សៀវភៅនេះ 2

ជំនាញផ្នែកមើលថែទាំ

PART 1 មូលដ្ឋាននៃការមើលថែទាំ

CHAPTER 1 សេចក្ដីថ្លៃថ្នូររបស់មនុស្សនិងភាពម្ចាស់ការនៅក្នុងការមើលថែទាំ 10

CHAPTER 2 តួនាទីរបស់អ្នកមើលថែទាំ ក្រមសីលធម៌វិជ្ជាជីវៈ 16

CHAPTER 3 ការរក្សាសុវត្ថិភាពនៅក្នុងការមើលថែទាំ និងការគ្រប់គ្រងហានីភ័យ 24

PART 2 ការស្វែងយល់អំពីប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្ត

CHAPTER 1 ការស្វែងយល់អំពីប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្ត 42

CHAPTER 2 ការស្វែងយល់អំពីមនុស្សដែលត្រូវការការមើលថែទាំ 68

—— ការស្វែងយល់ជាមូលដ្ឋានអំពីភាពចាស់ជរា

—— ការស្វែងយល់ជាមូលដ្ឋានអំពីពិការភាព

—— ការស្វែងយល់ជាមូលដ្ឋានអំពីជំងឺភ្លេចភ្លាំង

PART 3 បច្ចេកទេសក្នុងការប្រាស្រ័យទាក់ទង

CHAPTER 1 មូលដ្ឋាននៃការប្រាស្រ័យទាក់ទង 98
CHAPTER 2 ការប្រាស្រ័យទាក់ទងជាមួយអ្នកប្រើប្រាស់ 102
CHAPTER 3 ការប្រាស្រ័យទាក់ទងជាមួយក្រុមការងារ 114

PART 4 បច្ចេកទេសផ្តល់ជំនួយនៅក្នុងការរស់នៅ

CHAPTER 1 ការមើលថែទាំនៅពេលផ្លាស់ទី 120
CHAPTER 2 ការមើលថែទាំនៅពេលបរិភោគអាហារ 144
CHAPTER 3 ការមើលថែទាំនៅពេលបញ្ចេញចោល 152
CHAPTER 4 ការមើលថែទាំនៅពេលរៀបចំខ្លួន 170
CHAPTER 5 ការមើលថែទាំនៅពេលងូតទឹកនិងរក្សាអនាម័យ 186
CHAPTER 6 ការមើលថែទាំនៅពេលធ្វើការងារផ្ទះ 198

ភាសាជប៉ុនទាក់ទងនឹងការមើលថែទាំ

សូមចងចាំពាក្យ!

រាងកាយ 204
ឥរិយាបថរាងកាយ 206
ជំងឺនិងរោគសញ្ញា 207

ការមើលថែទាំនៅពេលផ្លាស់ទី

ពាក្យ 208
សំណួរ(ការសន្ទនានិងការនិយាយស្តី) 209

ការមើលថែទាំនៅពេលបរិភោគអាហារ

ពាក្យ 213
សំណួរ(ការសន្ទនានិងការនិយាយស្តី) 215

ការមើលថែទាំនៅពេលបញ្ចេញចោល

ពាក្យ 219
សំណួរ(ការសន្ទនានិងការនិយាយស្តី) 220

ការមើលថែទាំនៅពេលរៀបចំខ្លួន

ពាក្យ 224
សំណួរ(ការសន្ទនានិងការនិយាយស្តី) 225

ការមើលថែទាំនៅពេលងូតទឹកនិងរក្សាអនាម័យ

ពាក្យ 230
សំណួរ(ការសន្ទនានិងការនិយាយស្តី) 231

ការមើលថែទាំនៅពេលធ្វើការងារផ្ទះ

ពាក្យ 238
សំណួរ(ការសន្ទនានិងការនិយាយស្តី) 239

អត្ថបទ

ពាក្យ 245
សំណួរ(អត្ថបទ) 247

ផ្នែកចម្លើយ

ចម្លើយចំពោះសំណួរ"ការសន្ទនានិងការនិយាយស្តី" "អត្ថបទ" 271
ក្រដាសឆ្លើយសំណួរ 272

ការណែនាំអំពី **“Nihongo o Manabou”** ដែលជាការសិក្សាភាសាជប៉ុននៅលើវេបសាយ

PART 1

មូលដ្ឋាននៃការមើលថែទាំ

CHAPTER 1 សេចក្ដីថ្លៃថ្នូររបស់មនុស្សនិងភាពម្ចាស់ការនៅក្នុងការមើលថែទាំ

CHAPTER 2 តួនាទីរបស់អ្នកមើលថែទាំក្រមសីលធម៌វិជ្ជាជីវៈ

CHAPTER 3 ការរក្សាសុវត្ថិភាពនៅក្នុងការមើលថែទាំនិងការគ្រប់គ្រងហានិភ័យ

CHAPTER

1 សេចក្ដីថ្លៃថ្នូររបស់មនុស្សនិងភាពម្ចាស់ការនៅក្នុងការមើលថែទាំ

1 ការមើលថែទាំដែលគាំទ្រដល់សេចក្ដីថ្លៃថ្នូរ

1) សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការគោរពសិទ្ធិមនុស្ស

- ការងារមើលថែទាំ គឺជាវិជ្ជាជីវៈជំនាញដែលផ្ដល់ជំនួយដល់អ្នកដែលមានបញ្ហានៅក្នុងការរស់នៅប្រចាំថ្ងៃ ដោយសារតែជរាភាព ឬពិការភាព ដើម្បីឲ្យពួកគាត់អាចបន្តការរស់នៅទៅតាមបែបរបស់ពួកគាត់បាន។
- គំនិតដែលជាមូលដ្ឋាននៃការផ្ដល់ជំនួយនោះ គឺសេចក្ដីថ្លៃថ្នូររបស់មនុស្ស។
- សេចក្ដីថ្លៃថ្នូររបស់មនុស្ស គឺសំដៅលើមនុស្សម្នាក់ៗត្រូវបានគេគោរពក្នុងនាមជាបុគ្គលមួយរូប។
- ទោះបីជាត្រូវការមើលថែជាចាំបាច់ក៏ដោយ ពួកគេត្រូវទទួលបានការគោរព និងការការពារសិទ្ធិក្នុងនាមជាមនុស្សមួយរូប។

2) ការរស់នៅ គឺអ្នកប្រើប្រាស់ជាអ្នកសម្រេច

- ការរស់នៅ គឺជាទម្លាប់ ឬគំនិតរបស់អ្នកដែលរស់នៅ ហើយវាខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ ទោះបីជាត្រូវការការមើលថែទាំក៏ដោយ អ្នកសម្រេចនៅក្នុងការរស់នៅ គឺខ្លួនអ្នកប្រើប្រាស់ផ្ទាល់។
- ការផ្ដល់ជំនួយ ដើម្បីឲ្យពួកគាត់អាចរស់នៅទៅតាមបែបរបស់ពួកគាត់បានដោយគោរពនូវគំនិត ឬរបៀបនៃការរស់នៅ ថាតើចង់រស់នៅបែបណា គឺជាមូលដ្ឋាននៃការមើលថែទាំ។

● បែបបទនៃការរស់នៅផ្សេងៗ

3) QOL (Quality of life:គុណភាពនៃការរស់នៅ)

- QOL ក៏ត្រូវបានគេហៅថា គុណភាពនៃឆាកជីវិត ឬគុណភាពនៃជីវិតផងដែរ។ QOL គឺជាគំនិតនៃការរស់នៅដែលរួមមានភាពសម្បូរបែបផ្នែកស្មារតី ដូចជាមូលហេតុនៃការរស់នៅ អារម្មណ៍សុភមង្គល ឬអារម្មណ៍ពេញចិត្តចំពោះឆាកជីវិត។

4) ប្រក្រតីភាវូបនីយកម្ម

- ប្រក្រតីភាវូបនីយកម្ម ជាគំនិតដែលគិតថាជនពិការគឺដូចមនុស្សដែលមិនពិការដែរ ដែលទទួលបាននូវការគោរពសិទ្ធិមនុស្ស ដោយមិនមានការរើសអើង ហើយអាចរស់នៅដូចមនុស្សធម្មតាបាន។
- ការបន្តការរស់នៅធម្មតា ក្នុងនាមជាខ្លួនឯង ដោយមិនចាំបាច់អត់ទ្រាំ នៅក្នុងសង្គម ឬតំបន់។

2 ការផ្តល់ជំនួយឲ្យមានភាពម្ចាស់ការ

1) ជួយឲ្យមានភាពម្ចាស់ការ

- ការផ្តល់ជំនួយឲ្យមានភាពម្ចាស់ការ គឺជាការជួយអ្នកប្រើប្រាស់ឲ្យរស់នៅជីវិតដែលខ្លួនចង់បាន ដោយជ្រើសរើសថាតើចង់រស់នៅបែបណា ហើយធ្វើការសម្រេចចិត្តដោយខ្លួនឯង។ ត្រូវជួយឲ្យស្របទៅតាមសមត្ថភាពដែលគាត់មាន មិនមែនត្រឹមតែចលនារាងកាយដូចជាការផ្លាស់ទី ឬការស្លៀកពាក់នោះទេ។
- ត្រូវជួយឲ្យអ្នកប្រើប្រាស់មានអារម្មណ៍ថាទទួលបានជោគជ័យ ដោយបង្កើននូវរឿងដែលសាមីខ្លួនអាចធ្វើបានទៅតាមឆន្ទៈ ឬក៏សមត្ថភាពផ្ទាល់ខ្លួន ហើយយកគុណតម្លៃឬការទាមទាររបស់គាត់ជាសំខាន់។

2) ជម្រើសផ្ទាល់ខ្លួននិងការសម្រេចចិត្តផ្ទាល់ខ្លួន

- អ្នកសម្រេចលើការរស់នៅ គឺខ្លួនអ្នកប្រើប្រាស់ផ្ទាល់។ គាត់សម្រេចថាខ្លួនចង់ធ្វើបែបណាទៅតាមរបៀបនៃការរស់នៅ និងគុណតម្លៃរហូតមកដល់ត្រឹមពេលនេះ។
- ភាពម្ចាស់ការ គឺមានភាពម្ចាស់ការខាងផ្នែករាងកាយ និងភាពម្ចាស់ការខាងផ្លូវចិត្ត។ ទោះបីជាត្រូវការការមើលថែទាំក៏ដោយ ត្រូវសម្រេចជ្រើសរើសដោយខ្លួនឯងនូវរបៀបឬមធ្យោបាយនៃការរស់នៅដើម្បីអាចធ្វើការរស់នៅតាមបែបរបស់ខ្លួនឯងបាន។



3 ការស្វែងយល់អំពីការរស់នៅ

1) ការរស់នៅគឺជា

- នៅក្នុងការរស់នៅ វប្បធម៌ និងទំនៀមទម្លាប់មានភាពខុសគ្នាទៅតាមប្រទេស។ របៀបនៃការរស់នៅ មានផ្សេងៗគ្នាជាច្រើន ទៅតាមឆន្ទៈ គុណតម្លៃ ឬការទាមទាររបស់បុគ្គលម្នាក់ៗ។
- ចង្វាក់នៃការរស់នៅ មានការក្រោកពីគេង ការប្តូរសំលៀកបំពាក់ ការលុបមុខ ការបរិភោគអាហារ ការបញ្ចេញចោល ការងូតទឹក សកម្មភាពពេលទំនេរ និងការចូលគេងនៅពេលយប់។



- ស្ថានភាពសុខភាពរបស់សាមីខ្លួន ទីលំនៅ សមត្ថភាពធ្វើការងារផ្ទះ គ្រួសារ តំបន់ និងសង្គមជាដើម គឺមានទំនាក់ទំនងជាមួយនឹងការរស់នៅ។

2) ការផ្តល់ជំនួយក្នុងការរស់នៅដោយអ្នកមើលថែទាំ

- ការមើលថែទាំដោយស្វែងយល់ឲ្យបានគ្រប់ជ្រុងជ្រោយនូវរបៀបនៃការរស់នៅរបស់អ្នកប្រើប្រាស់ គឺនឹងជួយឲ្យពួកគាត់រស់នៅទៅតាមបែបរបស់ពួកគាត់។
- នៅពេលដែលត្រូវការការមើលថែទាំ ការគិតនិងសកម្មភាពគឺ ងាយនឹងមានភាពអវិជ្ជមាន។ អ្នកមើលថែទាំ ត្រូវធ្វើឲ្យអ្នកប្រើប្រាស់បញ្ចេញនូវចំណង់របស់ខ្លួន។

CHAPTER

2 តួនាទីរបស់អ្នកមើលថែទាំ ក្រមសីលធម៌វិជ្ជាជីវៈ

1 ក្រមសីលធម៌វិជ្ជាជីវៈរបស់អ្នកមើលថែទាំ

1) ការគិតដល់ភាពឯកជន

- នៅកន្លែងងូតទឹក ឬបញ្ចេញចោល អ្នកប្រើប្រាស់នឹងលេចចេញនូវសាច់របស់ខ្លួន។ អ្នកមើលថែទាំ ចាំបាច់ត្រូវគិតដល់ភាពឯកជនរបស់អ្នកប្រើប្រាស់ ដើម្បីកុំឲ្យគាត់មានអារម្មណ៍ខ្មាសអៀន។

2) ការរក្សាការសម្ងាត់

- អ្នកមើលថែទាំ ចាំបាច់ត្រូវដឹងព័ត៌មានទាក់ទងនឹងអ្នកប្រើប្រាស់ ដើម្បីផ្តល់ការមើលថែទាំដែលសមស្របដល់អ្នកប្រើប្រាស់។ ប៉ុន្តែ អ្នកមើលថែទាំ មិនអាចនិយាយអំពីព័ត៌មានបុគ្គល (អាយុ អាសយដ្ឋាន ឬប្រវត្តិជំងឺជាដើម) ទាក់ទងនឹងអ្នកប្រើប្រាស់ ទៅកាន់អ្នកដទៃ ដោយចិត្តឯងនោះទេ។
- មិនត្រូវបញ្ជូនព័ត៌មានទាក់ទងនឹងអ្នកប្រើប្រាស់តាមរយៈអ៊ីនធើណិត ឬSNSជាដើម ដោយមិនបានទទួលការយល់ព្រមពីអ្នកប្រើប្រាស់ឡើយ។

3) ការហាមឃាត់ចំពោះការឃុំខ្លួន

- ការឃុំខ្លួន គឺសំដៅលើការដកហូតសេរីភាពខាងរាងកាយរបស់អ្នកប្រើប្រាស់។

⦿ ឥទ្ធិពលអាក្រក់នៃការឃុំខ្លួន

ការឃុំខ្លួន គឺផ្តល់នូវឥទ្ធិពលអាក្រក់ដូចជា ការធ្វើឲ្យសមត្ថភាពខាងរាងកាយរបស់អ្នកប្រើប្រាស់មានការធ្លាក់ចុះ និងធ្វើឲ្យជំងឺភ្លេចភ្លាំងកាន់តែអាក្រក់ទៅៗ។

● ឧទាហរណ៍នៃអំពើដែលជាការឃុំខ្លួន

① ការចងដៃជើង
ឬរាងកាយដោយខ្សែមិនឲ្យកម្រើកបាន។

② ការដាក់ចំរឹងដែកជុំវិញគ្រែ ដើម្បីកុំឲ្យចុះពីគ្រែដោយខ្លួនឯងបាន។



③ ការចាក់សោរឲ្យនៅក្នុងផ្ទះ។

④ ការពាក់ខ្សែក្រវាត់ឃាត់ខ្លួន ដើម្បីកុំឲ្យក្រោកឈររួច។

⑤ ការឲ្យផឹកថ្នាំព្យាបាលផ្លូវចិត្តលើសកម្រិត។

4) ទារុណកម្ម

- ទារុណកម្ម គឺសំដៅលើការរំលោភបំពានដល់សិទ្ធិរបស់អ្នកប្រើប្រាស់។

ទម្រង់៥ប្រភេទនៃទារុណកម្ម

① ទារុណកម្មលើរាងកាយ
ប្រើអំពើហិង្សាលើរាងកាយ
របស់អ្នកប្រើប្រាស់។

② ទារុណកម្មលើផ្លូវចិត្ត
ការប្រើប្រាស់ពាក្យសម្ដី ឬ
កាយវិការដែលធ្វើឲ្យរបួសផ្លូវចិត្ត
របស់អ្នកប្រើប្រាស់។

③ ការបោះបង់ចោលការមើលថែទាំ
(ការធ្វេសប្រហែស)
ការទុកចោលអ្នកដែលត្រូវការ
ការមើលថែទាំ។

④ ទារុណកម្មលើផ្នែកសេដ្ឋកិច្ច
ការទទួលបាននូវផលប្រយោជន៍មិនត្រឹមត្រូវលើ
ទ្រព្យសម្បត្តិពីអ្នកប្រើប្រាស់។

⑤ ទារុណកម្មលើផ្លូវភេទ
ការប្រព្រឹត្តនូវអំពើបៀតបៀនកេរ្តិ៍ខ្មាស
លើអ្នកប្រើប្រាស់។

2 ការសហការអន្តរវិជ្ជាជីវៈ

1) វិធីសាស្ត្រក្រុមការងារ

- អ្នកជំនាញខាងវិជ្ជាជីវៈផ្សេងៗក្រៅពីអ្នកមើលថែទាំធ្វើការពាក់ព័ន្ធនឹងអ្នកប្រើប្រាស់ ដោយប្រើប្រាស់នូវជំនាញរៀងៗខ្លួនបំពេញការងារជាក្រុម។



2) តួនាទី និងមុខងាររបស់វិជ្ជាជីវៈដទៃទៀត

(វិជ្ជាជីវៈជំនាញដែលអនុវត្តសកម្មភាពព្យាបាល)

សកម្មភាពព្យាបាល គឺជាសកម្មភាពដែលអនុវត្តឡើងទៅតាមចំណេះដឹង បច្ចេកទេសខាងផ្នែកវេជ្ជសាស្ត្រ។ អ្នកមើលថែទាំ ជាគោលការណ៍គឺមិនអាចធ្វើសកម្មភាពព្យាបាលបានទេ។ អ្នកជំនាញដែលអនុវត្តសកម្មភាពព្យាបាលមាន គ្រូពេទ្យ និងគិលានុបដ្ឋាក។

● គ្រូពេទ្យ

ធ្វើការត្រួតពិនិត្យ និងព្យាបាលជំងឺ។

● គិលានុបដ្ឋាក

ផ្តល់ជំនួយក្នុងការពិនិត្យ ឬព្យាបាលជំងឺ ក្រោមការណែនាំរបស់គ្រូពេទ្យ។

(វិជ្ជាជីវៈជំនាញដែលធ្វើការស្តារនីតិសម្បទា)

វិជ្ជាជីវៈជំនាញដែលអនុវត្តនូវការហ្វឹកហាត់ឲ្យមុខងាររាងកាយឲ្យប្រសើរឡើងវិញ មានដូចជាអ្នកជំនាញផ្នែកព្យាបាលមុខងាររាងកាយ អ្នកជំនាញផ្នែកព្យាបាលមុខងាររាងកាយនិងស្មារតី អ្នកជំនាញព្យាបាលផ្នែកភាសានិងសោតវិញ្ញាណ។

● អ្នកជំនាញផ្នែកព្យាបាលមុខងាររាងកាយ (PT)

ហ្វឹកហាត់មុខងារធ្វើចលនា ដូចជាការដើរជាដើម។

● អ្នកជំនាញផ្នែកព្យាបាលមុខងាររាងកាយនិងស្មារតី (OT)

ហ្វឹកហាត់នូវសកម្មភាពដែលចាំបាច់នៅក្នុងជីវភាពប្រចាំថ្ងៃ។

● អ្នកជំនាញព្យាបាលផ្នែកភាសានិងសោតវិញ្ញាណ (ST)

ហ្វឹកហាត់អ្នកប្រើប្រាស់ដែលពិបាកក្នុងការនិយាយឬលេប (ការលេបអាហារ)។

(វិជ្ជាជីវៈជំនាញទាក់ទងនឹងចំណីអាហារ)

មានអ្នកប្រើប្រាស់ដែលយើងចាំបាច់ត្រូវតែពិចារណាដល់ទម្រង់នៃចំណីអាហារ ឬកាឡូរីជាដើម ដោយសារតែមានជំងឺ។ មានអ្នកជំនាញផ្នែកគ្រប់គ្រងអាហាររូបត្ថម្ភ ដែលជាវិជ្ជាជីវៈជំនាញផ្នែកចំណីអាហារ។

- អ្នកជំនាញផ្នែកគ្រប់គ្រងអាហាររូបត្ថម្ភ

ធ្វើបញ្ជីមុខម្ហូបដោយគិតដល់គុណភាពនៃសារធាតុចិញ្ចឹម។

(វិជ្ជាជីវៈជំនាញដែលធ្វើការពិគ្រោះនិងសម្របសម្រួលទាក់ទងនឹងសេវាកម្មសុខុមាលភាព)

នៅក្នុងការប្រើប្រាស់សេវាកម្មសុខុមាលភាពជាដើម ក្នុងនាមជាអ្នកជំនាញដែលធ្វើការពិគ្រោះនិងសម្របសម្រួលទាក់ទងនឹងសេវាកម្មសុខុមាលភាព អ្នកជំនាញជំនួយផ្នែកមើលថែទាំ ឬអ្នកធ្វើការងារសង្គមកិច្ច ធ្វើការរៀបចំគម្រោងផ្តល់ជំនួយដល់អ្នកប្រើប្រាស់ ។

- អ្នកជំនាញជំនួយផ្នែកមើលថែទាំ (អ្នកគ្រប់គ្រងផ្នែកសេវាមើលថែទាំ)
- អ្នកធ្វើការងារសង្គមកិច្ច (អ្នកជំនាញខាងសុខុមាលភាពសង្គមជាដើម)

ធ្វើការសម្របសម្រួល
ធ្វើទំនាក់ទំនងជាមួយគ្រួសារ ឬទទួលការពិគ្រោះពីអ្នកប្រើប្រាស់។

3 សេវាកម្មមើលថែទាំ

1) សេចក្ដីសង្ខេបអំពីសេវាកម្មមើលថែទាំ

សេវាកម្មមើលថែទាំ មានប្រភេទផ្សេងៗជាច្រើន។

① សេវាកម្មទាក់ទងនឹងការទៅសួរសុខទុក្ខ

- ទៅសួរសុខទុក្ខដល់ផ្ទះអ្នកប្រើប្រាស់ និងផ្ដល់សេវាកម្មដល់អ្នកប្រើប្រាស់។
- មានសេវាកម្មដូចជាការមើលថែទាំដោយការទៅសួរសុខទុក្ខ (សេវាកម្មផ្ដល់ជំនួយដល់គេហដ្ឋាន)។

② សេវាកម្មធ្វើដំណើរទៅមកមណ្ឌល

- សេវាកម្មនេះផ្ដល់សម្រាប់អ្នកប្រើប្រាស់ដែលធ្វើដំណើរទៅមកមណ្ឌលថែទាំនៅពេលថ្ងៃ។
- សេវាកម្មមានដូចជាការមើលថែទាំដោយការធ្វើដំណើរទៅមកមណ្ឌល (សេវាកម្មពេលថ្ងៃ)។

③ សេវាកម្មស្នាក់នៅមណ្ឌល

- សេវាកម្មនេះផ្ដល់សម្រាប់អ្នកប្រើប្រាស់នៅមណ្ឌលថែទាំ។
- សេវាកម្ម មានដូចជាមណ្ឌលមើលថែទាំមនុស្សចាស់ (មណ្ឌលមើលថែទាំមនុស្សចាស់ជាពិសេស) ជាដើម។

① សេវាកម្មទាក់ទងនឹងការទៅសួរសុខទុក្ខ

សេវាកម្មផ្ដល់ជំនួយដល់គេហដ្ឋានជាដើម

គេហដ្ឋាន

② សេវាកម្មធ្វើដំណើរទៅមកមណ្ឌល



គេហដ្ឋាន

សេវាកម្មពេលថ្ងៃជាដើម

③ សេវាកម្មស្នាក់នៅមណ្ឌល



មណ្ឌលមើលថែទាំមនុស្សចាស់ជាពិសេសជាដើម

2) ដំណាក់កាលនៃការមើលថែទាំ

- អ្នកមើលថែទាំ ត្រូវធ្វើការមើលថែទាំទៅតាមផែនការ ក្នុងគោលបំណងជួយអ្នកប្រើប្រាស់ឲ្យមានភាពម្ចាស់ការ។
- នៅក្នុងដំណាក់កាលនៃការមើលថែទាំ គេបង្កើតផែនការមើលថែទាំសម្រាប់អ្នកប្រើប្រាស់ម្នាក់ៗ។

● លំដាប់លំដោយជាមូលដ្ឋាននៃដំណាក់កាលមើលថែទាំ

① ការវិភាគ

ប្រមូលព័ត៌មានទាក់ទងនឹងអ្នកប្រើប្រាស់ រួចធ្វើការវិភាគអំពីបញ្ហានៃការរស់នៅ។

② ការបង្កើតផែនការ

បង្កើតខ្លឹមសារនៃផែនការមើលថែទាំដែលត្រូវផ្តល់ឲ្យអ្នកប្រើប្រាស់។

③ ការអនុវត្ត

អនុវត្តនូវការមើលថែទាំទៅតាមផែនការមើលថែទាំចំពោះអ្នកប្រើប្រាស់។

④ ការវាយតម្លៃ



ធ្វើការវាយតម្លៃ ថាតើខ្លឹមសារនៃផែនការមើលថែទាំ សមស្របចំពោះអ្នកប្រើប្រាស់ដែរឬទេ។

CHAPTER

3 ការរក្សាសុវត្ថិភាពនៅក្នុងការមើលថែទាំ និងការគ្រប់គ្រងហានិភ័យ

1 ការរក្សាសុវត្ថិភាពនៅក្នុងការមើលថែទាំ

1) សារៈសំខាន់នៃការសង្កេតមើល

◉ ការសង្កេតមើលគឺជា

ការមើលដោយប្រុងប្រយ័ត្នដើម្បីឲ្យដឹងពីស្ថានភាពរបស់អ្នកប្រើប្រាស់។

◉ អត្ថន័យនៃការសង្កេតមើល

ការសង្កេតមើលរបស់អ្នកមើលថែទាំ គឺដើម្បីធ្វើឲ្យប្រសើរឡើងនូវការរស់នៅរបស់អ្នកប្រើប្រាស់។

ធ្វើការកត់ត្រានូវការសង្កេតមើល រួចចែករំលែកដល់បុគ្គលិកទាំងឡាយ។

◉ របៀបនៃការសង្កេតមើល

① ទទួលបានព័ត៌មានដោយការធ្វើទំនាក់ទំនងជាមួយអ្នកប្រើប្រាស់។

② ទទួលបានព័ត៌មានតាមរយៈការវាស់ស្ទង់ជាដើម។

2) ការគ្រប់គ្រងសុខភាពរបស់អ្នកមើលថែទាំខ្លួនឯង

◉ សារៈសំខាន់នៃការគ្រប់គ្រងសុខភាពរបស់អ្នកមើលថែទាំ

អ្នកមើលថែទាំចាំបាច់ត្រូវរក្សាសុខភាពខ្លួនឯងឲ្យបានល្អ។ អ្នកមើលថែទាំ ប្រសិនបើគ្មានសុខភាពល្អទេ មិនអាចធ្វើការមើលថែទាំបានល្អប្រសើរនោះទេ។

◉ ចំណុចចាំបាច់ក្នុងការរក្សាសុខភាព
(ការទប់ស្កាត់អាការឈឺចង្កេះ)

អ្នកមើលថែទាំ ត្រូវប្រុងប្រយ័ត្នជានិច្ច ដោយសារតែងាយនឹងកើតមានអាការឈឺចង្កេះ។ គេអាចទប់ស្កាត់អាការឈឺចង្កេះ ដោយចំណេះដឹង និងការអនុវត្តដែលត្រឹមត្រូវ។

● ឥរិយាបថ និងអាការឈឺចង្កេះ



ការប្រើប្រាស់យន្តការរាងកាយ
(ម៉េកានិចរាងកាយ)
ដើម្បីទប់ស្កាត់អាការឈឺចង្កេះ។



វាងាយនឹងផ្តល់បន្ទុកដល់ចង្កេះ។

3) ការប្រើប្រាស់គោលការណ៍នៃយន្តការរាងកាយ

- ចាំបាច់ត្រូវបន្ថយបន្ទុករបស់អ្នកមើលថែទាំ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ នៅពេលមើលថែទាំពេលផ្លាស់ទី។
- យន្តការរាងកាយ គឺជារចនាសម្ពន្ធនៃចលនារាងកាយដែលកើតឡើងដោយទំនាក់ទំនងរវាងឆ្អឹង និងសាច់ដុំ។ តាមរយៈការប្រើប្រាស់គោលការណ៍នៃយន្តការរាងកាយ គេអាចធ្វើការមើលថែទាំដោយសុវត្ថិភាពដោយប្រើប្រាស់កម្លាំងតិច។

① យកផ្ទៃទម្រឲ្យបានទូលាយ ហើយបន្ទាបទីប្រជុំទម្ងន់ឲ្យទាប។





ការពន្យល់

ផ្ទៃទម្រ

គឺសំដៅលើវិសាលភាពដែលភ្ជាប់ផ្នែកប៉ះទៅនឹងផ្ទៃកម្រាលឥដ្ឋដើម្បីគាំទ្ររាងកាយ។ ផ្ទៃដែលព័ទ្ធជុំវិញបាតជើងទាំងសងខាង នៅពេលឈរដោយកន្ទែកជើងទាំងសងខាង។

② ធ្វើឲ្យទីប្រជុំទម្ងន់របស់ខាងអ្នកមើលថែទាំ
និងខាងអ្នកដែលត្រូវគេមើលថែទាំ ឲ្យនៅកៀកគ្នា។





③ ប្រើប្រាស់ក្រុមសាច់ដុំដែលធំៗ ដូចជាភ្លៅជាដើម។



ប្រើប្រាស់ក្រុមសាច់ដុំដែលធំ
នៅផ្នែកកំភួនជើង
និងកំប៉េះគូទ។

លើកឡើងលើដោយប្រើតែ
សាច់ដុំផ្នែកចង្កេះនិងខ្នង
ដោយមិនបន្ទន់ជង្គង់។



④ បត់រាងកាយអ្នកប្រើប្រាស់ឲ្យតូច។



⑤ ត្រូវ"ទាញ"មកខាងមុខ ជាជាងការ"រុញ"។



⑥ ការផ្លាស់ទីទីប្រជុំទម្ងន់ ត្រូវធ្វើឡើងតាមទិសផ្តេកតាមដែលអាចធ្វើបាន។



⑦ ចុងជើងត្រូវបែរទៅទិសដែលផ្លាស់ទីដោយមិនបត់ឲ្យវៀចខ្លួន។

⑧ ប្រើប្រាស់គោលការណ៍របស់ឃ្នាស់។



◉ ចំណុចសំខាន់ក្នុងការទប់ស្កាត់អាការឈឺចង្កេះ

- ការប្រើប្រាស់សមត្ថភាពរបស់អ្នកប្រើប្រាស់:ប្រើប្រាស់កម្លាំងរបស់អ្នកប្រើប្រាស់ ដោយពិនិត្យលើស្ថានភាពរបស់អ្នកប្រើប្រាស់។
- ការប្រើប្រាស់ឧបករណ៍ជំនួយ:ប្រើប្រាស់ឧបករណ៍យោង ឬបន្ទះក្តារប្រើនៅពេលរំកិលទីតាំងជាដើម។
- ប្រើប្រាស់យន្តការរាងកាយ
- ការត្រួតពិនិត្យឡើងវិញនូវទម្លាប់នៃការរស់នៅ:ការសម្រាក សារធាតុចិញ្ចឹម ការហាត់ប្រាណដែលសមស្រប គឺមានសារៈសំខាន់ណាស់។



ឧបករណ៍យោងដើម្បីផ្លាស់ទី

បន្ទះក្តារប្រើនៅពេលរំកិលទីតាំង

◉ ការគ្រប់គ្រងសុខភាពផ្លូវចិត្ត

អ្នកមើលថែទាំចាំបាច់ត្រូវរក្សាសុខភាពផ្លូវចិត្តខ្លួនឯងឲ្យបានល្អ ដើម្បីធ្វើការងារមើលថែទាំបន្តទៅមុខទៀត។ សូមកុំលាក់ទុកកង្វល់ឬក្តីបារម្ភ តែម្នាក់ឯង។

ការរស់នៅដោយមានវិន័យទៀងទាត់ គឺចាំបាច់សម្រាប់សុខភាពរាងកាយ និងផ្លូវចិត្ត។

● របៀបនៃការរក្សាសុខភាពផ្លូវចិត្ត



រក្សាឲ្យបាននូវពេលវេលាសម្រាប់បរិភោគអាហារ និងពេលវេលាសម្រាប់គេង។

ដឹងពីរបៀបរំសាយភាពតានតឹង (បន្ទូរអារម្មណ៍) ដែលសក្តិសមចំពោះខ្លួនឯង។



និយាយ ឬពិភាក្សាជាមួយសិស្សច្បង ឬមិត្តរួមការងារ។

4) ជំងឺឆ្លង និងវិធានការ

◉ ចំណេះដឹងជាមូលដ្ឋានទាក់ទងនឹងជំងឺឆ្លង

ជំងឺឆ្លង គឺជាជំងឺដែលភ្នាក់ងារបង្កជំងឺចូលទៅក្នុងរាងកាយហើយបង្កើតឡើងនូវរោគសញ្ញាផ្សេងៗ។

អ្នកប្រើប្រាស់ មានស្ថានភាពប្រព័ន្ធភាពស៊ាំខ្សោយ។ នៅពេលរស់នៅជាក្រុម គឺងាយនឹងឆ្លងជំងឺផ្សេងៗ។

អ្នកមើលថែទាំម្នាក់ៗ ចាំបាច់ត្រូវមានចំណេះដឹងអំពីជំងឺឆ្លងទាំងឡាយ។





◉ ប្រភេទផ្សេងៗនៃភ្នាក់ងារបង្កជំងឺ

វត្ថុដែលជាដើមហេតុនៃជំងឺមានដូចជា វីរុស បាក់តេរី ផ្សិត ប៉ារ៉ាស៊ីតជាដើម។

◉ ចំណុចដែលត្រូវធ្វើការសង្កេតមើល

នៅក្នុងវិធានការទប់ស្កាត់ជំងឺឆ្លង ចាំបាច់ត្រូវធ្វើការសង្កេតមើលទៅលើអ្នកប្រើប្រាស់។ ចំណុចត្រូវធ្វើការសង្កេតមើល គឺករណីដែលមើលឃើញនូវរោគសញ្ញាដូចជា ការក្តៅខ្លួន ការក្អួត ការរាករូស ការឈឺពោះ ការឡើងកន្ទួល ឬទឹកមុខមិនល្អជាដើម ចាំបាច់ត្រូវរាយការណ៍ទៅអ្នកជំនាញផ្នែកព្យាបាល ។

⦿ ធាតុផ្សំទាំង3នៃជំងឺឆ្លង និងគោលការណ៍នៃវិធានការ

ធាតុផ្សំទាំង3នៃជំងឺឆ្លងមាន ប្រភពនៃការឆ្លង ផ្លូវចម្លងរោគ អ្នកដែលទទួលជំងឺឆ្លង។ ជំងឺឆ្លងកើតមានឡើងដោយការភ្ជាប់នូវធាតុផ្សំទាំង3។ គោលការណ៍នៃវិធានការទប់ស្កាត់ជំងឺឆ្លង គឺការកាត់ផ្ដាច់នូវការភ្ជាប់ទំនាក់ទំនងរបស់វា។ ការកាត់ផ្ដាច់នូវការភ្ជាប់ទំនាក់ទំនងរបស់វា គឺ ① ការកម្ចាត់នូវប្រភពនៃការឆ្លង ② ការផ្ដាច់ផ្លូវចម្លងរោគ ③ ការពង្រឹងប្រព័ន្ធភាពស៊ាំរបស់អ្នកដែលទទួលជំងឺឆ្លង (មនុស្ស)។

● ធាតុផ្សំទាំង3នៃជំងឺឆ្លង និងគោលការណ៍នៃការកាត់ផ្ដាច់



មូលដ្ឋាននៃការគ្រប់គ្រងការឆ្លង មាន3 ដូចខាងក្រោម។

① កុំយកចូល

② កុំយកចេញ

③ កុំធ្វើឲ្យវាសាយភាយ

● ប្រភេទនៃផ្លូវចម្លងរោគ

ការឆ្លងតាមការបាចសាច

ជំងឺគ្រុនផ្ដាសាយធំជាដើម

ការឆ្លងតាមខ្យល់អាកាស

ជំងឺរបេង ជំងឺកញ្ជ្រឹលជាដើម

ការឆ្លងតាមការប៉ះពាល់

វីរុសណូរ៉ូ (Norovirus) O-157ជាដើម

● ប្រភេទប្រភពនៃការឆ្លង

ឈាម

ធាតុរាវក្នុងខ្លួន
(ទឹកមាត់ ទឹកសំបោរជាដើម)

កាកសំណល់បញ្ចេញចោល
(កម្អួត ទឹកនោម លាមកជាដើម)

⊙ វិធានការបង្ការលក្ខណៈស្តង់ដា (Standard-Precaution)

គឺជាមូលដ្ឋាននៃការគិតដែលចែងថា "គ្រប់វត្ថុទាំងអស់របស់អ្នកជំងឺ ដូចជាឈាម ធាតុរាវក្នុងខ្លួន សារធាតុបញ្ចេញដោយក្រពេញ កាកសំណល់បញ្ចេញចោល ស្នាមរបួស ស្បែក ភ្នាសជាដើម គឺជាវត្ថុដែលមានគ្រោះថ្នាក់ដែលចម្លងជំងឺ ដូច្នេះត្រូវចាត់ចែងឲ្យបានត្រឹមត្រូវ" ។

មិនត្រូវប៉ះពាល់ឈាម ធាតុរាវក្នុងខ្លួន កាកសំណល់បញ្ចេញចោលជាដើមដោយដៃទទេនោះទេ។ ចាំបាច់ត្រូវប្រើប្រាស់ស្រោមដៃនៅពេលមើលថែទាំ។

● ឧទាហរណ៍នៃរបស់ដែលប្រើប្រាស់

ស្រោមដៃ

អៀមប្លាស្ទិច

ម៉ាស



ទោះបីជាពាក់ស្រោមដៃក៏ដោយ ក៏ត្រូវលាងដៃដែរ។

● របៀបប្រើប្រាស់ម៉ាសឲ្យបានត្រឹមត្រូវ



ត្រូវគ្របចាប់ពីច្រមុះរហូតដល់ចង្កា។

⦿ របៀបផ្លាស់ប្តូរស្រោមដៃដែលប្រើប្រាស់រួចហើយបោះចោល

- ត្រូវបោះចោលដោយពន្លាត់ខាងដែលប្រឡាក់ចូលទៅក្នុង។
- ត្រូវបោះចោលនៅកន្លែងដែលបានកំណត់។
- ត្រូវធ្វើការផ្លាស់ប្តូររាល់ការធ្វើសកម្មភាពម្តងៗ។

⦿ របៀបនៃការលាងដៃ និងចំណុចដែលត្រូវប្រុងប្រយ័ត្ន

ការលាងដៃ មានការលាងដោយទឹកហូរនិងសាប៊ូទឹក និងការលាងដោយប្រើប្រាស់អាល់កុលកម្ចាត់មេរោគម្រាមដៃ។

● ផ្នែកដែលងាយនឹងប្រឡាក់



■ ផ្នែកដែលងាយនឹងមិនត្រូវបានលាងឲ្យបានគ្រប់គ្រាន់ជាងគេបំផុត

■ ផ្នែកដែលភាគច្រើនងាយនឹងមិនត្រូវបានលាងឲ្យបានគ្រប់គ្រាន់

ផ្នែកដែលងាយនឹងប្រឡាក់ មានដូចជា ចុងម្រាម ចន្លោះម្រាម ខ្នងដៃ គល់មេដៃ និងកដៃ។

ការលាងដោយទឹកហូរនិងសាប៊ូទឹក



① ដោះចិញ្ចៀន ឬនាឡិកាចេញ។

② ផ្សើមម្រាមដៃដោយទឹកហូរ។

③ យកសាប៊ូទឹកដាក់លើបាតដៃក្នុងបរិមាណសមរម្យ។

④ ញីបាតដៃជាមួយនឹងបាតដៃឲ្យចេញពពុះរួចលាងឲ្យបានគ្រប់គ្រាន់។

⑤ ច្របាច់លាងខ្នងដៃដោយបាតដៃម្ខាងទៀត (ដៃទាំងសងខាង)។

⑥ ច្របាច់លាងចន្លោះម្រាមដៃទាំងសងខាងដោយស៊កម្រាមដៃចូលគ្នា។

⑦ ក្តោប ហើយច្របាច់លាងមេដៃដោយយកដៃម្ខាងទៀត (ដៃទាំងសងខាង)។

⑧ ច្របាច់លាងចុងម្រាមដៃដោយបាតដៃម្ខាងទៀត (ដៃទាំងសងខាង)។

⑨ ច្របាច់លាងឲ្យបានសព្វរហូតដល់កដៃទាំងសងខាង។

⑩ លាងជម្រះឲ្យបានស្អាតដោយប្រើទឹកបង្ហូរ។

⑪ ជូតទឹកចេញដោយប្រើក្រដាសជូតដៃរួចធ្វើវាឲ្យស្ងួតទាំងស្រុង។

ការកម្ចាត់មេរោគនៅលើម្រាមដៃដោយប្រើអាល់កុលត្រដុស

① នៅពេលដែលមានស្នាមប្រឡាក់ដែលអាចមើលឃើញដោយភ្នែក ជាដំបូងត្រូវលាងដៃដោយសាប៊ូទឹកទៅតាមការណែនាំដូចមាននៅទំព័រមុននេះ។

② បត់ក្តោបម្រាមដៃត្រងយកទឹកកម្ចាត់មេរោគម្រាមដៃដែលបាញ់ចេញមកក្នុងបរិមាណសមស្រប។

③ ដុសបាតដៃនិងបាតដៃជាមួយគ្នា។



④ ដុសចុងម្រាម និងខ្នងម្រាមដោយបាតដៃម្ខាងទៀត (ដៃទាំងសងខាង)។

⑤ ដុសខ្នងដៃដោយបាតដៃម្ខាងទៀត (ដៃទាំងសងខាង)។

⑥ ដុសចន្លោះម្រាមដៃទាំងសងខាងដោយស៊កម្រាមដៃចូលគ្នា។

⑦ ក្តោប ហើយមូលដុសមេដៃដោយបាតដៃម្ខាងទៀត (ដៃទាំងសងខាង)។

⑧ ដុសឲ្យបានសព្វរហូតដល់កដៃទាំងសងខាង។

⑨ ដុសរហូតដល់ស្ងួត។

5) ការទប់ស្កាត់គ្រោះថ្នាក់ និងវិធានការសុវត្ថិភាព

ដោយសារតែអ្នកប្រើប្រាស់ជាមនុស្សចាស់ជរា ឬជនពិការ ដូច្នេះហើយងាយនឹងជួបគ្រោះថ្នាក់ណាស់។

[ការបង្ការការរអិលដួល និងការដួលធ្លាក់]

អ្នកប្រើប្រាស់តែងតែធ្វើចលនាផ្លាស់ទី ឬចលនារំកិលឆ្លងជាញឹកញាប់នៅក្នុងការរស់នៅ។ ដូច្នេះហើយ វាងាយនឹងកើតមានគ្រោះថ្នាក់ណាស់។

- ធ្វើការសង្កេតមើលស្ថានភាពរបស់អ្នកប្រើប្រាស់ឲ្យបានដិតដល់។

ទោះបីកិច្ចការដែលតែងតែអាចធ្វើបានក៏ដោយ ក៏មានពេលដែលមិនអាចធ្វើបានដែរ។

- បញ្ជាក់មើលថា តើសម្លៀកបំពាក់ ស្បែកជើងរបស់អ្នកប្រើប្រាស់សមរម្យដែរឬទេ។

ស្បែកជើងផ្ទាត់ឆាប់របូត និងរអិល។ ជើងខោ ប្រសិនបើវែងពេក វាងាយនឹងទាក់ជើង។

- នៅមុនពេលប្រើប្រាស់ឧបករណ៍ជំនួយ ត្រូវធ្វើការត្រួតពិនិត្យជាមុនសិន។



ប្រសិនបើឧបករណ៍ជំនួយខូច
វានឹងក្លាយទៅជាដើមហេតុបង្កឲ្យមានគ្រោះថ្នាក់។

● ពិនិត្យមើលពីបរិស្ថានជុំវិញ

ប្រសិនបើកម្រាលឥដ្ឋសើម វាងាយនឹងធ្វើឲ្យរអិល។

ប្រសិនបើទាក់ខ្សែភ្លើង វាងាយនឹងធ្វើឲ្យដួល។

⦿ ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យ គឺសំដៅលើការប៉ាន់ប្រមាណទុកមុននូវគ្រោះថ្នាក់ដែលអាចកើតមានឡើង រួចហើយរៀបចំគម្រោងជាប្រព័ន្ធដើម្បីបង្ការនូវគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ គោលគំនិតនៃការបង្ការទុកមុនចំពោះអ្វីដែលអាចបង្ការបាន ដោយប៉ាន់ប្រមាណទុកមុននូវគ្រោះថ្នាក់គឺពិតជាសំខាន់ខ្លាំងណាស់។

ដើម្បីដឹងពីគ្រោះថ្នាក់ ត្រូវបន្សល់ទុកនៅកំណត់ត្រាឲ្យបានត្រឹមត្រូវ។ ដើម្បីបង្ការគ្រោះថ្នាក់កំណត់ត្រា គឺមានសារៈសំខាន់ខ្លាំងណាស់។

● ឧទាហរណ៍ជាក់ស្តែងនៃការគ្រប់គ្រងហានិភ័យ

① អ្នកប្រើប្រាស់ចង់រអិលដួល នៅពេលកំពុងផ្លាស់ទីពីគ្រែទៅកៅអីរុញ។

② គិតមើលថាហេតុអ្វីបានជាកើតឡើង
⇒ ភ្លេចដាក់ហ្វ្រាំង។
⇒ បន្សល់ទុកកំណត់ត្រា។

③ វិធានការបង្ការ
⇒ ចាប់ពីពេលក្រោយទៅ ចាំបាច់ត្រូវបញ្ជាក់មើលថាតើមានដាក់ហ្វ្រាំងដែរឬអត់។
⇒ ចែករំលែកព័ត៌មានជាមួយបុគ្គលិកទាំងអស់។

⦿ វិធានការបង្ការគ្រោះមហន្តរាយ

គ្រោះមហន្តរាយ គឺសំដៅលើអន្តរាយដែលទទួលរង ដោយការរញ្ជួយដី ខ្យល់ព្យុះ គ្រោះអគ្គីភ័យជាដើម។ នៅក្នុងមណ្ឌល ឬតំបន់ មានត្រៀមនូវប្រព័ន្ធទំនាក់ទំនងនៅពេលមានគ្រោះមហន្តរាយជាប្រចាំ។ ការត្រៀមទុកមុន ដើម្បីកុំឲ្យមានការស្ពន់ស្លោទោះបីជាមានមហន្តរាយកើតឡើងក៏ដោយ គឺជារឿងដែលសំខាន់។

● រៀបចំត្រៀមទុកនូវរបស់ដែលចាំបាច់

● អនុវត្តការហ្វឹកហាត់ពីការទប់ស្កាត់គ្រោះមហន្តរាយ

PART 2

ការស្វែងយល់អំពីប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្ត

CHAPTER 1 ការស្វែងយល់អំពីប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្ត

CHAPTER 2 ការស្វែងយល់អំពីមនុស្សដែលត្រូវការការមើលថែទាំ

— ការស្វែងយល់ជាមូលដ្ឋានអំពីភាពចាស់ជរា

— ការស្វែងយល់ជាមូលដ្ឋានអំពីពិការភាព

— ការស្វែងយល់ជាមូលដ្ឋានអំពីជំងឺភ្លេចភ្លាំង

CHAPTER

1 ការស្វែងយល់អំពីប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្ត

1 ការស្វែងយល់អំពីប្រព័ន្ធនៃផ្លូវចិត្ត

1) ការស្វែងយល់ពីផ្លូវចិត្ត

មនុស្សម្នាក់ៗ មានអារម្មណ៍ និងការគិតរបស់ខ្លួន។ អារម្មណ៍ ការគិត និងរបៀបនៃការបង្ហាញ គឺខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់។

ភាពខុសគ្នានោះ គឺទាក់ទងទៅនឹងបុគ្គលិកលក្ខណៈ និងការរស់នៅនិងការអប់រំរហូតមកដល់ពេលនេះ របស់មនុស្សម្នាក់នោះ។ អារម្មណ៍ និងការគិត ប្រែប្រួលទៅតាមអាយុ ហើយត្រូវបានបង្ហាញជាអារម្មណ៍ ឬចំណង់។

អ្នកមើលថែទាំ ចាំបាច់ត្រូវស្វែងយល់ពីអារម្មណ៍របស់ដៃគូ។

● អារម្មណ៍



ចលនារបស់ផ្លូវចិត្តត្រូវបានបង្ហាញឡើងតាមរយៈទឹកមុខ ឬអាកប្បកិរិយា។

(ចំណង់)

ចំណង់ គឺជាអារម្មណ៍ដែលគិតចង់ធ្វើអ្វីមួយ។ អ្នកមើលថែទាំ ត្រូវជួយអ្នកប្រើប្រាស់ឲ្យអាចរស់នៅបានដោយមានចំណង់។

● ចំណង់

(ភាពតានតឹង)

ភាពតានតឹង គឺសំដៅលើស្ថានភាពអន្ទះសាដែលកើតមានឡើងនៅលើរាងកាយនិងផ្លូវចិត្ត។ មូលហេតុនៃភាពតានតឹងមាន មូលហេតុជាលក្ខណៈរូបដូចជាសំឡេងរំខាន ឬសីតុណ្ហភាពជាដើម មូលហេតុពាក់ព័ន្ធនឹងផ្លូវកាយដូចជាការនឿយហត់ ការគេងមិនបានគ្រប់គ្រាន់ ការឃ្លានជាដើម មូលហេតុដែលពាក់ព័ន្ធស្មារតីនិងសង្គមដូចជាភាពមិនស្ងប់ ការភ័យខ្លាច សេចក្តីរំភើប ទំនាក់ទំនងរវាងមនុស្សនិងមនុស្សជាដើម។

● មូលហេតុនៃភាពតានតឹង

(ការចងចាំ)

ការចងចាំ គឺសំដៅលើការចាំមិនភ្លេចនូវរឿងរ៉ាវទាំងឡាយ។

● ដំណាក់កាលនៃការចងចាំ

ការកត់ចំណាំ (ការចាំនូវអ្វីថ្មី) → **ការរក្សាទុក** (បន្តរក្សាទុកព័ត៌មាន) → **ការនឹកឃើញឡើងវិញ** (ទាញយកព័ត៌មានចេញមក)

● ប្រភេទនៃការចងចាំ

ការចងចាំរយៈពេលខ្លី ការចងចាំមួយរយៈ		
ការចងចាំរយៈពេលវែង ការចងចាំដែលមានរយៈពេលវែង	ការចងចាំព្រឹត្តិការណ៍	ការចងចាំទាក់ទងនឹងបទពិសោធន៍ ឬអនុស្សាវរីយ៍
	ការចងចាំអត្ថន័យ	ការចងចាំទាក់ទងនឹងចំណេះដឹង
	ការចងចាំដែលព័ត៌មានដែលធ្លាប់មានឥទ្ធិពលលើព័ត៌មានថ្មី (Priming)	ការចងចាំដែលចាំដោយមិនដឹងខ្លួន
	ការចងចាំនីតិវិធី	ការចងចាំដែលចាំដោយរាងកាយ

(តម្រូវការ)

សំដៅលើស្ថានភាពដែលគិតថាចង់បានអ្វីមួយ។

ចិត្តវិទូលោក ម៉ាស្លូ (Maslow, A. H.) បានរៀបរាប់ថា តម្រូវការរបស់មនុស្សមាន 5កម្រិត (ទ្រឹស្ដីកម្រិតនៃតម្រូវការរបស់ម៉ាស្លូ)។

● ទ្រឹស្ដីកម្រិតនៃតម្រូវការរបស់ម៉ាស្លូ



2 ការស្វែងយល់អំពីប្រព័ន្ធនៃរាងកាយ

1) ប្រព័ន្ធនៃលំនឹង និងការរក្សាអាយុជីវិត (កម្ដៅក្នុងខ្លួន ដង្ហើម ជីពចរ សម្ពាធឈាមជាដើម)

⦿ លំនឹងសទិសភាព (homeostasis)

លំនឹងសទិសភាព គឺសំដៅលើប្រព័ន្ធរាងកាយដែលទោះបីជាបរិស្ថានមានការប្រែប្រួលក៏ដោយ ក៏អាចធ្វើការរក្សាស្ថានភាពនឹងនរក្នុងរាងកាយរបស់មនុស្សបាន។

ឧទាហរណ៍ នៅពេលដែលកម្ដៅក្នុងខ្លួនកើនឡើងដោយសារតែអាកាសធាតុឡើងក្ដៅ កម្ដៅក្នុងខ្លួននឹងត្រូវបានបញ្ចេញចេញមកខាងក្រៅតាមរយៈញើស រួចហើយធ្វើឲ្យរាងកាយត្រឡប់រកសភាពធម្មតាវិញ។

● មុខងារនៃលំនឹងសទិសភាព

(សញ្ញាដែលទាក់ទងនឹងអាយុជីវិត (Vital signs))

សញ្ញាដែលទាក់ទងនឹងអាយុជីវិត គឺជារបស់ដែលបង្ហាញពីសញ្ញានៃការរស់រានមានជីវិត ដូចជា កម្ដៅក្នុងខ្លួន ដង្ហើម ជីពចរ សម្ពាធឈាមជាដើម។ វាគឺជាសន្ទស្សន៍ដែលឆ្លុះបញ្ចាំងពីស្ថានភាពសុខភាពនិងភាពមិនប្រក្រតី។

① កម្ដៅក្នុងខ្លួន

- កម្ដៅក្នុងខ្លួន មានចង្វាក់ក្នុងរយៈពេល1ថ្ងៃ ដែលវាកើនឡើងនៅពេលថ្ងៃ និងធ្លាក់ចុះនៅពេលយប់ចូលគេង។
- ដោយសារតែវាមានភាពខុសគ្នាខ្លាំងរវាងមនុស្សម្នាក់ៗ ដូច្នេះហើយកម្ដៅធម្មតាក៏ខុសគ្នាទៅតាមមនុស្សម្នាក់ៗផងដែរ។

● កន្លែងវាស់កម្តៅក្នុងខ្លួន និងចំណុចដែលត្រូវប្រុងប្រយ័ត្ន

ក្លៀក

ដាក់ផ្នែកខាងចុងនៃប្រដាប់វាស់កម្តៅទៅក្រោមក្លៀក។

នៅពេលកំពុងវាស់កម្តៅ ត្រូវគាបដៃបិទឲ្យជិត ។

ក្រៅពីនេះ



ប្រដាប់វាស់កម្តៅដែលអាចវាស់កម្តៅតាមរយៈថ្ងាស និងត្រចៀកក៏មានដែរ។

ករណីដែលមានពិការភាព ត្រូវវាស់នៅផ្នែកដែលមិនមានពិការភាព។

② ដង្ហើម

- ជាការស្រូបចូលនូវអុកស៊ីសែន ហើយបញ្ចេញឧស្ម័នកាបូនិចពីក្នុងរាងកាយ។
- ដង្ហើមត្រូវបានធ្វើឡើងជាទៀងទាត់ដោយមិនដឹងខ្លួន។
- ចំនួនដកដង្ហើម ប្រែប្រួលទៅតាមកត្តាផ្សេងៗដូចជា អាយុនិងការធ្វើសកម្មភាព ស្ថានភាពស្មារតី សុខភាពរាងកាយនិងការមានឬគ្មានជំងឺជាដើម។
- ពិនិត្យមើលថា តើការដកដង្ហើមពិបាកឬទេ គ្មានស្លេស្មជាប់ឬទេ គ្មានសំឡេងឬទេ។
- អណ្តាត និងក្រចកឡើងពណ៌ខៀវស្វាយ ក្នុងករណីដែលពិបាកដកដង្ហើមខ្លាំង។ ស្ថានភាពបែបនេះគេហៅថាស្យាណូស៊ីស (cyanosis)។

● ទម្រង់រលកចង្វាក់នៃដង្ហើម



ប្រក្រតី
មនុស្សពេញវ័យ 12-18ដង/នាទី
ការស្រូបចូល និងការបញ្ចេញមកក្រៅ គឺថេរ

③ ជីពចរ

- ជីពចរ គឺជាការលោតនៃបេះដូង ដែលបញ្ជូនទៅកាន់អាកទែ។
- ជាទូទៅ អាយុកាន់តែតិច ចំនួនជីពចរកាន់តែច្រើន ប៉ុន្តែនៅពេលចាស់ទៅចំនួនជីពចរកាន់តែតិច។
- ចំនួនជីពចរ ប្រែប្រួលទៅតាមកត្តាផ្សេងៗដូចជា អាយុនិងការធ្វើសកម្មភាព ស្ថានភាពស្មារតី ស្ថានភាពរាងកាយនិងការមានឬគ្មានជំងឺជាដើម។
- ចំពោះជីពចរ ត្រូវសង្កេតមើលចំនួន ចង្វាក់ និងភាពខ្លាំងខ្សោយ។

● ផ្នែកសំខាន់ៗនៃរាងកាយដែលអាចវាស់ជីពចរបាន



ជីពចរ អាចស្ទង់នៅត្រង់កដៃខាងក្នុង ក្រលៀននិងខ្នងប្រអប់ជើងជាដើម ក្រៅពីផ្នែកចំហៀងក្បាល ក កែងដៃ។

④ សម្ពាធឈាម

- សម្ពាធឈាម គឺសំដៅលើកម្លាំងឈាមដែលបញ្ជូនចេញពីបេះដូងដែលសង្កត់លើសរសៃឈាម (អាកទែ)។
- នៅក្នុងរយៈពេល១ថ្ងៃក៏ដោយ សម្ពាធឈាមគឺមានការប្រែប្រួលជានិច្ច។
- សម្ពាធឈាម ប្រែប្រួលទៅតាមកត្តាផ្សេងៗដូចជា ឥរិយាបថ ការធ្វើសកម្មភាព ស្ថានភាពស្មារតី និងការមានឬគ្មានជំងឺជាដើម។
- ប្រសិនបើសម្ពាធឈាមខ្ពស់នៅតែបន្ត វាមានលទ្ធភាពខ្ពស់ដែលអាចវិវត្តន៍ទៅជាជំងឺបេះដូង ឬជំងឺសរសៃឈាមខួរក្បាល។

● ទំនាក់ទំនងរវាងស្ថានភាពបេះដូង និងសម្ពាធឈាម

អំឡុងពេលដែលបេះដូងរួញ	អំឡុងពេលដែលបេះដូងរីកធំ
សម្ពាធឈាម:ខ្ពស់	សម្ពាធឈាម:ទាប
	
សម្ពាធឈាមនៅពេលដែលបេះដូងរួញ (សម្ពាធឈាមខ្ពស់បំផុត)	សម្ពាធឈាមនៅពេលដែលបេះដូងរីកធំ (សម្ពាធឈាមទាបបំផុត)
សម្ពាធឈាមនៅពេលដែលបេះដូងរួញតូច (អំឡុងពេលដែលបេះដូងរួញ)	សម្ពាធឈាមនៅពេលដែលបេះដូងរីកធំ (អំឡុងពេលដែលបេះដូងរីកធំ)

● ពេលដែលសម្ពាធឈាមឡើងខ្ពស់

នៅពេលដែលរំភើប

ការគេងមិនបានគ្រប់គ្រាន់

នៅពេលពិបាកក្នុងបន្ទោបង់

នៅពេលស្លន់ស្លោ

សីតុណ្ហភាពមានការប្រែប្រួលភ្លាមៗ

នៅពេលធ្វើចលនារហ័ស

(ការនោម) នៅពេលដែលរាន់នោម

● ជំងឺដែលបង្កដោយសម្ពាធឈាមឡើងខ្ពស់



2) រចនាសម្ពន្ធមូលដ្ឋាននៃរាងកាយ

- គេអាចធ្វើការបែងចែករាងកាយជា ផ្នែកក្បាលនិងផ្នែកក (ក) ដងខ្លួន (រាងកាយ) អវយវៈខាងលើ (ដៃទាំងសងខាង) អវយវៈខាងក្រោម (ជើងទាំងសងខាង)។



[ប្រព័ន្ធប្រសាទ]

ប្រព័ន្ធប្រសាទត្រូវបានបែងចែកជាពីរផ្នែកធំៗ គឺមជ្ឈមណ្ឌលប្រសាទ និងបរិមណ្ឌលប្រសាទ។

⦿ មជ្ឈមណ្ឌលប្រសាទ (ខួរក្បាល ខួរឆ្អឹងខ្នង)

- ខួរក្បាល ប្រមូលព័ត៌មានពីរាងកាយទាំងមូល រួចធ្វើការវិភាគនិងវិនិច្ឆ័យ បន្ទាប់មកចេញបញ្ជាទៅរាងកាយទាំងមូល។
- ខួរឆ្អឹងខ្នង ជាប់ទៅនឹងខួរក្បាល
  វាមានមុខងារបញ្ជូនបន្តព័ត៌មានពីរាងកាយទាំងមូលទៅខួរក្បាល និងបញ្ជូនបន្តពីខួរក្បាលទៅរាងកាយទាំងមូលវិញ ហើយវាក៏ធ្វើការបញ្ជា និងវាយតម្លៃលើព័ត៌មានដោយខ្លួនឯងផងដែរ។

⦿ បរិមណ្ឌលប្រសាទ (សរសៃប្រសាទខួរក្បាល សរសៃប្រសាទខួរឆ្អឹងខ្នង)

- ធ្វើការបញ្ជូនព័ត៌មានរវាង មជ្ឈមណ្ឌលប្រសាទជាមួយនឹងសរីរាង្គនៃរាងកាយទាំងមូល។

● បំណែងចែកប្រព័ន្ធប្រសាទ



● ផ្នែកផ្សេងៗនៃខួរក្បាល និងមុខងារសំខាន់ៗ



⊙ ប្រព័ន្ធប្រសាទស្វ័យប្រវត្តិ

- ប្រព័ន្ធប្រសាទស្វ័យប្រវត្តិ គឺជាសរសៃប្រសាទដែលធ្វើការគ្រប់គ្រងមុខងារនៃសរីរាង្គខាងក្នុងដោយមិនដឹងខ្លួន វាត្រូវបានបែងចែកជាប្រព័ន្ធប្រសាទសាំប៉ាទិច(sympathetic nerves) និងប្រព័ន្ធប្រសាទប៉ារ៉ាសាំប៉ាទិច(parasympathetic nerves)។
- ប្រព័ន្ធប្រសាទសាំប៉ាទិច គឺជាសរសៃប្រសាទដែលដំណើរការនៅពេលជ្រួលច្រាលក្នុងចិត្ត ដូចជាពេលកំពុងធ្វើសកម្មភាព មិនស្ងប់ក្នុងចិត្ត ពេលមានអារម្មណ៍ដូចជាខឹង តានតឹងជាដើម។
- ប្រព័ន្ធប្រសាទប៉ារ៉ាសាំប៉ាទិច គឺជាសរសៃប្រសាទដែលដំណើរការនៅពេលបន្ធូរអារម្មណ៍ដូចជាពេលគេង ឬពេលសម្រាកជាដើម។

● ចលនារបស់ប្រព័ន្ធប្រសាទស្វ័យប្រវត្តិ (ប្រព័ន្ធប្រសាទសាំប៉ាទិច(sympathetic nerves) និងប្រព័ន្ធប្រសាទប៉ារ៉ាសាំប៉ាទិច(parasympathetic nerves))

ប្រព័ន្ធប្រសាទសាំប៉ាទិច (sympathetic nerves) (សកម្មភាព)		ប្រព័ន្ធប្រសាទប៉ារ៉ាសាំប៉ាទិច (parasympathetic nerves) (ការសម្រាក)
ជីពចរមានចលនាលឿន	បេះដូង	ជីពចរមានចលនាយឺត
រួញ	សរសៃឈាមបរិមណ្ឌល	រីក
កើនឡើង	សម្ពាធឈាម	ថយចុះ
រីកធំ	រន្ធប្រស្រីភ្នែក	រួមតូច
ទប់ស្កាត់ការធ្វើចលនា	ពោះវៀន	បង្កើនចលនា
បន្ធូរទងសួត	ផ្លូវដង្ហើម	ទងសួតរួញ
ឡើង	ការបែកញើស	ថយចុះ

ប្រព័ន្ធប្រសាទស្វ័យប្រវត្តិ ធ្វើការសម្រួលមុខងាររបស់សរីរាង្គខាងក្នុងជាដើម។
នៅពេលដែលប្រព័ន្ធប្រសាទស្វ័យប្រវត្តិច្របូកច្របល់ ធ្វើឲ្យមានឥទ្ធិពលផ្សេងៗដល់ផ្លូវចិត្តនិងរាងកាយ។

[ប្រព័ន្ធគ្រោងឆ្អឹង]

- នៅក្នុងរាងកាយទាំងមូលរបស់មនុស្ស មានឆ្អឹងតូចធំ ហើយវាផ្សំចូលគ្នាបង្កើតបានទៅជាគ្រោងឆ្អឹង។
- មុខងារសំខាន់ៗរបស់ឆ្អឹងមាន ①តួនាទីជាសសរទ្រទ្រង់រាងកាយ ②តួនាទីជាម៉ាស៊ីនធ្វើចលនា ③ការពារសរីរាង្គខាងក្នុង ④ស្តុកសារធាតុកាល់ស្យូម ⑤ប្រសិទ្ធភាពក្នុងការផលិតឈាម។
- ឆ្អឹងខ្នងរបស់មនុស្ស មានរាងកោងជាទម្រង់អក្សរ S តាមបែបសរីរៈ។

● គំនូសបង្ហាញអំពីគ្រោងឆ្អឹងរបស់មនុស្ស





[ប្រព័ន្ធសាច់ដុំ]

- ទាក់ទងទៅនឹងការបង្កើតសរីរាង្គខាងក្នុងនិងការធ្វើចលនា និងរក្សាឥរិយាបថ។



[ប្រព័ន្ធសរីរាង្គវិញ្ញាណ]

- ការមើលវត្ថុ (ចក្ខុវិញ្ញាណ) ស្តាប់ (សោតវិញ្ញាណ) ដឹងក្លិន (ឃានវិញ្ញាណ) ដឹងរសជាតិ (ជីវ្ហាវិញ្ញាណ) ដឹងពីវត្ថុដែលប៉ះ (កាយវិញ្ញាណ) គឺទទួលនូវរំញោចៗនិមួយៗដោយសរីរាង្គវិញ្ញាណ ហើយបញ្ជូនទៅខួរក្បាលតាមរយៈសរសៃប្រសាទវិញ្ញាណ។

● ប្រព័ន្ធមើលវត្ថុ



● ប្រព័ន្ធស្តាប់សំឡេង



[ប្រព័ន្ធដង្ហើម]

ខ្យល់ដែលត្រូវបានដកដង្ហើមចូល នឹងឆ្លងកាត់ផ្លូវដង្ហើម។ អុកស៊ីសែននឹងត្រូវបានស្ងួតស្រូបយក ហើយឧស្ម័នកាបូនិចនឹងត្រូវបានបញ្ចេញមកក្រៅវិញដោយឆ្លងកាត់តាមផ្លូវដង្ហើម។

ផ្លូវដង្ហើម គឺផ្លូវដែលខ្យល់ឆ្លងកាត់ពីច្រមុះរហូតដល់ស្ងួត។

● សរីរាង្គទាក់ទងនឹងដង្ហើម



◉ ក្អក និងស្លេស្ម

- នៅពេលដែលមានរបស់ប្លែក ដូចជាបាក់តេរី ឬធូលី ចូលក្នុងផ្លូវដង្ហើម វានឹងបញ្ចេញចេញមកក្រៅរាងកាយជាការក្អក ឬស្លេស្ម។

ការក្អករយៈពេលយូរ ឬពណ៌របស់ស្លេស្មមានការប្រែប្រួល គឺជាសញ្ញានៃភាពមិនប្រក្រតី។

[ប្រព័ន្ធរបត់ឈាម]

- វាមានមុខងារដឹកនាំអុកស៊ីសែន សារធាតុចិញ្ចឹម កាកសំណល់តាមចរន្តឈាម ឬទឹករងៃ រួចបញ្ជូនទៅរាងកាយទាំងមូល។

◉ បេះដូង

- បេះដូងត្រូវបានបែងចែកចេញជា4ថត។
- វាធ្វើចលនារីករួមចុះឡើងដដែលៗ ហើយបញ្ចេញឈាមដូចជាស្នប់។

◉ សរសៃឈាម និងឈាម

- អាកទែ គឺជាសរសៃឈាមដែលដឹកជញ្ជូនឈាមដែលសម្បូរអុកស៊ីសែនពីបេះដូងទៅកាន់រាងកាយទាំងមូល។
- វ៉ែន ប្រមូលឈាមដែលសម្បូរឧស្ម័នកាបូនិច ឬកាកសំណល់ពីគ្រប់កន្លែងនៅក្នុងរាងកាយ ហើយបញ្ជូនត្រឡប់ទៅកាន់បេះដូង ឬសួត។
- សរសៃប្តូរ គឺសំដៅលើផ្នែកដែលផ្លាស់ប្តូរពីអាកទែទៅវ៉ែន។

● របត់ឈាមសួតឬរបត់ឈាមខ្លី និងរបត់ឈាមវែង



នៅក្នុងរបត់ឈាមសួតឬរបត់ឈាមខ្លី ឈាមដែលខ្សត់អុកស៊ីសែននឹងប្ដូរទៅជាឈាមដែលសម្បូរអុកស៊ីសែន។

⦿ របត់ឈាមវែង និងរបត់ឈាមសួតឬរបត់ឈាមខ្លី

អាកទែដឹកនាំឈាមដែលសម្បូរអុកស៊ីសែន ហើយវ៉ែនដឹកនាំឈាមដែលខ្សត់អុកស៊ីសែន ដោយធ្វើចលនាជុំវិញរាងកាយ។ គេហៅវាថា របត់ឈាមវែង។

ចលនានៃឈាមដែលហូរចេញពីបេះដូង ហើយត្រឡប់ទៅកាន់បេះដូងវិញ ដោយឆ្លងកាត់តាមសួត គេហៅថា របត់ឈាមសួតឬរបត់ឈាមខ្លី។ ឈាមដែលខ្សត់អុកស៊ីសែន ហូរចេញពីថតក្រោមស្ដាំនៃបេះដូងឆ្លងកាត់អាកទែសួតរួចទៅដល់សួត បន្ទាប់មកធ្វើការផ្លាស់ប្ដូរឧស្ម័ន ក្លាយជាឈាមដែលសម្បូរអុកស៊ីសែន ហើយហូរឆ្លងកាត់វ៉ែនសួតត្រឡប់ទៅថតលើឆ្វេងនៃបេះដូងវិញ។

[ប្រព័ន្ធរំលាយអាហារ]

- គឺជាបំពង់រំលាយអាហារចាប់ពីមាត់ដល់ទ្វារធំ (បំពង់អាហារ ក្រពះ ពោះវៀនតូច ពោះវៀនធំ) ព្រមទាំងសរីរាង្គដែលបញ្ចេញអង់ស៊ីមរំលាយអាហារ។
- វាធ្វើការរំលាយនិងស្រូបយកអាហារ ហើយបឺតយកសារធាតុចិញ្ចឹមដែលចាំបាច់ ហើយបញ្ចេញសំណល់ដែលសល់ពីការរំលាយនិងការស្រូបយកចេញជាលាមក។

● លំហូរនៃអាហារ និងមុខងាររបស់សរីរាង្គនីមួយៗ



① បំពង់អាហារ
អាហារដែលបានលេបចូល ត្រូវបានបញ្ជូនទៅកាន់ក្រពះតាមបំពង់អាហារ។

② ក្រពះ
នៅពេលដែលអាហារត្រូវបានបញ្ជូនទៅដល់ក្នុងក្រពះ ចលនាប៉េរីស្តាល់នឹងចាប់ផ្តើម។
អាហារត្រូវបានរំលាយដោយរសក្រពះ។

③ ពោះវៀនតូច
សារធាតុចិញ្ចឹមនៃអាហារ ត្រូវបានស្រូបយក។

④ ពោះវៀនធំ
ការស្រូបយកសារធាតុចិញ្ចឹមនិងជាតិទឹកបន្តទៅមួយកម្រិតទៀត ហើយលាមកត្រូវបានបង្កើតឡើង។

⑤ ចុងពោះវៀនធំ
នៅពេលដែលលាមកផ្ទុំបានមួយចំនួន វានឹងរំញោចផ្នែកចុងពោះវៀនធំ ហើយធ្វើឲ្យមានចំណង់បន្ទោបង់។

⑥ ទ្វារធំ
សាច់ដុំរង្វង់ទ្វារ ហើយលាមកត្រូវបានបញ្ចេញចេញមកក្រៅ។

[ប្រព័ន្ធទឹកនោម]

- វាធ្វើការបញ្ចេញចោលកាកសំណល់ពីក្នុងរាងកាយ ក្នុងទម្រង់ជាទឹកនោម។
- ទឹកនោម ត្រូវបានបង្កើតឡើងនៅក្នុងតម្រងនោម បន្ទាប់មកត្រូវបានបញ្ជូនទៅកាន់ប្លោកនោម ដោយឆ្លងកាត់តាមបំពង់បង្ហូរទឹកនោម ហើយវាត្រូវបានបញ្ចេញចេញមកក្រៅរាងកាយដោយឆ្លងកាត់បង្ហូរនោមបន្ទាប់ពីត្រូវបានស្តុកទុកមួយរយៈ។



[ប្រព័ន្ធអង់ដូគ្រីន]

- គឺជាសរីរាង្គដែលមានក្រពេញបញ្ចេញអ័រម៉ូន ដែលជួយសម្រួលដល់មុខងារផ្សេងៗរបស់រាងកាយ។



[ប្រព័ន្ធភាពស៊ាំ]

- ភាពស៊ាំ គឺសំដៅលើប្រតិកម្មតបដែលកើតឡើងដើម្បីការពាររាងកាយ ដោយប្រឆាំងទៅនឹងភ្នាក់ងារបង្កជំងឺដូចជាវីរុស ឬបាក់តេរីផ្សេងៗដែលមាននៅក្នុងមជ្ឈដ្ឋានខាងក្រៅ នៅពេលដែលវាជ្រៀតចូលក្នុងរាងកាយ។
- ទម្លាប់នៃការរស់នៅ និងស្ថានភាពផ្លូវចិត្ត ធ្វើឲ្យសមត្ថភាពនៃភាពស៊ាំឡើងខ្លាំង ឬចុះខ្សោយ។

● ទម្លាប់នៃការរស់នៅ និងស្ថានភាពផ្លូវចិត្ត ដែលបង្កើនសមត្ថភាពនៃភាពស៊ាំ

កត្តាដែលបង្កើនសមត្ថភាពនៃភាពស៊ាំ
ការហាត់ប្រាណដែលមានលក្ខណៈសមស្រប
សើចច្រើន
កម្តៅរាងកាយ
ទទួលទានអាហារដែលមានតុល្យភាពល្អ



កត្តាដែលធ្វើឲ្យសមត្ថភាពភាពស៊ាំចុះខ្សោយ
ការកើនអាយុ
ការគេងមិនបានគ្រប់គ្រាន់
ការនឿយហត់
ការហាត់ប្រាណខ្លាំង
ភាពតានតឹងនៃស្មារតី

3) ប្រព័ន្ធរាងកាយដែលទាក់ទងទៅនឹងការសម្រាក និងការគេង

1. ភាពចាំបាច់នៃការសម្រាក និងការគេង

- ការសម្រាក គឺសំដៅលើការសម្រាករាងកាយនិងផ្លូវចិត្តដោយស្ងប់ស្ងាត់ ដោយបញ្ឈប់នូវសកម្មភាពផ្សេងៗ។
- ការសម្រាកដែលសមស្រប គឺជាប្រភពនៃការធូរស្បើយពីការនឿយហត់ និងការរស់នៅដោយភាពរស់រវើក។
- ការគេង គឺជាការសម្រាកខួរក្បាលជាទៀងទាត់។ វាមិនអាចខ្វះបានទេចំពោះសុខភាពរាងកាយ និងផ្លូវចិត្ត។

● ប្រសិទ្ធភាពដែលទទួលបានដោយការគេងដែលមានគុណភាពល្អ

2. ប្រព័ន្ធនៃការគេង

- នៅក្នុងរាងកាយមនុស្ស មាននាឡិកាជីវសាស្ត្រដែលកំណត់ចង្វាក់ជាខួបរយៈពេល1ថ្ងៃ។
- នាឡិកាជីវសាស្ត្រ មានចង្វាក់ថេរ ដែលនឹងត្រូវកំណត់ឡើងវិញនៅពេលត្រូវពន្លឺព្រះអាទិត្យនាពេលព្រឹក។

3. វដ្តនៃការគេង

- ការគេង គឺជាការធ្វើម្តងហើយម្តងទៀតនៃការគេងដោយភ្នែកគ្មានចលនា (គេងស្កប់) និងការគេងដោយភ្នែកមានចលនា (គេងមិនស្កប់) នៅពេល1យប់។
- នៅពេលគេងដោយភ្នែកគ្មានចលនា ខួរក្បាលស្ថិតក្នុងស្ថានភាពសម្រាក។ នៅពេលគេងដោយភ្នែកមានចលនា ខួរក្បាលស្ថិតក្នុងស្ថានភាពមួយដែលប្រហែលនឹងការភ្ញាក់ដឹងខ្លួន។ ការយល់សប្តិ ត្រូវបានគេនិយាយថាកើតឡើងនៅពេលដែលគេងដោយភ្នែកមានចលនា។

● ការគេងដោយភ្នែកគ្មានចលនា

● ការគេងដោយភ្នែកមានចលនា

4. លក្ខណៈពិសេសនៃការគេងរបស់មនុស្សចាស់ជរា

- រយៈពេលនៃការគេង គឺខ្លី។
- រយៈពេលដែលគេងដោយភ្នែកគ្មានចលនា (ការគេងស្កប់) មានការថយចុះ។ ដូច្នេះហើយ គឺនឹងដឹងខ្លួនច្រើនដងដោយសារតែចំណង់នោម ឬដោយសារតែសំឡេងតិចតួចជាដើម។

CHAPTER

2 ការស្វែងយល់អំពីមនុស្សដែលត្រូវការការមើលថែទាំ

1 ការស្វែងយល់ជាមូលដ្ឋានអំពីភាពចាស់ជរា

1) ការស្វែងយល់ពីការប្រែប្រួលនៃរាងកាយនិងផ្លូវចិត្តដោយសារតែភាពចាស់ជរា

1. ភាពចាស់ជរាគឺជា

មនុស្សនៅពេលដែលអាយុមានការកើនឡើង មុខងារនៃរាងកាយ និងផ្លូវចិត្ត មានការចុះខ្សោយ។ គេហៅវាថា ភាពចាស់ជរា។ ភាពចាស់ជរា គឺកើតមានឡើងចំពោះមនុស្សគ្រប់ៗរូប។



(លក្ខណៈពិសេសនៃភាពចាស់ជរា)

- មានភាពខុសគ្នារវាងមនុស្សម្នាក់ៗ។
- ងាយនឹងកើតជំងឺ។
- ទទួលឥទ្ធិពលពីទម្លាប់នៃការរស់នៅ។

2. ការប្រែប្រួលខាងផ្លូវចិត្តដោយសារតែភាពចាស់ជរា

ការប្រែប្រួលខាងផ្លូវចិត្ត មានភាពខុសគ្នារវាងមនុស្សម្នាក់ៗ ដោយសារតែទទួលឥទ្ធិពលផ្សេងៗដូចជាបរិស្ថាននៃការរស់នៅ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងប្រវត្តិនៃការរស់នៅរបស់មនុស្សចាស់។ ដូច្នេះហើយ នៅពេលមើលថែទាំ ចាំបាច់ត្រូវធ្វើការស្វែងយល់ពីភាពខុសគ្នារបស់មនុស្សម្នាក់ៗ។

(ការប្រែប្រួលខាងផ្លូវចិត្ត)

- អារម្មណ៍មិនស្ងប់ អារម្មណ៍អន្ទះអន្ទែង
  មូលហេតុដែលកើតមានឡើងគឺដោយសារតែអ្វីដែលធ្លាប់អាចធ្វើបានកន្លងមក បានប្រែជាមិនអាចធ្វើបានទៀត។
- អារម្មណ៍នៃការបាត់បង់ និងអារម្មណ៍នៃភាពគ្មានកម្លាំង
  វាកើតមានឡើងដោយសារតែការប្រែប្រួលតួនាទី ឬមិត្តភក្តិសាច់ញាតិ ប្តីឬប្រពន្ធស្លាប់ចោលជាដើម។ វាងាយនឹងកើតមានជំងឺបាក់ទឹកចិត្ត ដោយសារតែការប្រែប្រួលខាងផ្លូវចិត្ត។



3. ការប្រែប្រួលនៃរាងកាយដោយសារតែភាពចាស់ជរា

គេអាចមើលឃើញពីការប្រែប្រួលរូបរាងខាងក្រៅ និងផ្នែកខាងក្នុងនៃរាងកាយដោយសារតែភាពចាស់ជរា។



វាធ្វើឲ្យមនុស្សម្នាក់មានជំងឺច្រើនមុខ ហើយងាយនឹងទៅជារ៉ាំរ៉ៃមិនងាយជា និងងាយកើតមានផលវិបាកនៃជំងឺ។

2) លក្ខណៈពិសេសនៃជំងឺ និងរោគសញ្ញាដែលកើតមានច្រើនចំពោះមនុស្សចាស់ជរា

រោគសញ្ញាដែលកើតមានច្រើនចំពោះមនុស្សចាស់ជរា មានដូចជាការខ្សោះជាតិទឹក ការក្តៅខ្លួន ការទល់លាមក ការហើម (ការហើមប៉ោង) ការគេងមិនលក់ រោគសញ្ញានៃការប្រើលែងបាន អាការលោកស្បែកដោយសារគេងយូរជាដើម។

⦿ លក្ខណៈពិសេសនៃជំងឺរបស់មនុស្សចាស់ជរា

- មានជំងឺច្រើនមុខ។
- រោគសញ្ញាជាដើមគឺមានភាពខុសគ្នាខ្លាំងរវាងមនុស្សម្នាក់ៗ។
- ងាយនឹងឈឺ ហើយមានលក្ខណៈរ៉ាំរ៉ៃ។
- មិនងាយនឹងបង្ហាញរោគសញ្ញា (រោគសញ្ញាខុសពីធម្មតា)។

3) រោគសញ្ញាដែលមានច្រើនចំពោះមនុស្សចាស់ជរា

ការខ្សោះជាតិទឹក

ស្ថានភាពដែលបរិមាណជាតិទឹកនៅក្នុងខ្លួនធ្លាក់ចុះក្រោមបរិមាណធម្មតា

ផ្នែកខាងក្នុងនៃរាងកាយ មានផ្ទុកបរិមាណជាតិទឹកថេរ ប៉ុន្តែការខ្សោះជាតិទឹកកើតឡើងដោយសារតែការខូចតុល្យភាពនៃបរិមាណស្រូបយក និងបរិមាណបញ្ចេញចោល។

ដើមហេតុៈ ការរាករូស ការក្អួត ការក្ដៅខ្លួន ការបែកញើស បរិមាណស្រូបយកជាតិទឹកថយចុះជាដើម

រោគសញ្ញាៈ ការស្ងួតបបូរមាត់ ផ្ទៃក្នុងមាត់ និងស្បែក ការថយចុះនៃចំនួនដងបត់ជើងតូចនិងបរិមាណទឹកនោម សម្ពាធឈាមខ្សោយហើយជីពចរដើរលឿន កម្ដៅក្នុងខ្លួនកើនឡើងជាដើម

ចំណុចសំខាន់នៃការមើលថែទាំ

- ទទួលទានជាតិទឹកបំពេញបន្ថែម។
- ធ្វើការគ្រប់គ្រងសីតុណ្ហភាពនៅក្នុងបន្ទប់។
- នៅពេលហាត់ប្រាណ មុននិងក្រោយពេលងូតទឹក ត្រូវធ្វើការផឹកទឹក។
- ការបាត់បង់ជាតិទឹកធ្ងន់ធ្ងរ អាចមានគ្រោះថ្នាក់ដល់អាយុជីវិត។ ទទួលការពិនិត្យពីស្ថាប័នសុខាភិបាល (មន្ទីរពេទ្យ ឬគ្លីនិក)។

◉ តុល្យភាពនៃបរិមាណជាតិទឹក

ការរក្សាតុល្យភាពនៃជាតិទឹកដែលបាត់បង់ និងជាតិទឹកដែលបានស្រូបចូលដោយការទទួលទានអាហារ ឬភេសជ្ជៈតាមមាត់ គឺនឹងជួយរក្សាការរស់នៅប្រកបដោយសុខភាពល្អ។

ក្តៅខ្លួន

សភាពដែលកម្ដៅក្នុងរាងកាយខ្ពស់ជាងពេលធម្មតា

ការសម្រួលកម្ដៅក្នុងរាងកាយ គឺត្រូវបានធ្វើឡើងដោយក្រពេញអ៊ីប៉ូតាឡាមុស(hypothalamus)នៃខួរធំ។

ដើមហេតុ: ជំងឺឆ្លង អាការរលាក ការខ្សោះជាតិទឹកជាដើម។

រោគសញ្ញា: កម្ដៅឡើងខ្ពស់ មុខឡើងក្រហម ស្លេកស្លាំង គ្មានចំណង់អាហារជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ទទួលទានជាតិទឹកបំពេញបន្ថែម។
- ធ្វើការវាស់កម្ដៅក្នុងខ្លួន។
- ចំពោះមនុស្សចាស់ជរា ពេលខ្លះពិបាកដឹងពីរោគសញ្ញានៅពេលក្ដៅខ្លួន។
- ពិនិត្យមើលផងដែរថាគ្មានរោគសញ្ញាផ្សេងឬទេ។

ទល់លាមក

ស្ថានភាពដែលលាមកស្ថិតនៅក្នុងពោះវៀនធំរយៈពេលយូរ

ជាធម្មតា ចំណីដែលបានបរិភោគ នឹងត្រូវបញ្ចេញចេញមកក្រៅជាលាមកក្នុងរយៈពេលប្រហែល24 - 72ម៉ោង។

ដើមហេតុ: មុខងាររបស់ពោះវៀនចុះខ្សោយ ហើយកម្លាំងសាច់ដុំចុះខ្សោយ ការទ្រាំមិនទៅបន្ទោបង់ជាដើម។

រោគសញ្ញា: ការមិនឃ្លានអាហារ ការឈឺពោះ អារម្មណ៍ចង់ក្អួតជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ធ្វើការហាត់ប្រាណឲ្យបានសមស្រប និងញ៉ាំអាហារសម្បូរជាតិសរសៃ។
- បង្កើតទម្លាប់ចូលបង្គន់ក្រោយពេលបរិភោគអាហាររួច។
- ធ្វើការម៉ាស្សាទៅតាមចលនាពោះវៀន។

● ការម៉ាស្សាទៅតាមចលនាពោះវៀន



ការហើម (ការហើមប៉ោង)

ស្ថានភាពដែលចលនាឈាមរត់មិនល្អនិងមានធាតុរាវដែលមិនចាំបាច់នៅក្នុងខ្លួន ដោយសារតែមុខងារសរីរាង្គក្នុងខ្លួនចុះខ្សោយនិងកម្លាំងសាច់ដុំចុះខ្សោយជាដើម។

ដើមហេតុៈ កម្លាំងសាច់ដុំអវយវៈខាងក្រោមចុះខ្សោយ មុខងារបេះដូងនិងតម្រងនោមចុះខ្សោយ ភាពខ្វះសារធាតុចិញ្ចឹមនៃមនុស្សចាស់ជរា ការអង្គុយក្នុងរយៈពេលយូរជាដើម។

រោគសញ្ញាៈ ការឡើងទម្ងន់ជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ពិនិត្យមើលផ្នែករាងកាយនិងកម្រិតដែលហើម។
- មនុស្សដែលមានភាពពិការ គឺងាយនឹងកើតនៅត្រង់ខាងដែលមានបញ្ហា។
- លើកអវៈយវៈខាងក្រោមឲ្យខ្ពស់ និងធ្វើការហាត់ប្រាណដែលសមស្រប។
- នៅពេលដែលមានជំងឺដែលជាមូលហេតុបង្ក ត្រូវទទួលការព្យាបាល។



អាការរមាស់ (ការរមាស់)

ស្ថានភាពដែលមានការរមាស់នៅលើស្បែក។

ដើមហេតុៈ ការប្រែប្រួលនៃកម្តៅនិងសំណើមនិងភាពស្ងួតនៃស្បែកដោយសារតែភាពចាស់ជរា មូលហេតុដែលបង្កដោយប្រភេទសំលៀកបំពាក់ជាដើម។

រោគសញ្ញាៈ កន្ទួលក្រហម ឡើងកន្ទួល អារម្មណ៍អន្ទះអន្ទែងជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ធ្វើការរក្សាសំណើមដល់ស្បែក។
- ព្យាយាមកុំឲ្យស្បែកមានរបួស និងកុំអត់ចូលគេង។ ដោយសារតែវាក៏មានករណីឆ្លងផងដែរ ត្រូវសហការជាមួយនឹងអ្នកជំនាញផ្នែកព្យាបាល។

ការគេងមិនលក់

ស្ថានភាពនៃការគេងមិនគ្រប់គ្រាន់ ដូចជាការមិនងងុយគេង គេងមិនស្រួល ឬភ្ញាក់កណ្តាលយប់ជាដើម។
ស្ថានភាពនៃការគេងមិនគ្រប់គ្រាន់ ដូចជាការគេងមិនស្កប់ ពិបាកគេងលក់ ឬភ្ញាក់កណ្តាលយប់ជាដើម។

ដើមហេតុ: ការប្រែប្រួលខ្លឹមសារនៃការគេងជាដើម។

រោគសញ្ញា: អារម្មណ៍អន្ទះអន្ទែង អារម្មណ៍បាត់នឿយ អារម្មណ៍ល្ងិតល្ងៃជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- រៀបចំចង្វាក់នៃការរស់នៅឲ្យរៀបរយ។
- ធ្វើការហាលថ្ងៃនៅពេលក្រោកពីគេង។
- ធ្វើការហាត់ប្រាណឲ្យបានសមស្រប។
- កុំគេងពេលថ្ងៃក្នុងរយៈពេលយូរ។
- រៀបចំបរិស្ថាននៅក្នុងបន្ទប់។
- ករណីមានឧបសគ្គនៅក្នុងការរស់នៅ ត្រូវសហការជាមួយអ្នកជំនាញផ្នែកព្យាបាល។

សម្ពាធឈាមខ្ពស់

ស្ថានភាពដែលមានសម្ពាធឈាមខ្ពស់

ដើមហេតុ: ជំងឺបេះដូងឬតម្រងនោម ការប្រែប្រួលនៃសរសៃឈាមដោយសារតែការកើនអាយុ ទម្លាប់នៃការរស់នៅដូចជាការហាត់ប្រាណ ឬការបរិភោគអាហារជាដើម។

រោគសញ្ញា: ការឈឺក្បាល ការញ័រដើមទ្រូងជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ធ្វើការកែលម្អទម្លាប់នៃការរស់នៅ។ ត្រូវប្រុងប្រយ័ត្នចំពោះចំណីអាហារ ដូចជាកុំញ៉ាំឲ្យឆ្អែតពេក និងជៀសវាងជាតិប្រៃជាដើម។ ធ្វើការហាត់ប្រាណឲ្យបានសមស្រប។
- នៅក្នុងការព្យាបាល មានការព្យាបាលតាមរបបអាហារ ការព្យាបាលដោយហាត់ប្រាណ ការព្យាបាលដោយប្រើថ្នាំ។
- នៅពេលដែលស្ថានភាពនៃសម្ពាធឈាមខ្ពស់នៅតែបន្ត វាធ្វើឲ្យកើតមាននូវជំងឺកកខ្លាញ់ក្នុងអាកទែ។ ជំងឺកកខ្លាញ់ក្នុងអាកទែ គឺជាដើមហេតុនៃជំងឺសរសៃឈាមខួរក្បាល និងជំងឺបេះដូង។

4) ជំងឺដែលកើតមានច្រើនចំពោះមនុស្សចាស់ជរា

ជំងឺដែលកើតមានច្រើនចំពោះមនុស្សចាស់ជរាមាន ដូចជាជំងឺសរសៃឈាមខួរក្បាល ជំងឺបេះដូង ជំងឺរលាកសួត រលាកសួតដោយលេបចូលខុសបំពង់អាហារ ជំងឺទឹកនោមផ្អែម ជំងឺខ្វះជាតិកាល់ស្យូម (ជំងឺពុកឆ្អឹង) ជំងឺភ្លេចភ្លាំងជាដើម។

នៅពេលមើលថែទាំ ក៏មានអ្នកដែលត្រូវការការណែនាំពីគ្រូពេទ្យផងដែរ។

ជំងឺសរសៃឈាមខួរក្បាល

គឺជាជំងឺនៃសរសៃឈាមខួរក្បាល។ វាកើតឡើងដោយសារតែសរសៃឈាមដាច់ ឬស្ទះ។ វាអាចនឹងបន្សល់ឲ្យមានពិការភាពផ្សេងៗដោយសារតែផ្នែកណាមួយនៃខួរក្បាលទទួលរងការខូចខាត។

ដើមហេតុៈ ត្រូវបានបែងចែកជា 2ប្រភេទធំៗ។

1 កើតឡើងដោយសារតែសរសៃឈាមនៅក្នុងខួរក្បាលស្ទះ (ជំងឺស្ទះសរសៃឈាមក្នុងខួរក្បាល)។

2 កើតឡើងដោយសារតែដាច់សរសៃឈាមនៅក្នុងខួរក្បាល (ជំងឺចេញឈាមក្នុងខួរក្បាលជាដើម)។

រោគសញ្ញាៈ ការឈឺក្បាល ការវិលមុខ អារម្មណ៍ចង់ក្អួតនិងការក្អួត ពិការផ្នែកស្មារតី ពិការផ្នែកដង្ហើម ពិការផ្នែកសតិបញ្ញា។

ចំណុចសំខាន់នៃការមើលថែទាំ

• ធ្វើការមើលថែទាំទៅតាមរោគសញ្ញារបស់អ្នកប្រើប្រាស់។
• ដោយសារតែវាពាក់ព័ន្ធនឹងទម្លាប់នៃការរស់នៅ ហេតុនេះត្រូវប្រុងប្រយ័ត្នចំពោះបរិមាណនិងរបបអាហារ និងការហាត់ប្រាណ ។

ជំងឺស្ទះសរសៃឈាមក្នុងខួរក្បាល
(សរសៃឈាមស្ទះ)



ជំងឺចេញឈាមក្នុងខួរក្បាល
(សរសៃឈាមដាច់ជាដើម)



ជំងឺបេះដូង

គឺជាជំងឺនៃបេះដូង។វាកើតឡើងដោយសារតែសរសៃឈាមនៃបេះដូងស្ទះជាដើម។

ដើមហេតុៈ សម្ពាធឈាមខ្ពស់ និងទឹកនោមផ្អែម ការប្រែប្រួលនៃសរសៃឈាមក្អូរ៉ូនែ (សរសៃឈាមចិញ្ចឹមបេះដូង)ជាដើម។

- វាកើតឡើងដោយសារតែសរសៃឈាមបេះដូងក្លាយទៅជាចង្អៀត (ជំងឺតឹងទ្រូង)។
- វាកើតឡើងដោយសារតែសរសៃឈាមបេះដូងស្ទះ (ជំងឺស្ទះសាច់ដុំបេះដូង)។
- វាកើតឡើងដោយសារតែការចុះខ្សោយនៃមុខងារបេះដូង (ជំងឺខ្សោយបេះដូង)។

រោគសញ្ញាៈ ចំពោះជំងឺតឹងទ្រូង មានការឈឺចាប់ដើមទ្រូងជាដើម ដោយសារអុកស៊ីសែនមិនគ្រប់គ្រាន់មួយរយៈ។

ចំពោះជំងឺស្ទះសាច់ដុំបេះដូង មានការឈឺចាប់ដើមទ្រូងខ្លាំង ដោយសារការស្លាប់នៃសាច់ដុំបេះដូង។

ចំពោះជំងឺខ្សោយបេះដូង មានអាការដូចជា ពិបាកក្នុងការដកដង្ហើម ការញ័រដើមទ្រូង ដង្ហើមខ្លីដាច់ៗ អារម្មណ៍ល្ហិតល្ហៃ ការហើម ការកើនទម្ងន់ ការថយចុះនៃបរិមាណទឹកនោម ជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ប្រសិនបើមានការហើម និងការកើនទម្ងន់ ចាំបាច់ត្រូវជៀសវាងជាតិប្រៃ និងជាតិទឹក។
- នៅពេលពិបាកដកដង្ហើម ត្រូវសម្រាកឲ្យស្រួល ហើយត្រូវសម្រួលឥរិយាបថរាងកាយឲ្យស្រួល ដើម្បីកាត់បន្ថយបន្ទុករបស់បេះដូង។

ជំងឺតឹងទ្រូង

(សរសៃឈាមបេះដូងចង្អៀត)



ជំងឺស្ទះសាច់ដុំបេះដូង

(សរសៃឈាមស្ទះ)



● ឥរិយាបថរាងកាយដែលបន្ថយបន្ទុករបស់បេះដូង

ជំងឺរលាកសួត

វាកើតឡើងដោយសារតែមានភ្នាក់ងារបង្កជំងឺចូលទៅក្នុងសួត។

ដើមហេតុ: ការឆ្លងភ្នាក់ងារបង្កជំងឺដូចជាបាក់តេរី ឬមេរោគជាដើម។

រោគសញ្ញា: រោគសញ្ញានៃរាងកាយទាំងមូល ដូចជាការក្ដៅខ្លួន អារម្មណ៍ល្វិតល្វៃ និងការមិនឃ្លានអាហារជាដើម។

រោគសញ្ញាសរីរាង្គដង្ហើម ដូចជាការក្អក ឬស្លេស្មជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ទទួលទានបំពេញជាតិទឹកបន្ថែម និងធ្វើអាហារដែលងាយស្រួលញ៉ាំ។
- ករណីមនុស្សចាស់ជរា ដោយសារតែពេលខ្លះក៏មិនមានចេញរោគសញ្ញាដែរ ដូច្នេះហើយ ចាំបាច់ត្រូវធ្វើការប្រុងប្រយ័ត្ន។

រលាកសួតដោយលេបចូលខុសបំពង់អាហារ

វាកើតឡើងដោយសារតែបាក់តេរីរួមជាមួយអាហារនិងទឹកមាត់ចូលខុសទៅក្នុងបំពង់ខ្យល់និងទងសួត។

ដើមហេតុ: កើតឡើងដោយសារតែអាហារ និងជាតិទឹកចូលទៅក្នុងបំពង់ខ្យល់ មិនមែនបំពង់អាហារ។

រោគសញ្ញា: ការក្ដៅខ្លួន ការក្អកនិងស្លេស្ម ការមិនឃ្លានអាហារជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- ប្រុងប្រយ័ត្នចំពោះឥរិយាបថនៅពេលញ៉ាំអាហារ។ រក្សាឥរិយាបថអង្គុយ កុំទម្រេតក្រោយពេលបរិភោគអាហារភ្លាមៗ។
- ធ្វើការថែរក្សាមាត់ធ្មេញ។
- ករណីមានរោគសញ្ញា ត្រូវសហការជាមួយអ្នកជំនាញផ្នែកព្យាបាល។



ជំងឺទឹកនោមផ្អែម

គឺជាជំងឺដែលមេតាបូលីសខុសប្រក្រតីដែលជាតិស្ករនៅក្នុងឈាមឡើងខ្ពស់។

ដើមហេតុៈ ជំងឺទឹកនោមផ្អែមមាន2ទម្រង់

- ជំងឺទឹកនោមផ្អែមទម្រង់ទី1 គឺជាជំងឺដែលខ្វះការបញ្ចេញអាំងស៊ុយលីន។ វាត្រូវបានគេមើលឃើញច្រើននៅលើមនុស្សវ័យក្មេង។
- ជំងឺទឹកនោមផ្អែមទម្រង់ទី2 គឺជាជំងឺដែលថយចុះការបញ្ចេញអាំងស៊ុយលីន។ វាត្រូវបានគេមើលឃើញច្រើននៅលើមនុស្សចាស់ជរា។ វាគឺជាជំងឺទាក់ទងនឹងទម្លាប់នៃការរស់នៅដែលមានដើមហេតុមកពីការញ៉ាំហួសកម្រិត ការហាត់ប្រាណមិនបានគ្រប់គ្រាន់ ភាពតានតឹងជាដើម។

រោគសញ្ញាៈ ការស្រេកទឹក ការញ៉ាំទឹកច្រើននិងការនោមច្រើន ការថយទម្ងន់ អារម្មណ៍ល្ហិតល្ហៃជាដើម។

ចំណុចសំខាន់នៃការមើលថែទាំ

- នៅក្នុងការព្យាបាល មានការព្យាបាលតាមរបបអាហារ ការព្យាបាលដោយហាត់ប្រាណ ការព្យាបាលដោយប្រើថ្នាំជាដើម។
- ចំពោះការព្យាបាលតាមរបបអាហារ ត្រូវទប់ស្កាត់កាឡូរីនៅក្នុងការបរិភោគអាហារ។
- ព្យាយាមលៃយ៉ាងណាកុំឲ្យអារម្មណ៍ចូលចិត្តអាហារមានការធ្លាក់ចុះ។
- នៅពេលដែលជាតិស្ករក្នុងឈាមខ្ពស់នៅតែបន្ត នៅពេលមានរបួស វានឹងពិបាកជាសះវិញ។
- ផលវិបាក គឺមានជំងឺបាតភ្នែក ជំងឺខ្សោយតម្រងនោម ជំងឺវិកលចរិតជាដើម។ ចាំបាច់ត្រូវសហការជាមួយអ្នកជំនាញផ្នែកព្យាបាល ដើម្បីទប់ស្កាត់ផលវិបាកនៃជំងឺ។

● ផលវិបាកនៃជំងឺទឹកនោមផ្អែម



ជំងឺវិកលចរិត



ជំងឺខ្សោយតម្រងនោម



ជំងឺបាតភ្នែក

ជំងឺពុកឆ្អឹង

គឺជាជំងឺដែលឆ្អឹងក្លាយទៅជាផុយស្រួយដោយសារតែការថយចុះនៃកំហាប់ឆ្អឹង។

ដើមហេតុៈ ការគេងផ្ដេកខ្លួនយូរ ការខ្វះជាតិកាល់ស្យូមជាដើម។

មនុស្សស្រី ងាយនឹងកើតជំងឺនេះ ដោយសារតែការថយចុះនៃអ័រម៉ូនភេទស្រី។

រោគសញ្ញាៈ ខ្នងឡើងកោង ថយកម្ពស់ និងឈឺចង្កេះជាដើម។

ដោយសារតែឆ្អឹងក្លាយទៅជាផុយស្រួយ បើដួលគឺងាយនឹងធ្វើឲ្យបាក់ឆ្អឹង ។

ចំណុចសំខាន់នៃការមើលថែទាំ

- ញ៉ាំអាហារដែលមានផ្ទុកជាតិកាល់ស្យូម។
- ធ្វើការហាត់ប្រាណ និងស្រូបយកពន្លឺថ្ងៃជាដើម។
- រៀបចំបរិស្ថានរស់នៅ ដើម្បីបង្ការការដួល។

● ផ្នែកនៃរាងកាយនៃមនុស្សចាស់ជរាដែលភាគច្រើនរងគ្រោះបាក់ឆ្អឹង



2 ការស្វែងយល់ជាមូលដ្ឋានអំពីពិការភាព

1) ពិការភាពគឺជា

ពិការភាព ត្រូវបានគេកំណត់និយមន័យ តាមអនុសញ្ញាស្តីពីសិទ្ធិជនពិការថា "ជាអ្វីដែលកើតឡើងដោយសារតែអន្តរកម្មជាមួយនឹងឧបសគ្គផ្សេងៗ"។ ICF(International Classification of Functioning, Disability and Health: ចំណាត់ថ្នាក់អន្តរជាតិនៃមុខងារនៃការរស់នៅ)បានកំណត់ថា មិនត្រូវមើលពិការភាពថាជារូបភាពអវិជ្ជមាននោះទេ ត្រូវចាត់ទុកថាជាបុគ្គលិកលក្ខណៈមួយរបស់មនុស្សជាតិ។



● ICF:ចំណាត់ថ្នាក់អន្តរជាតិនៃមុខងារនៃការរស់នៅ



2) ប្រភេទ ដើមហេតុនិងលក្ខណៈពិសេសនៃពិការភាព

[ពិការអវយវៈ]

ពិការអវយវៈ គឺសំដៅលើស្ថានភាពដែលទទួលរងនូវពិការភាពនៃដងខ្លួនឬអវយវៈ ដោយសារតែជំងឺ ឬគ្រោះថ្នាក់ ដែលធ្វើឲ្យមានការលំបាកនៅក្នុងការរស់នៅប្រចាំថ្ងៃ និងការរស់នៅក្នុងសង្គម។

វាបង្កឡើងដោយសារដូចជាការខូចខាតដៃជើងដោយសារតែជំងឺឬគ្រោះថ្នាក់ ការខូចខាតខួរក្បាលឬសរសៃប្រសាទខួរឆ្អឹងខ្នង ការប្រែប្រួលទ្រង់ទ្រាយនៃសន្លាក់ឬខួរឆ្អឹងខ្នងដោយសារតែជំងឺ ឬផលប៉ះពាល់បន្តមកទៀត និងការរួញនៃសាច់ដុំជាដើម។

ការលំបាកនៅក្នុងការរស់នៅគឺខុសគ្នាពីមនុស្សម្នាក់ៗ អាស្រ័យលើកម្រិត ឬផ្នែកនៃរាងកាយដែលពិការ។ ពេលខ្លះក៏មានកើតឡើងនូវពិការផ្នែកស្មារតីស្របពេលជាមួយគ្នានឹងពិការភាពមុខងារធ្វើចលនាផងដែរ។ ត្រូវប្រើប្រាស់ឧបករណ៍ជំនួយដែលសមស្របចំពោះអ្នកប្រើប្រាស់ដូចជា ឈើច្រត់ កៅអីរុញ ឬជើងសិប្បនិម្មិតជាដើម។



ការពន្យល់

ICF (International Classification of Functioning, Disability and Health:ចំណាត់ថ្នាក់អន្តរជាតិនៃមុខងារនៃការរស់នៅ)

ICF គឺជាការធ្វើចំណាត់ថ្នាក់មុខងារនៃការរស់នៅរបស់មនុស្ស ដើម្បីស្វែងយល់រូបភាពទាំងមូលនៃមនុស្សដែលជាកម្មវត្ថុ។ មុខងារនៃការរស់នៅរបស់មនុស្សគឺសំដៅលើ មុខងាររាងកាយនិងផ្លូវចិត្តនិងរចនាសម្ព័ន្ធរាងកាយ សមត្ថភាពឬមុខងារដើម្បីអនុវត្តការរស់នៅប្រចាំថ្ងៃដូចជាសកម្មភាពនិងការចូលរួម និងបរិស្ថានជាដើម។

[ពិការភ្នែក]

ពិការភ្នែក គឺសំដៅលើស្ថានភាពដែលមានពិការភាពខាងការមើលវត្ថុផ្សេងៗ ដូចជាសមត្ថភាពភ្នែកឬដែនគំហើញជាដើម ដែលធ្វើឲ្យមានការលំបាកនៅក្នុងការរស់នៅប្រចាំថ្ងៃ និងការរស់នៅក្នុងសង្គម។

ដើមហេតុ មានដូចជា ករណីពីកំណើត (តំណពូជ) និងជំងឺ គ្រោះថ្នាក់ ភាពចាស់ជរាជាដើម។ ករណីពិការភ្នែកដែលបណ្តាលមកពីជំងឺទឹកនោមផ្អែមមានការកើនឡើងច្រើន។

មនុស្សដែលពិការភ្នែកមានផ្សេងៗគ្នាជាច្រើន ដូចជាមនុស្សដែលមិនអាចមើលឃើញទាល់តែសោះ មនុស្សដែលដឹងពីពន្លឺ មនុស្សដែលអាចមើលក្នុងវិសាលភាពចង្អៀតជាដើម។

● បែបផែនដែលអាចមើលឃើញនៃពិការភ្នែក



មើលឃើញដុំខ្មៅនៅចំកណ្តាល/ការខូចខាតដែនគំហើញ

ដែនគំហើញចង្អៀត

ការមើលមិនឃើញមួយចំហៀង

[ពិការត្រចៀក]

ពិការត្រចៀក គឺសំដៅលើស្ថានភាពដែលទទួលរងនូវការខូចខាតនូវដំណើរការបញ្ជូនព័ត៌មានពីត្រចៀកទៅកាន់សរសៃប្រសាទសោតវិញ្ញាណ ដែលធ្វើឲ្យស្តាប់មិនលឺ ឬពិបាកក្នុងការស្តាប់។ គេធ្វើការបែងចែកទៅតាមកម្រិតនៃការស្តាប់លឺ ផ្នែកនៃរាងកាយដែលមានបញ្ហា និងពេលវេលាដែលចេញរោគសញ្ញា។

ត្រចៀកធ្ងន់ គឺសំដៅលើស្ថានភាពដែលពិបាកស្តាប់សំឡេង។ មធ្យោបាយក្នុងការប្រាស្រ័យទាក់ទង មានការប្រើប្រាស់ឧបករណ៍ជំនួយក្នុងការស្តាប់ ការធ្វើទំនាក់ទំនងដោយការសរសេរ ភាសាកាយវិការ ការអានមើលមាត់ (ការនិយាយស្ទាត់ៗ) ជាដើម។

ការធ្វើទំនាក់ទំនងដោយការសរសេរ

ភាសាកាយវិការ



ការអានមើលមាត់ (ការនិយាយស្ទាត់ៗ)



ឧបករណ៍ជំនួយក្នុងការស្តាប់

[ពិការផ្នែកភាសា]

- ពិការផ្នែកភាសា គឺសំដៅលើស្ថានភាពដែលទទួលរងនូវការខូចខាតសរីរាង្គទាក់ទងនឹងការបញ្ចេញសំឡេង និងសរសៃប្រសាទភាសានៃខួរធំ ដែលធ្វើឲ្យខូចដល់ការប្រាស្រ័យទាក់ទងដោយប្រើប្រាស់ភាសា។
- សំដៅលើស្ថានភាពដែលទទួលរងនូវការខូចខាតសរសៃប្រសាទភាសានៃខួរធំដែលកើតមានតាមក្រោយមិនមែនពីកំណើត ដែលធ្វើឲ្យមានការលំបាកក្នុងការ "ស្ដាប់" "និយាយ" "អាន" "សរសេរ"។
- មធ្យោបាយក្នុងការប្រាស្រ័យទាក់ទងគឺខុសគ្នាទៅតាមស្ថានភាពនៃពិការភាពដូចជាការប្រើប្រាស់ការសរសេរ ឬផ្ទាំងរូបភាពជាដើម។

● ស្ថានភាពអ្នកប្រើប្រាស់ដែលមានជំងឺនិយាយមិនរួច

ស្ថានភាពដែលគិតថាចង់និយាយ ប៉ុន្តែមិនអាចនិយាយជាប់គ្នាបាន

[ការចុះខ្សោយមុខងារនៃបេះដូង]

គឺជាស្ថានភាពដែលមានការលំបាកក្នុងការបញ្ជូនឈាមទៅកាន់រាងកាយទាំងមូល។

ក្នុងចំណោមអ្នកប្រើប្រាស់ដែលមានបញ្ហាជីពចរ ក៏មានអ្នកដែលដាក់ឧបករណ៍និយ័តបេះដូង (ភ្លោចបេះដូង) នៅក្នុងដើមទ្រូងផងដែរ។

ចំណុចសំខាន់នៃការមើលថែទាំ

- ជៀសវាងកុំធ្វើការហាត់ប្រាណដែលគោះទង្គិចខ្លាំងដល់ផ្នែកដែលបានដាក់នៅក្នុងដើមទ្រូង។

● ឧបករណ៍និយ័តបេះដូងសិប្បនិម្មិត



[ការចុះខ្សោយមុខងារនៃតម្រងនោម]

គឺជាស្ថានភាពដែលមានការលំបាកក្នុងការសម្អាតឈាម។

អ្នកប្រើប្រាស់ដែលចុះខ្សោយមុខងារតម្រងនោម ត្រូវសម្អាតឈាមដោយការច្រោះឈាមសិប្បនិម្មិត។

● ប្រព័ន្ធច្រោះឈាមសិប្បនិម្មិត



ចំណុចសំខាន់នៃការមើលថែទាំ

- ជៀសវាងកុំងូតទឹកនៅក្នុងថ្ងៃដែលធ្វើការច្រោះឈាម។
- កុំលើករបស់ធ្ងន់ដោយដៃដែលបានភ្ជាប់ដើម្បីធ្វើការច្រោះឈាម។
- ដាក់កម្រិតលើជាតិប្រៃនិងជាតិទឹក។

[ការចុះខ្សោយមុខងារនៃសរីរាង្គដង្ហើម]

គឺជាស្ថានភាពដែលពិបាកដកដង្ហើម។

អ្នកប្រើប្រាស់ដែលមិនអាចធ្វើការដកដង្ហើមបានគ្រប់គ្រាន់ ត្រូវទទួលការព្យាបាលដោយអុកស៊ីសែន។

● ឧបករណ៍ដកដង្ហើមស្រូបអុកស៊ីសែនចល័ត

● ឧបករណ៍ចម្រាញ់អុកស៊ីសែន



ចំណុចសំខាន់នៃការមើលថែទាំ

- នៅពេលប្រើប្រាស់ឧបករណ៍ចម្រាញ់អុកស៊ីសែន ត្រូវជៀសវាងកុំឲ្យមានអណ្តាតភ្លើង។
- ការបង្ការជំងឺឆ្លង គឺមានសារៈសំខាន់ណាស់។
- ត្រូវត្រៀមថ្មបម្រុងទុក ដើម្បីប្រើប្រាស់នៅពេលដាច់ភ្លើង។

[ការចុះខ្សោយមុខងារនៃប្លោកនោមនិងចុងពោះវៀនធំ]

គឺជាស្ថានភាពដែលមិនអាចនោមឬបញ្ចេញលាមក ដោយសារតែជំងឺប្លោកនោម ឬចុងពោះវៀនធំ។

ត្រូវធ្វើរន្ធមាត់ (កន្លែងបើក) ដើម្បីយកលាមកចេញ ដោយធ្វើការវះកាត់នៅត្រង់ផ្នែកពោះ។

មានប្លោកនោមសិប្បនិម្មិតនិងទ្វារធំសិប្បនិម្មិត។ ទីតាំងរបស់វា ខុសគ្នាទៅតាមប្រភេទជំងឺ។

● ប្លោកនោមសិប្បនិម្មិត



● ទ្វារធំសិប្បនិម្មិត



ចំណុចសំខាន់នៃការមើលថែទាំ

- អ្នកមើលថែទាំ ត្រូវចាត់ចែងលាមកនៅក្នុងថង់ (ស្បោង) ដែលគ្របនៅកន្លែងបើក។
- ប្រសិនបើនៅជុំវិញកន្លែងបើកឡើងរលាកក្រហម ត្រូវរាយការណ៍ទៅកាន់អ្នកជំនាញផ្នែកព្យាបាល។

[ពិការផ្នែកសតិបញ្ញា]

ពិការផ្នែកសតិបញ្ញា គឺសំដៅលើមនុស្សដែលមានការអភិវឌ្ឍផ្នែកសតិបញ្ញាមានលក្ខណៈយឺតជាទូទៅ។ នៅពេលដែលមានឧបសគ្គនៅក្នុងការរស់នៅប្រចាថ្ងៃ ចាំបាច់ត្រូវមានជំនួយពិសេសណាមួយ។

ចំណុចសំខាន់នៃការមើលថែទាំ

- ត្រូវធ្វើការថែទាំទៅតាមដំណាក់កាលនៃជីវិត។
- ត្រូវដឹងពីស្ថានភាពរបស់អ្នកប្រើប្រាស់ ហើយធ្វើការមើលថែទាំដែលសមស្របចំពោះអ្នកប្រើប្រាស់។

[ពិការផ្នែកស្មារតី]

ពិការផ្នែកស្មារតី គឺសំដៅលើស្ថានភាពដែលកើតមាននូវពិការភាពនៃមុខងារស្មារតីដោយសារតែជំងឺផ្នែកស្មារតី ដែលធ្វើឲ្យមានការលំបាកក្នុងការរស់នៅប្រចាំថ្ងៃ និងការចូលរួមក្នុងសង្គម។ នៅពេលដែលជំងឺមានលក្ខណៈធ្ងន់ធ្ងរ វាអាចធ្វើឲ្យមានការចុះខ្សោយគួរឲ្យកត់សម្គាល់នៅក្នុងការគ្រប់គ្រងចលនានិងសមត្ថភាពក្នុងការវិនិច្ឆ័យ។ នៅក្នុងជំងឺផ្នែកស្មារតី មានជំងឺវិកលចរិត និងជំងឺថប់អារម្មណ៍ (mood disorder)។

រោគសញ្ញានៃមនុស្សដែលពិការផ្នែកស្មារតី មានការមមើមមាយ ការរវើរវាយ និងការបាក់ទឹកចិត្តជាដើម។

● រោគសញ្ញានៃពិការផ្នែកស្មារតី

● ការរវើរវាយ

កើតមានការមមើមមាយ
និងការរវើរវាយ។

● ការបាក់ទឹកចិត្ត

គឺជាស្ថានភាពដែលផ្លូវចិត្តធ្លាក់ចុះ
លែងសូវនិយាយស្តី
និងមានការខូចចិត្ត។

● អារម្មណ៍ជ្រួលអរខ្លាំង

គឺជាស្ថានភាពដែលអារម្មណ៍ពុះកញ្ជ្រោលឡើងខ្ពស់ខុសពីធម្មតា
ហើយមានលក្ខណៈបើកទូលាយ។

3 ការស្វែងយល់ជាមូលដ្ឋានអំពីជំងឺភ្លេចភ្លាំង

1) ការស្វែងយល់អំពីជំងឺភ្លេចភ្លាំង

ខួរក្បាល គឺជាផ្នែកនៃរាងកាយដែលធ្វើការគ្រប់គ្រងសកម្មភាពរបស់មនុស្ស។ ជំងឺភ្លេចភ្លាំង គឺសំដៅលើជំងឺដែលមុខងារនៃការស្គាល់របស់ខួរក្បាលបានចុះខ្សោយដោយសារតែដើមហេតុណាមួយ ដែលធ្វើឲ្យកើតមានឧបសគ្គក្នុងការរស់នៅប្រចាំថ្ងៃ និងការរស់នៅក្នុងសង្គម។

មុខងាររបស់ខួរក្បាល

ចាំបាច់ត្រូវដឹងពីមុខងាររបស់ខួរក្បាល ដើម្បីស្វែងយល់ពីជំងឺភ្លេចភ្លាំង។ នៅពេលដែលមុខងាររបស់ខួរក្បាលចុះខ្សោយ ធ្វើឲ្យកើតមានឧបសគ្គក្នុងការរស់នៅ។

● មុខងារ និងកំពកទាំង4 របស់ខួរធំ



និយមន័យនៃជំងឺភ្លេចភ្លាំង

● មុខងារនៃការស្គាល់គឺជា

ការចងចាំ
(ចាំ និងនឹកឃើញ)



ភាសា
(និយាយ និងស្វែងយល់)

អំពើ
(ការប្រព្រឹត្តនៅក្នុងជីវភាពប្រចាំថ្ងៃ)

ការស្គាល់
(ការស្គាល់វត្ថុ)

រៀបចំគម្រោង
និងដាក់តាមលំដាប់លំដោយជាដើម

ភាពខុសគ្នានៃការភ្លេចភ្លាំង និងជំងឺភ្លេចភ្លាំង

នៅក្នុងរោគសញ្ញាចំបងនៃជំងឺភ្លេចភ្លាំង មានការភ្លេចភ្លាំង។ ការភ្លេចភ្លាំង គឺជារោគសញ្ញាដែលអាចមើលឃើញនៅពេលកើនអាយុ ប៉ុន្តែ វាខុសពីការភ្លេចភ្លាំងនៃជំងឺភ្លេចភ្លាំង។

● ភាពខុសគ្នានៃការភ្លេចភ្លាំង

ការភ្លេចភ្លាំងទៅតាមការកើនអាយុ	ការភ្លេចភ្លាំងនៃជំងឺភ្លេចភ្លាំង
ភ្លេចបទពិសោធន៍មួយផ្នែក	ភ្លេចបទពិសោធន៍ទាំងអស់
មិនវិវឌ្ឍនទៅមុខ	វិវឌ្ឍនទៅមុខ
ដឹងខ្លួនថាមានការភ្លេចភ្លាំង	មិនដឹងខ្លួនថាមានការភ្លេចភ្លាំងទេ
គ្មានឧបសគ្គនៅក្នុងការរស់នៅទេ	មានឧបសគ្គនៅក្នុងការរស់នៅ

2) ចំណុចសំខាន់ៗនៅក្នុងការមើលថែជំងឺភ្លេចភ្លាំង

នៅពេលមើលថៃទាំអ្នកដែលមានជំងឺភ្លេចភ្លាំង

① គិតដោយឈរលើជំហររបស់អ្នកប្រើប្រាស់

ចាំបាច់ត្រូវធ្វើការមើលថែទាំដោយផ្តោតលើអ្នកប្រើប្រាស់ជាចម្បង។

② ស្វែងយល់ពីការរស់នៅរបស់អ្នកប្រើប្រាស់

ចាំបាច់ត្រូវជួយឲ្យអ្នកប្រើប្រាស់ឲ្យរស់នៅដោយមានស្ថេរភាព។

③ ធ្វើការជួយដោយមើលពីអ្វីដែលអ្នកប្រើប្រាស់អាចធ្វើបាន

ធ្វើការជួយដោយធ្វើឲ្យអ្នកប្រើប្រាស់បញ្ចេញនូវចំណង់និងសមត្ថភាពរបស់ខ្លួន។

3) រោគសញ្ញានិងជំងឺដែលជាមូលហេតុបង្កសំខាន់ៗជាដើមនៃជំងឺភ្លេចភ្លាំង

ជំងឺដែលជាដើមហេតុនៃជំងឺភ្លេចភ្លាំងមានដូចជា ①ជំងឺភ្លេចភ្លាំងដោយសារជំងឺអាល់ហ្សាយម័រ (Alzheimer's Disease) ②ជំងឺភ្លេចភ្លាំងដោយសារបញ្ហាសរសៃឈាមក្នុងខួរក្បាល ③ជំងឺភ្លេចភ្លាំងដោយសារជាតិប្រូតេអ៊ីនមិនធម្មតាហៅថា Lewy Bodies ④ ជំងឺភ្លេចភ្លាំងដោយសារកំពកថ្ងាសនិងកំពកសៀតផ្កា។

● រោគសញ្ញានិងជំងឺដែលជាមូលហេតុបង្កសំខាន់ៗជាដើមនៃជំងឺភ្លេចភ្លាំង

ប្រភេទ	ស្ថានភាពនៃខួរក្បាល	រោគសញ្ញាសំខាន់ៗជាដើម
①ជំងឺភ្លេចភ្លាំងដោយសារជំងឺអាល់ហ្សាយម័រ (Alzheimer's Disease) 	ខួរក្បាលរួញតូច។ មានលេចចេញនូវបន្ទះប្រូតេអ៊ីនអាមីឡូអ៊ីដ(Amyloid plaques)	•ការចេញរោគសញ្ញា និងការវិវឌ្ឍនគឺសន្សឹមៗ។ •ចាប់ផ្ដើមដោយពិការការចងចាំ។ •ភាគច្រើនមានអារម្មណ៍ល្អ។ •មានថ្នាំពន្យារការវិវឌ្ឍននៃជំងឺ។
②ជំងឺភ្លេចភ្លាំងដោយសារបញ្ហាសរសៃឈាមក្នុងខួរក្បាល 	សរសៃឈាមស្ទះ ហើយស្លាប់កោសិកាខួរក្បាលមួយផ្នែកដោយសារតែជំងឺសរសៃឈាមខួរក្បាល។	•វិវឌ្ឍនជាដំណាក់កាល។ •ពិការមួយចំហៀងខ្លួន និងពិការផ្នែកភាសាជាដើម។ •មានរឿងដែលអាចធ្វើបាននិងរឿងដែលមិនអាចធ្វើបាន។
③ជំងឺភ្លេចភ្លាំងដោយសារជាតិប្រូតេអ៊ីនមិនធម្មតាហៅថា Lewy Bodies 	មានលេចចេញប្រូតេអ៊ីន lewy ដែលកំពកពយរួញតូច	•មើលឃើញរបស់ដែលមិនអាចមើលឃើញ (មមើមមាយ)។ •ដើរខ្ញើកៗជាដើម (រោគសញ្ញាជំងឺផាកគីនសុន)។ •បញ្ចេញសំឡេងតាមការយល់សប្តិជាដើម (ពិការចលនាគេង)។
④ជំងឺភ្លេចភ្លាំងដោយសារកំពកថ្ងាសនិងកំពកសៀតផ្កា 	កំពកថ្ងាសនិងកំពកសៀតផ្កានៃខួរធំរួញតូច។	•សមត្ថភាពគិតដោយប្រើហេតុផលនិងគ្រប់គ្រងខ្លួនឯងគឺមិនដំណើរការ។ •ការប្រែប្រួលបុគ្គលិកលក្ខណៈ។ •ការធ្វើចលនាទៅតាមគំរូដែលបានកំណត់។ •ការរំភើប និងការគឃ្លើន។

4) រោគសញ្ញានៃជំងឺភ្លេចភ្លាំង

រោគសញ្ញានៃជំងឺភ្លេចភ្លាំង អាចបែងចែកដូចខាងក្រោម។

រោគសញ្ញាស្នូលៈ កើតមានឡើងដោយសារតែពិការភាពនៃខួរក្បាល។

ពិការការចងចាំ ការវង្វេងស្មារតី ពិការមុខងារប្រតិបត្តិ ពិការការស្វែងយល់និងសមត្ថភាពវិនិច្ឆ័យជាដើម។

រោគសញ្ញាសកម្មភាពនិងផ្លូវចិត្ត (BPSD):កើតឡើងដោយសារតែបរិស្ថាន បុគ្គលិកលក្ខណៈ និងអត្តចរិតនៃអ្នកប្រើប្រាស់ និងទំនាក់ទំនងអន្តរបុគ្គលជាដើម។

ការមិនស្ងប់ក្នុងចិត្តនិងការអន្ទះអន្ទែង ការមើលមាយនិងការវង្វេងវង្វាយ ការធ្វើសកម្មភាពដោយការរំភើបនិងការគឃ្លើន ការដើរចរច្រប់ជាដើម។

● រោគសញ្ញាស្នូល និងរោគសញ្ញាផ្លូវចិត្តនិងសកម្មភាពនៃជំងឺភ្លេចភ្លាំង



រោគសញ្ញាសកម្មភាពនិងផ្លូវចិត្តអាចហៅម្យ៉ាងទៀតបានថារោគសញ្ញាបរិមណ្ឌល។

[រោគសញ្ញាស្នូល]

① ពិការការចងចាំ

ពិការការចងចាំ គឺជាពិការភាពមួយដែលមិនអាចចងចាំនូវព្រឹត្តិការណ៍ឬព័ត៌មានដែលថ្មីៗ គឺជារោគសញ្ញាចម្បងនៃជំងឺភ្លេចភ្លាំង។

② ការវង្វេងស្មារតី

ការវង្វេងស្មារតី គឺជាពិការភាពមួយដែលមិនអាចស្គាល់ពេលវេលា ទីកន្លែង និងមនុស្សជាដើម។

- ក្រោកឡើងនៅពេលយប់ជ្រៅ ហើយព្យាយាមចេញទៅខាងក្រៅ។
- គិតថាអ្នកផ្ទះខ្លួនឯងថាជាអ្នកដទៃ។

③ ពិការមុខងារប្រតិបត្តិ

ពិការមុខងារប្រតិបត្តិ គឺជាពិការភាពមួយដែលលែងដឹងពីលំដាប់លំដោយ និងលែងចេះធ្វើសកម្មភាព។

- លែងដឹងពីលំដាប់លំដោយនៃការធ្វើម្ហូប។

④ ពិការភាពនៃការស្វែងយល់និងសមត្ថភាពវិនិច្ឆ័យ

- មិនអាចធ្វើការវិនិច្ឆ័យលើរឿងរ៉ាវផ្សេងៗ ដោយសារតែការចុះខ្សោយការស្វែងយល់និងសមត្ថភាពវិនិច្ឆ័យ។
- ក្លាយទៅជាពិបាកក្នុងការគិតលុយ។

[រោគសញ្ញាសកម្មភាពនិងផ្លូវចិត្ត (BPSD)]

⦿ រោគសញ្ញាសកម្មភាព

① ការធ្វើសកម្មភាពដោយការរំភើបនិងការគឃ្លើន

ការធ្វើសកម្មភាពដោយការរំភើបនិងការគឃ្លើន គឺជាការធ្វើសកម្មភាពដែលកើតឡើងពីអារម្មណ៍មិនស្ងប់ក្នុងចិត្តដែលមិនអាចស្វែងយល់ថាត្រូវធ្វើអ្វី។ ការដែលមិនអាចរៀបរាប់ដោយរលូនពីការឈឺចាប់ ចំណង់បន្ទោបង់ ចំណង់នោមជាដើម ត្រូវបានគេគិតថាទាក់ទងទៅនឹងសកម្មភាពដែលគឃ្លើនផងដែរ។

② ការដើរចរច្រប់

ការដើរចរច្រប់ គឺសំដៅលើសកម្មភាពដែលដើរទៅដើរមក ដោយសារតែមានគោលដៅណាមួយ ឬដោយសារតែមានមូលហេតុដែលមិនអាចនៅស្ងៀម។

◉ រោគសញ្ញាផ្លូវចិត្ត

មនុស្សដែលមានជំងឺភ្លេចភ្លាំង គឺមានការមិនស្ងប់ និងការច្របូកច្របល់ក្នុងចិត្ត។

① ការមមើមមាយ

ការមមើមមាយ គឺសំដៅលើអារម្មណ៍ដែលគិតថាមានចំពោះរបស់ដែលគ្មាននៅក្នុងភាពជាក់ស្តែង។

② ការរវើរវាយ

ការរវើរវាយ គឺសំដៅលើអារម្មណ៍ដែលគិតថាមានចំពោះរឿងរ៉ាវដែលគ្មានពិតប្រាកដ។

◉ ចំណុចដែលត្រូវប្រុងប្រយ័ត្នក្នុងការមើលថែទាំមនុស្សដែលមានជំងឺភ្លេចភ្លាំង។

- ទទួលយកពាក្យសម្ដី និងកាយវិការ ដោយមិនធ្វើការបដិសេធ។
- ព្យាយាមស្ដាប់ការនិយាយដោយហ្មត់ចត់ ហើយផ្ដល់នូវអារម្មណ៍ស្ងប់ចិត្ត។
- រៀបរាប់ដោយពាក្យខ្លីៗហើយងាយយល់ ឲ្យឆ្លើយតបទៅនឹងសមត្ថភាពនៃការយល់ដឹងរបស់គាត់។
- រៀបចំចង្វាក់នៃការរស់នៅចាប់តាំងពីការក្រោកពីព្រលឹម រហូតដល់ចូលគេងវិញ។
- ធ្វើការគិត និងធ្វើសកម្មភាពជាមួយគ្នាដើម្បីបំបាត់នូវការមិនស្ងប់ក្នុងចិត្ត។
- រៀបចំបរិស្ថាននៅក្នុងបន្ទប់និងជុំវិញ កុំឲ្យមានការផ្លាស់ប្ដូរដោយងាយៗ។



PART 3

បច្ចេកទេសក្នុងការប្រាស្រ័យទាក់ទង

CHAPTER 1 មូលដ្ឋាននៃការប្រាស្រ័យទាក់ទង

CHAPTER 2 ការប្រាស្រ័យទាក់ទងជាមួយអ្នកប្រើប្រាស់

CHAPTER 3 ការប្រាស្រ័យទាក់ទងជាមួយក្រុមការងារ

CHAPTER

1 មូលដ្ឋាននៃការប្រាស្រ័យទាក់ទង

1 អត្ថន័យនៃការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទង គឺជាការរៀបរាប់ និងការចែករំលែកទៅវិញទៅមក នូវអារម្មណ៍ ឬការគិតជាដើម។

ចាំបាច់ត្រូវរៀនឲ្យចេះពីបច្ចេកទេសក្នុងការប្រាស្រ័យទាក់ទង ដែលជាមធ្យោបាយក្នុងការបង្កើតទំនាក់ទំនងនិងការទុកចិត្តជាមួយដៃគូ។

● រូបភាពនៃការប្រាស្រ័យទាក់ទង

2 មធ្យោបាយក្នុងការបញ្ជូនព័ត៌មាន

មធ្យោបាយក្នុងការបញ្ជូនព័ត៌មាន មានការប្រាស្រ័យទាក់ទងជាភាសាដោយធ្វើការប្រើប្រាស់ភាសា និងការប្រាស្រ័យទាក់ទងដោយមិនប្រើភាសាដោយប្រើប្រាស់នូវរបស់ផ្សេងពីភាសាដូចជាទឹកមុខ ឬកាយវិការជាដើម។

1) ការប្រាស្រ័យទាក់ទងជាភាសា

ការប្រាស្រ័យទាក់ទងជាភាសា មានការសន្ទនាដោយការបញ្ចេញសំឡេងនៃភាសា ឬភាសាកាយវិការ និងការបញ្ជូនព័ត៌មានតាមរយៈអក្សរ។

● ឧទាហរណ៍នៃការប្រាស្រ័យទាក់ទងជាភាសា



ការបញ្ចេញសំឡេងនៃភាសា | ភាសាកាយវិការ | អក្សរ

2) ការប្រាស្រ័យទាក់ទងដោយមិនប្រើភាសា

មធ្យោបាយក្នុងការប្រាស្រ័យទាក់ទងក្រៅពីភាសា មានទឹកមុខនិងកាយវិការដូចជាកាយវិការរាងកាយនិងកាយវិការដៃជាដើម។



3 បច្ចេកទេសក្នុងការប្រាស្រ័យទាក់ទង

ដើម្បីកសាងទំនាក់ទំនង ត្រូវធ្វើការប្រាស្រ័យទាក់ទងដោយយកចិត្តទុកដាក់ចំពោះរឿងរ៉ាវខាងក្រោម ។

● ការស្តាប់ដោយប្រុងប្រយ័ត្ន



- ការស្តាប់ដោយប្រុងប្រយ័ត្ន គឺជាការស្តាប់ការនិយាយដោយត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ក្នុងឥរិយាបថស្តាប់ការនិយាយដោយយកចិត្តទុកដាក់។

● ការយល់ចិត្ត



- ការយល់ចិត្ត ជាការមានអារម្មណ៍ថាគំនិត ឬអារម្មណ៍របស់ដៃគូ គឺដូចនឹងអារម្មណ៍របស់ខ្លួនដែរ។
- ការស្វែងយល់ដោយឈរលើគោលជំហររបស់ដៃគូ គឺជារឿងសំខាន់។

● ការទទួលយក

- ការទទួលយក គឺជាការទទួលយោបល់ឬអារម្មណ៍របស់ដៃគូ ដោយមិនបដិសេធឬយល់ស្រប។

CHAPTER

2 ការប្រាស្រ័យទាក់ទងជាមួយអ្នកប្រើប្រាស់

1 បច្ចេកទេសក្នុងការស្តាប់ការនិយាយ (បច្ចេកទេសនៃការស្តាប់ដោយសកម្ម)

អ្នកមើលថែទាំ ត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកប្រើប្រាស់និងគ្រួសារអ្នកប្រើប្រាស់ព្រមទាំងអ្នកជំនាញផ្សេងទៀត ដើម្បីជួយដល់ការរស់នៅរបស់អ្នកប្រើប្រាស់ឲ្យកាន់តែប្រសើរឡើង។

1) ការគោរពគុណតម្លៃរបស់អ្នកប្រើប្រាស់

អ្នកប្រើប្រាស់ មានគុណតម្លៃខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ដោយសារសម័យកាលដែលបានកើតនិងធំដឹងក្តី និងបរិស្ថានដែលបានរស់នៅកន្លងមកជាដើម។
អ្នកមើលថែទាំ ត្រូវផ្តល់ការមើលថែទាំដោយគោរពគុណតម្លៃ ការគិតនិងការយល់ឃើញនិងអារម្មណ៍របស់អ្នកប្រើប្រាស់។

2) ចំណុចដែលត្រូវប្រុងប្រយ័ត្នក្នុងការប្រាស្រ័យទាក់ទងជាភាសា

[របៀបនិយាយ]

អ្នកមើលថែទាំ ត្រូវចងចាំក្នុងចិត្តពីរបៀបនិយាយដែលគួរសម។



[បច្ចេកទេសក្នុងការសួរសំណួរ]

អ្នកមើលថែទាំ ត្រូវចងចាំក្នុងចិត្តពីការប្រាស្រ័យទាក់ទងទៅវិញទៅមកជាមួយនឹងអ្នកប្រើប្រាស់ ដោយមិនមែនគ្រាន់តែធ្វើការសួរទៅកាន់អ្នកប្រើប្រាស់តែម្ខាងពីអ្វីដែលខ្លួនចង់ដឹងនោះទេ។

សំណួរមាន ①សំណួរបិទ ②សំណួរបើក។

① សំណួរបិទ

សំណួរបិទ គឺជាសំណួរដែលដៃគូអាចឆ្លើយដោយងាយស្រួលត្រឹមតែមួយមាត់ឬពីរមាត់ ដូចជា"បាទចាស់" ឬ "ទេ" "A" ឬ "B"ជាដើម។ ប្រសិនបើបន្តសួរតែសំណួរបិទ វានឹងក្លាយទៅជាការប្រាស្រ័យទាក់ទងដែលមានលក្ខណៈតែម្ខាង។

② សំណួរបើក

សំណួរបើក គឺជាសំណួរដែលដៃគូអាចឆ្លើយដោយសេរី ដូចជា "តើអ្នកគិតដូចម្តេច?" "តើអ្នកចង់ធ្វើយ៉ាងណា?"។ ប៉ុន្តែ ប្រសិនបើបន្តសួរតែសំណួរបើកដែលសួររកហេតុផលថា "ហេតុអ្វី"នឹងអាចកើតមានករណីដែលធ្វើឲ្យដៃគូមានអារម្មណ៍ថាត្រូវបានគេស្តីបន្ទោស ដូច្នេះចាំបាច់ត្រូវប្រុងប្រយ័ត្ន។

● ឧទាហរណ៍នៃសំណួរ



[ការថាឡើងវិញ]

អ្នកមើលថែទាំអាចផ្ញើសារថា "ខ្ញុំកំពុងស្តាប់អ្នកនិយាយ" ដោយធ្វើការថាឡើងវិញនូវពាក្យសម្តីដែលអ្នកប្រើប្រាស់បាននិយាយ។

● ឧទាហរណ៍នៃការថាឡើងវិញ

3) ចំណុចដែលត្រូវប្រុងប្រយ័ត្នក្នុងការប្រាស្រ័យទាក់ទងដោយមិនប្រើភាសា

[កាយវិការនិងទឹកមុខ]

អ្នកមើលថែទាំ ត្រូវធ្វើការសង្កេតមើលកាយវិការនិងទឹកមុខរបស់អ្នកប្រើប្រាស់ ហើយត្រូវប្រាស្រ័យទាក់ទងឲ្យស្របទៅតាមនោះ។

[ខ្សែភ្នែក]

អ្នកមើលថែទាំ ត្រូវធ្វើទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ដោយមើលឲ្យត្រូវខ្សែភ្នែករបស់គាត់។ ប្រសិនបើខ្សែភ្នែកមិនត្រូវគ្នាជាមួយនឹងអ្នកប្រើប្រាស់ទេ វាពិបាកនឹងបង្ហាញថាកំពុងស្តាប់ការនិយាយណាស់។

● របៀបមើលឲ្យត្រូវខ្សែភ្នែក



មើលឲ្យត្រូវខ្សែភ្នែក

ប្រសិនបើអ្នកមើលថែទាំមើលអ្នកប្រើប្រាស់ពីលើចុះក្រោម នឹងធ្វើឲ្យមានអារម្មណ៍ភ័យខ្លាច។

[ការបញ្ចេញសំឡេង]

និយាយដោយបញ្ចេញសំឡេងយឺតៗ ដោយល្បឿនល្មម និងស្រាលៗ។

[ការងក់ក្បាលនិងការឆ្លើយតប]

ការងក់ក្បាលដោយងក់កចុះឡើង និងការឆ្លើយតបចំពោះការនិយាយរបស់អ្នកប្រើប្រាស់ដូចជា "ពិតមែនឬ" គឺបង្ហាញពីឥរិយាបថនៃការព្យាយាមស្វែងយល់និងស្តាប់ការនិយាយរបស់អ្នកប្រើប្រាស់។

[ឥរិយាបថ កាយវិកាយខ្លួននិងកាយវិការដៃ]

អ្នកមើលថែទាំ ត្រូវប្រាស្រ័យទាក់ទងដោយបែរមុខចំទៅអ្នកប្រើប្រាស់។

- នៅពេលស្តាប់គេនិយាយ ការអោបដៃ និងគងជើង និងផ្អែកខ្នងទៅក្រោយ គឺផ្តល់នូវចំណាប់អារម្មណ៍មិនល្អទៅកាន់ដៃគូ។
- អត្ថន័យនៃកាយវិការខ្លួននិងកាយវិការដៃ មានភាពខុសគ្នាខ្លាំងទៅតាមប្រទេសនិងវប្បធម៌។

ចំណុចត្រូវប្រុងប្រយ័ត្នចំពោះឥរិយាបថ



និយាយដោយបែរមុខចំ។



អោបដៃ។

គងជើង។



ផ្អែកខ្នងទៅក្រោយ។

[ចម្ងាយ និងការប៉ះរាងកាយ]

អាស្រ័យតាមប្រទេសនិមួយៗ ការនិយាយនៅក្នុងចម្ងាយជិត និងការប៉ះរាងកាយ ក៏អាចបង្ហាញពីភាពជិតស្និទ្ធផងដែរ។

នៅប្រទេសជប៉ុន គេនិយាយថាមនុស្សភាគច្រើនមានអារម្មណ៍ល្អ ប្រសិនបើរក្សាចម្ងាយក្នុងកម្រិតមួយ ទោះបីជាមានទំនាក់ទំនងជិតស្និទ្ធក៏ដោយ។

ការប៉ះពាល់រាងកាយរបស់ដៃគូ នឹងផ្តល់នូវខ្លឹមសារខុសៗគ្នាទៅដៃគូអាស្រ័យលើពេលវេលាដែលប៉ះ កម្រិតតិចឬខ្លាំង និងភាពញឹកញាប់។

ឧទាហរណ៍នៃការប៉ះពាល់រាងកាយ



ការប្រាស្រ័យទាក់ទងដោយកាន់ដៃថ្នមៗ។

2 ការពន្យល់ និងការយល់ព្រម (ការព្រមព្រៀងដែលបានជូនដំណឹង)

អ្នកមើលថែទាំ ជួយដល់ការសម្រេចចិត្តរបស់អ្នកប្រើប្រាស់ ដើម្បីឲ្យអ្នកប្រើប្រាស់រស់នៅតាមបែបរបស់ពួកគាត់។ អ្នកមើលថែទាំ ត្រូវប្រុងប្រយ័ត្ននូវចំណុចដូចខាងក្រោម នៅពេលពេលជួយដល់ការសម្រេចចិត្តរបស់អ្នកប្រើប្រាស់។

① បង្ហាញជម្រើស។
② ពន្យល់ឲ្យបានក្បោះក្បាយនូវគុណប្រយោជន៍និងគុណវិបត្តិនៃជម្រើសនិមួយៗ។
③ ត្រូវឲ្យអ្នកប្រើប្រាស់ធ្វើការជ្រើសរើស និងសម្រេចចិត្តដោយឆន្ទៈរបស់ខ្លួនឯង។

អ្នកមើលថែទាំត្រូវគោរពនូវការជ្រើសរើសនិងផ្តល់ជំនួយធ្វើយ៉ាងណាឲ្យអ្នកប្រើប្រាស់អាចធ្វើបាននូវអ្វីដែលខ្លួនបានជ្រើសរើសនោះ។

3 ការប្រាស្រ័យទាក់ទងទៅតាមស្ថានភាពរបស់អ្នកប្រើប្រាស់

អ្នកប្រើប្រាស់ មានករណីខ្លះពិបាកក្នុងការប្រាស្រ័យទាក់ទងជាមួយដោយសារតែជំងឺ ឬពិការភាព។ អ្នកមើលថែទាំ ចាំបាច់ត្រូវជ្រើសរើសមធ្យោបាយនៃការប្រាស្រ័យទាក់ទងដែលសមស្រប ទៅតាមជំងឺ ឬពិការភាពរបស់អ្នកប្រើប្រាស់។

1) ចំណុចសំខាន់ៗនៃការប្រាស្រ័យទាក់ទងទៅតាមលក្ខណៈពិសេសនៃពិការភាពផ្សេងៗ

ពេលខ្លះអាចកើតមានឧបសគ្គក្នុងការប្រាស្រ័យទាក់ទង ដោយសារតែជំងឺ ឬពិការភាព។ អ្នកមើលថែទាំ ត្រូវប្រាស្រ័យទាក់ទងជាមួយអ្នកប្រើប្រាស់ ដោយក្តាប់ឲ្យបានថាតើអ្នកប្រើប្រាស់មានឧបសគ្គបែបណានៅក្នុងការប្រាស្រ័យទាក់ទង។

ថ្មីៗនេះ ការប្រើប្រាស់ ICT (បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន) ធ្វើជាមធ្យោបាយនៃការប្រាស្រ័យទាក់ទង កំពុងមានការរីកចម្រើន។

2) ការប្រាស្រ័យទាក់ទងជាមួយមនុស្សពិការភ្នែក

1. លក្ខណៈពិសេសនៃការប្រាស្រ័យទាក់ទងជាមួយមនុស្សពិការភ្នែក

ពិការភ្នែក គឺជាការពិការដែលភ្នែកមើលមិនឃើញ ឬភ្នែកពិបាកមើលជាដើម។ ដោយសារតែមិនអាចទទួលព័ត៌មានបានគ្រប់គ្រាន់តាមរយៈចក្ខុវិញ្ញាណ ដូច្នេះហើយគាត់អាចនឹងមិនដឹងពីចម្ងាយ ឬទីតាំងនៃវត្ថុនោះទេ។

2. ចំណុចដែលត្រូវប្រុងប្រយ័ត្ននៅពេលប្រាស្រ័យទាក់ទងជាមួយមនុស្សពិការភ្នែក

⊙ ប្រើប្រាស់ព័ត៌មានក្រៅពីចក្ខុវិញ្ញាណ

ពន្យល់ឲ្យបានជាក់លាក់និងច្បាស់លាស់ដោយពាក្យពេចន៍នូវទីតាំង ឬលក្ខណៈនៃវត្ថុជាដើម។ ម៉្យាងវិញទៀត ការយកចិត្តទុកដាក់អំពីរបៀបនិយាយ និងការបញ្ចេញសំឡេង ជាដើមគឺមានសារៈសំខាន់ណាស់។

ការឲ្យស្ទាបដោយផ្ទាល់ ក៏អាចបញ្ជូនព័ត៌មានបានផងដែរ។

⊙ ការនិយាយទៅកាន់ដោយការហៅឈ្មោះ

ដោយសារតែការប៉ះរាងកាយរបស់អ្នកប្រើប្រាស់ដោយមិននិយាយអ្វីទាល់តែសោះ អាចនឹងធ្វើឲ្យមានការភ្ញាក់ផ្អើល ដូច្នេះហើយដំបូងចាំបាច់ត្រូវធ្វើការនិយាយទៅកាន់គាត់ជាមុនសិន។ នៅពេលនិយាយទៅកាន់អ្នកប្រើប្រាស់ ត្រូវនិយាយបន្ទាប់ពីហៅឈ្មោះរបស់អ្នកប្រើប្រាស់រួច។

ម៉្យាងវិញទៀត អ្នកមើលថែទាំ ចាំបាច់ត្រូវតែប្រាប់ឈ្មោះរបស់ខ្លួនផងដែរ។

● ហៅឈ្មោះរួចនិយាយទៅកាន់គាត់



◉ ចំពោះទីកន្លែងនិងទិសដៅ ត្រូវពន្យល់ឲ្យបានជាក់លាក់

នៅពេលពន្យល់ពីទីកន្លែង ត្រូវប្រាប់ឲ្យបានជាក់លាក់ដូចជា "នៅខាងស្តាំដៃរបស់អ្នក" "នៅខាងសំឡេងរបស់ខ្ញុំ"ជាដើម។ នៅក្នុងករណីប្រាប់ពីទីតាំងនៃអាហារ នៅពេលបរិភោគអាហារ មានវិធីសាស្ត្រដែលគេហៅថា ទីតាំងទ្រនិចនាឡិកា ដែលពន្យល់ទីតាំងដោយធៀបនឹងមុខនាឡិកា។

3. ឧទាហរណ៍នៃមធ្យោបាយនិងឧបករណ៍ជំនួយក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សពិការភ្នែក

ការប្រាស្រ័យទាក់ទងនឹងមានភាពងាយស្រួលដោយការប្រើប្រាស់ឧបករណ៍ជំនួយដែលត្រូវទៅតាមស្ថានភាពនៃអ្នកប្រើប្រាស់ដែលពិការភ្នែក។

(អក្សរសម្រាប់មនុស្សពិការភ្នែក)

ឧបករណ៍ផ្តល់ព័ត៌មានដល់មនុស្សដែលភ្នែកមើលមិនឃើញ មានអក្សរសម្រាប់មនុស្សពិការភ្នែក និងឥដ្ឋសម្រាប់មនុស្សពិការភ្នែក។

អក្សរសម្រាប់មនុស្សពិការភ្នែក



ឥដ្ឋសម្រាប់មនុស្សពិការភ្នែក

3) ការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សពិការត្រចៀក

1. លក្ខណៈពិសេសនៃការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សពិការត្រចៀក

ដោយសារតែមិនអាចស្តាប់លឺសំឡេងបានគ្រប់គ្រាន់ ធ្វើឲ្យមានអារម្មណ៍ឯកោ និងអារម្មណ៍នៃការបាត់បង់ខ្លាំង ដូច្នេះចាំបាច់ត្រូវផ្តល់ជំនួយខាងផ្លូវចិត្ត។

2. ចំណុចដែលត្រូវប្រុងប្រយ័ត្ននៅពេលប្រាស្រ័យទាក់ទងជាមួយមនុស្សពិការត្រចៀក

- និយាយចំពីខាងមុខ ដើម្បីដឹងពីទឹកមុខនិងចលនាមាត់ទៅវិញទៅមក។
- ប្រសិនបើមានត្រចៀកខាងណាមួយអាចស្តាប់បាន ត្រូវនិយាយនៅខាងត្រចៀកនោះ។
- បញ្ចេញសំឡេងមួយៗនិងច្បាស់ៗ។
- ត្រូវបញ្ចេញសំឡេងឲ្យខ្លាំងៗលើសពីការចាំបាច់។
- ត្រូវធ្វើការសន្ទនានៅកន្លែងដែលស្ងាត់តាមដែលអាចធ្វើទៅបាន។

3. ឧទាហរណ៍នៃមធ្យោបាយនិងឧបករណ៍ជំនួយក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សពិការត្រចៀក

ការអានមើលមាត់ (ការនិយាយស្ងាត់ៗ)

ព្យាយាមប្រាស្រ័យទាក់ទងដោយអានមើលចលនាមាត់។

● ការសន្ទនាដោយអានមើលចលនាមាត់



(ការធ្វើទំនាក់ទំនងដោយការសរសេរ)

ព្យាយាមប្រាស្រ័យទាក់ទងដោយប្រើប្រាស់ក្រដាស ឧបករណ៍ធ្វើទំនាក់ទំនងដោយការសរសេរជាដើម។ គេក៏ប្រើប្រាស់ICTផងដែរ។

● ការសន្ទនាតាមរយៈការធ្វើទំនាក់ទំនងដោយការសរសេរ

(ភាសាកាយវិការ)

ប្រាប់អត្ថន័យ ដោយផ្សំចលនាផ្សេងៗដូចជាចលនាដៃនិងម្រាមដៃនិងចលនាក្បាលនិងកជាដើម។

● ការសន្ទនាដោយប្រើប្រាស់ភាសាកាយវិការ



(ឧបករណ៍ជំនួយក្នុងការស្តាប់)

ឧបករណ៍ជំនួយក្នុងការស្តាប់ គឺជាឧបករណ៍ដែលពង្រីកសំឡេងហើយបញ្ជូនទៅត្រចៀកដោយមេក្រូ។

● ការសន្ទនាដោយប្រើឧបករណ៍ជំនួយក្នុងការស្តាប់



4) ការប្រាស្រ័យទាក់ទងជាមួយមនុស្សដែលមានជំងឺនិយាយមិនរួច

1. លក្ខណៈ ពិសេសនៃការប្រាស្រ័យទាក់ទងជាមួយមនុស្សដែលមានជំងឺនិយាយមិនរួច

ជំងឺនិយាយមិនរួច ត្រូវបានគេមើលឃើញមានការចុះខ្សោយមុខងារដូចជា "ស្តាប់យល់ការសន្ទនា" "អានយល់អត្ថបទដែលគេសរសេរ" "និយាយ" "សរសេរអក្សរ"ជាដើម ដោយសារតែការខូចខាតផ្នែកដែលទាក់ទងនឹងភាសានៃខួរធំ។

2. ចំណុចដែលត្រូវប្រុងប្រយ័ត្ននៅពេលធ្វើការប្រាស្រ័យទាក់ទងជាមួយមនុស្សដែលមានជំងឺនិយាយមិនរួច

- និយាយទៅកាន់មួយៗនិងច្បាស់ៗដោយប្រើប្រាស់ពាក្យពេចន៍ខ្លីៗហើយងាយស្រួលយល់។
- ប្រើប្រាស់ការប្រាស្រ័យទាក់ទងដោយមិនប្រើភាសាដូចជារូបភាពនិងរូបថត កាយវិការខ្លួននិងកាយវិការដៃជាដើម។
- កុំព្យាយាមចាប់កំហុសតិចតួចនៅពេលដែលនិយាយខុស។ ព្យាយាមសួរសំណួរបិទ ដែលងាយក្នុងការឆ្លើយដូចជា "បាទ/ចាស៎" "ទេ"ជាដើម។

3. ឧទាហរណ៍នៃមធ្យោបាយនិងឧបករណ៍ជំនួយក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សដែលមានជំងឺនិយាយមិនរួច

- ប្រើប្រាស់កាយវិការខ្លួននិងកាយវិការដៃជាដើម ក្រៅពីការបញ្ចេញសំឡេង
- ប្រើប្រាស់រូបភាព ឬរូបគំនូរជាដើម



5) ការប្រាស្រ័យទាក់ទងជាមួយមនុស្សមានជំងឺភ្លេចភ្លាំង

1. លក្ខណៈពិសេសនៃការប្រាស្រ័យទាក់ទងជាមួយមនុស្សមានជំងឺភ្លេចភ្លាំង

ដោយសារតែការចុះខ្សោយមុខងារនៃការស្គាល់ នោះនឹងធ្វើឲ្យកើតឡើងនូវការសន្ទនាដដែលៗប៉ុន្មានដង ឬការមិនស៊ីគ្នានៃការប្រាស្រ័យទាក់ទងរវាងអ្នកមើលថែទាំនិងអ្នកប្រើប្រាស់ ។

2. ចំណុចដែលត្រូវប្រុងប្រយ័ត្ននៅពេលប្រាស្រ័យទាក់ទងជាមួយមនុស្សមានជំងឺភ្លេចភ្លាំង

- និយាយមួយៗ។
- ប្រាប់ដោយឃ្លាខ្លីៗ និងពាក្យពេចន៍ដែលងាយយល់។
- ទោះបីជាសាមីខ្លួន និយាយខុសពីការពិតជាក់ស្តែងក៏ដោយ ត្រូវយល់ចិត្ត និងទទួលយកដោយមិនធ្វើការបដិសេធ។

● ឧទាហរណ៍នៃការប្រាស្រ័យទាក់ទងជាមួយមនុស្សមានជំងឺភ្លេចភ្លាំង

ទទួលយកការមិនស្ងប់ក្នុងចិត្តរបស់មនុស្សមានជំងឺភ្លេចភ្លាំង។

CHAPTER

3 ការប្រាស្រ័យទាក់ទងជាមួយក្រុមការងារ

1 ការស្វែងយល់ជាមូលដ្ឋានពីការចែករំលែកព័ត៌មានតាមរយៈកំណត់ត្រា

1) គោលដៅនៃការចែករំលែកព័ត៌មាន

ការមើលថែទាំ គឺមិនមែនអនុវត្តដោយអ្នកមើលថែទាំតែឯងនោះទេ គឺត្រូវធ្វើជាក្រុម ដោយសហការជាមួយវិជ្ជាជីវៈផ្សេងៗដូចជាអ្នកជំនាញផ្នែកព្យាបាលជាដើម។ ដើម្បីផ្តល់សេវាកម្មមើលថែទាំកាន់តែល្អប្រសើរដល់អ្នកប្រើប្រាស់ ត្រូវចែករំលែកខ្លឹមសារនៃការមើលថែទាំ និងព័ត៌មានទាក់ទងនឹងការព្យាបាលជាមួយក្រុមការងារ ។

⦿ របៀបនៃការចែករំលែកព័ត៌មាន

ការចែករំលែកព័ត៌មានតាមរយៈកំណត់ត្រា

មានដូចជាគម្រោងនៃការមើលថែទាំ កំណត់ត្រាករណី សៀវភៅសរសេរការផ្តាំផ្ញើជាដើម។

ការចែករំលែកព័ត៌មានតាមរយៈការប្រជុំ (ការសន្ទនា)

មានដូចជាការផ្តាំផ្ញើដែលបញ្ជូនព័ត៌មានទាក់ទងនឹងអ្នកប្រើប្រាស់ក្នុងចំណោមបុគ្គលិកទាំងឡាយ និងការប្រជុំដែលធ្វើការពិចារណាខ្លឹមសារទាក់ទងនឹងការមើលថែទាំ។

● ការចែករំលែកព័ត៌មានតាមរយៈកំណត់ត្រា



● ស្ថានភាពនៃការផ្តាំផ្ញើ

2) អត្ថន័យនៃកំណត់ត្រានៅក្នុងការមើលថែទាំ

ដើម្បីផ្តល់នូវការមើលថែទាំដែលមានគុណភាពខ្ពស់ អ្នកមើលថែទាំ ចាំបាច់ត្រូវក្តាប់ឲ្យបាននូវព័ត៌មានទាក់ទងនឹងអ្នកប្រើប្រាស់ ។ អ្នកមើលថែទាំ ត្រូវកត់ត្រាពីស្ថានភាពរបស់អ្នកប្រើប្រាស់ និងសកម្មភាពទៅកាន់អ្នកប្រើប្រាស់និងប្រតិកម្មតបចំពោះសកម្មភាពនោះ។

អត្ថន័យនៃកំណត់ត្រាមាន2ចំណុច គឺការផ្តល់សេវាកម្មដែលកាន់តែល្អប្រសើរ និងការអនុវត្តការមើលថែទាំជាក្រុម។

3) មូលដ្ឋានដើម្បីសរសេរកំណត់ត្រាការមើលថែទាំ

① កត់ត្រានៅពេលដែលកំពុងចងចាំច្បាស់។

② កត់ត្រាថ្ងៃខែនិងពេលវេលាឲ្យបានត្រឹមត្រូវ។

កត់ត្រាថ្ងៃខែ ដើម្បីឲ្យដឹងថារឿងរ៉ាវដែលបានកត់ចូលកើតឡើងនៅពេលណា។

③ កត់ត្រាការពិត។

ការពិត មាន "ការពិតលក្ខណៈអត្តនោម័ត" "ការពិតលក្ខណៈសត្យានុម័ត"។

ការពិត	ខ្លឹមសារ
ការពិតលក្ខណៈអត្តនោម័ត	• ការមើលរបស់អ្នកប្រើប្រាស់ បទពិសោធន៍សាមីខ្លួន និងការត្អូញត្អែររបស់សាមីខ្លួនជាដើម • ពាក្យសម្តីរបស់អ្នកប្រើប្រាស់
ការពិតលក្ខណៈសត្យានុម័ត	• ការសង្កេតមើលរបស់អ្នកមើលថែទាំជាដើម • ទិន្នន័យនៃការពិនិត្យ តួរលេខសម្ពាធឈាមនិងកម្តៅក្នុងខ្លួនជាដើម

● ឧទាហរណ៍នៃកំណត់ត្រា

ការពិតលក្ខណៈសត្យានុម័ត ការពិតលក្ខណៈអត្តនោម័ត

ថ្ងៃខែ	ខ្លឹមសារ
2019/7/20	ម៉ោង8ព្រឹកនៅពេលមើលថែទាំក្នុងការបន្ទោបង់បានមើលឃើញកន្ទួលក្រហមប្រវែង 1cmនៅឆ្អឹងកងត្រគាករបស់លោក○○។ នៅពេលសួរបញ្ជាក់សាមីខ្លួន គាត់ប្រាប់ថា "គ្មានការឈឺចាប់ទេ"។ បានរាយការណ៍ទៅកាន់គិលានុបដ្ឋាក និងបានដឹងថាវាជាដំណាក់កាលដំបូងនៃអាការរលាកស្បែកដោយសារគេងយូរ។

④ កត់ត្រាខ្លឹមសារដែលអាចយល់នៅពេលអានតែមួយដង។

កំណត់ត្រា ត្រូវសរសេរឲ្យបានច្បាស់លាស់នូវចំណុចទាំង6 ដូចខាងក្រោម។

①When	⇒	ពេលណា
②Where	⇒	កន្លែងណា
③Who	⇒	នរណា
④What	⇒	អ្វី
⑤Why	⇒	ហេតុអ្វី
⑥How	⇒	របៀបណា

● ឧទាហរណ៍នៃឃ្លាដែលងាយយល់

① ពេលណា ② កន្លែងណា ③ នរណា

នៅថ្ងៃទី○ ខែ○ ដោយសារតែលោក A រើសបាន កាបូបលុយមួយនៅស្ថានីយ៍រថភ្លើងទីក្រុងតូក្យូ យើងបានទៅប៉ុស្តិ៍ប៉ូលីស។

④ អ្វី ⑤ ហេតុអ្វី ⑥ របៀបណា

4) ការការពារព័ត៌មានបុគ្គល និងការរក្សាការសម្ងាត់

អ្នកមើលថែទាំ ត្រូវប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់អំពីការគ្រប់គ្រងព័ត៌មាន។ ជាពិសេស ការការពារព័ត៌មានបុគ្គល និងការរក្សាការសម្ងាត់ ត្រូវបានទាមទារយ៉ាងតឹងរឹងជាក្រមសីលធម៌វិជ្ជាជីវៈរបស់អ្នកជំនាញ។

ករណីចែករំលែកព័ត៌មានបុគ្គល ចាំបាច់ត្រូវទទួលការយល់ព្រមពីអ្នកប្រើប្រាស់ផ្ទាល់ខ្លួន អំពីការប្រើប្រាស់ជាដើមនៃព័ត៌មានបុគ្គល។

(ប្រភេទផ្សេងៗនៃព័ត៌មានបុគ្គល)

ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ រូបថតដែលសាមីខ្លួនបានថតជាដើម

ដើម្បីការពារព័ត៌មានបុគ្គល ត្រូវប្រុងប្រយ័ត្ននូវចំណុចដូចខាងក្រោម។

- នៅក្រៅកន្លែងធ្វើការ មិនត្រូវនិយាយពីអ្នកប្រើប្រាស់ឬកន្លែងធ្វើការឡើយ។
- មិនត្រូវសរសេរខ្លឹមសារទាក់ទងនឹងអ្នកប្រើប្រាស់ ឬកន្លែងធ្វើការនៅក្នុងអ៊ីនធឺណិត ឬSNSជាដើមឡើយ។



2 ការរាយការណ៍ ការទាក់ទង និងការពិភាក្សា

1) ការរាយការណ៍ និងការទាក់ទង

អ្នកមើលថែទាំ ត្រូវផ្តល់ការមើលថែទាំនៅក្នុងក្រុមការងារ។ ដូច្នេះហើយ ត្រូវធ្វើការរាយការណ៍ ធ្វើការទាក់ទង និងធ្វើការចែករំលែកព័ត៌មាននៅក្នុងក្រុមការងារ ដូចជារឿងដែលខ្លួនចាប់អារម្មណ៍ទាក់ទងនឹងអ្នកប្រើប្រាស់ ស្ថានភាពដំណើរការនៃការងាររបស់ខ្លួនជាដើម។

ពេលវេលានៃការរាយការណ៍ និងការទាក់ទង គឺខុសគ្នាទៅតាមខ្លឹមសារ។ ប្រសិនបើមានភាពបន្ទាន់ខ្ពស់ដូចជាករណីមានគ្រោះថ្នាក់កើតឡើង ត្រូវរាយការណ៍ឲ្យបានលឿន។

● ភាគីបញ្ជូនព័ត៌មាន

- ត្រូវប្រាប់ឲ្យបានច្បាស់លាស់
- ប្រាប់ដោយធ្វើការបែងចែករវាងការពិតនិងការវិនិច្ឆ័យ
- ត្រូវរាយការណ៍ដោយគិតពីទីកន្លែងនិងពេលវេលា

● ភាគីទទួលព័ត៌មាន

- ធ្វើការកត់ត្រា
- ស្តាប់ដោយធ្វើការបែងចែករវាងការពិតនិងការវិនិច្ឆ័យ
- ថាឡើងវិញ

2) ការពិភាក្សា

ការពិភាក្សា គឺជាការទទួលការផ្តល់ដំបូន្មានពីបុគ្គលិក ឬអ្នកជំនាញផ្សេងទៀត នៅពេលមានការលំបាក ឬរឿងដែលមិនយល់។ នៅពេលដែលមានបញ្ហា ត្រូវធ្វើការពិភាក្សា កុំធ្វើការវិនិច្ឆ័យតែម្នាក់ឯង។

PART 4

បច្ចេកទេសផ្តល់ជំនួយនៅក្នុងការរស់នៅ

CHAPTER 1 ការមើលថែទាំនៅពេលផ្លាស់ទី

CHAPTER 2 ការមើលថែទាំនៅពេលបរិភោគអាហារ

CHAPTER 3 ការមើលថែទាំនៅពេលបញ្ចេញចោល

CHAPTER 4 ការមើលថែទាំនៅពេលរៀបចំខ្លួន

CHAPTER 5 ការមើលថែទាំនៅពេលងូតទឹកនិងរក្សាអនាម័យ

CHAPTER 6 ការមើលថែទាំនៅពេលធ្វើការងារផ្ទះ

CHAPTER

1 ការមើលថែទាំនៅពេលផ្លាស់ទី

1 អត្ថន័យនៃការផ្លាស់ទី

1) អត្ថន័យនៃការផ្លាស់ទីនៅក្នុងការមើលថែទាំ

មនុស្ស តាមរយៈការផ្លាស់ទីនឹងធ្វើឲ្យវិសាលភាពនៃសកម្មភាពរីកធំទូលាយ។ ការរស់នៅដែលវិសាលភាពនៃសកម្មភាពមានភាពធំទូលាយ នឹងមានឥទ្ធិពលដល់ការរក្សានិងពង្រឹងស្ថានភាពរាងកាយនិងមុខងារស្មារតី។ នៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ មនុស្សធ្វើការផ្លាស់ទីទៅដល់កន្លែងធ្វើសកម្មភាព ដូចជាញុំាអាហារនៅអាហារដ្ឋាន បន្ទោបង់នៅបង្គន់ ងូតទឹកនៅបន្ទប់ទឹកជាដើម។ ការផ្លាស់ទី គឺទាក់ទងទៅនឹងសកម្មភាពនៃការរស់នៅទាំងមូល។

● ទំនាក់ទំនងនៃADL, IADL



ការពន្យល់

ADL (Activities of Daily Living: សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ) និងIADL (Instrumental Activities of Daily Living: សកម្មភាពជាមធ្យោបាយក្នុងការរស់នៅប្រចាំថ្ងៃ)

ADL គឺជាក្រុមសកម្មភាពរាងកាយជាមូលដ្ឋានដែលអនុវត្តឡើងដើម្បីការរស់នៅដោយឯករាជ្យរបស់មនុស្សម្នាក់ៗ។ ADL រួមមានការផ្លាស់ទី ការបរិភោគអាហារ ការប្តូរសម្លៀកបំពាក់ ការបន្ទោបង់ និងការងូតទឹកជាដើម។ IADL គឺជាសមត្ថភាពដែលចាំបាច់ដើម្បីរក្សាការរស់នៅនៅក្នុងគ្រួសារ និងតំបន់។ IADL រួមមានការគ្រប់គ្រងប្រាក់កាស ការទិញឥវ៉ាន់ ការបោកគក់ ការប្រើប្រាស់យានជំនិះ ការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ជាដើម។

2 ប្រព័ន្ធរាងកាយ និងផ្លូវចិត្តដែលទាក់ទងនឹងការផ្លាស់ទី

1) ផ្នែកនៃរាងកាយដែលទាក់ទងនឹងការផ្លាស់ទី

ការផ្លាស់ទី មានទំនាក់ទំនងជាមួយនឹងសាច់ដុំ និងសន្លាក់ផ្សេងៗ។

● ផ្នែករាងកាយសំខាន់ៗដែលទាក់ទងនឹងការផ្លាស់ទី



2) ឥរិយាបថរាងកាយ

ឥរិយាបថរាងកាយ ត្រូវបានបែងចែកជា ឥរិយាបថរាងកាយឈរ (ឥរិយាបថឈរ) ឥរិយាបថរាងកាយអង្គុយ (ឥរិយាបថអង្គុយ) ឥរិយាបថរាងកាយគេង (ឥរិយាបថគេង)។

① ឥរិយាបថឈរ

● ឥរិយាបថឈរ



② ឥរិយាបថអង្គុយ

● ឥរិយាបថអង្គុយទម្លាក់ជើងទាំងពីរនៅចំហៀងគ្រែ



● ឥរិយាបថអង្គុយកៅអី(ឥរិយាបថអង្គុយ)



● ឥរិយាបថអង្គុយច្រត់ដៃទៅក្រោយ



● ឥរិយាបថទម្រេតខ្លួន

③ ឥរិយាបថគេង

● ឥរិយាបថគេងផ្ងារ



● ឥរិយាបថគេងផ្អៀង



● ឥរិយាបថគេងផ្កាប់មុខ



3) ឥរិយាបថរាងកាយសម្រាក

- ឥរិយាបថរាងកាយសម្រាកដោយគេងផ្ងារ
  គឺជាឥរិយាបថដែលមានលំនឹងបំផុត។



- ឥរិយាបថរាងកាយសម្រាកដោយគេងផ្អៀង (ខាងស្តាំ)
  ដាក់ខ្នើយនៅមុខដើមទ្រូង។
  ដាក់ខ្នើយនៅក្រោមជើងខាងស្តាំ និងចន្លោះអវយវៈខាងក្រោមទាំងសងខាង។



- ឥរិយាបថរាងកាយសម្រាកដោយអង្គុយពាក់កណ្តាល (ការទម្រេតខ្លួន)
  លើកបត់អវយវៈខាងក្រោមទាំងសងខាងបញ្ឈរឡើង។ ករណីដែលមិនអាចបត់បញ្ឈរឡើងបាន ត្រូវដាក់ខ្នើយនៅក្រោមជង្គង់ទាំងសងខាង។



ការពន្យល់

ការបង្វើបខ្នង

បន្ទាប់ពីលើកពាក់កណ្តាលខ្លួនលើឡើង បង្វើបខ្នងរបស់អ្នកប្រើប្រាស់ចេញពីគ្រែមួយដងសិន។ គេហៅវាថា ការបង្វើបខ្នង។ ការបង្វើបខ្នងនេះ នឹងជួយទប់ស្កាត់អាការរលាកស្បែកដោយសារគេងយូរ។

4) រោគសញ្ញានៃការប្រើលែងបាន

រោគសញ្ញានៃការប្រើលែងបាន គឺជាស្ថានភាពផ្សេងៗនៃរាងកាយនិងផ្លូវចិត្តដែលកើតឡើងក្នុងករណីដែលការសម្រាករយៈពេលយូរ និងការធ្វើសកម្មភាពថយចុះ។



5) អាការរលាកស្បែកដោយសារគេងយូរ

អាការរលាកស្បែកដោយសារគេងយូរ គឺការស្លាប់នៃកោសិការបស់ស្បែកដែលកើតឡើងដោយសារបញ្ហាលំហូរចរន្តឈាមនៅក្នុងផ្នែកនៃរាងកាយដែលមានឆ្អឹងលយចេញ ដែលបណ្តាលមកពីការគេងក្នុងរយៈពេលយូរ។ ស្នាមជ្រួញនៃកម្រាលគ្រែ និងការកកិតនៅពេលផ្លាស់ប្តូរឥរិយាបថរាងកាយ ក៏ជាមូលហេតុបង្កឲ្យកើតអាការរលាកស្បែកដោយសារគេងយូរផងដែរ។

⦿ មធ្យោបាយនៃការទប់ស្កាត់អាការរលាកស្បែកដោយសារគេងយូរ

① ងើបក្រោកពីគ្រែ ប្រសិនបើអាចធ្វើទៅបាន។

② ធ្វើការផ្លាស់ប្តូរឥរិយាបថរាងកាយជាទៀងទាត់។

③ ទទួលទានសារធាតុចិញ្ចឹមឲ្យបានគ្រប់គ្រាន់។

● ផ្នែកនៃរាងកាយដែលងាយនឹងមានអាការរលាកស្បែកដោយសារគេងយូរ



6) ឧបករណ៍ជំនួយទាក់ទងនឹងការផ្លាស់ទី

ឧបករណ៍ជំនួយទាក់ទងនឹងការផ្លាស់ទីក្រៅពីកៅអីរុញ មានឈើច្រត់និងប្រដាប់ទប់លំនឹងនៅពេលដើរ ឧបករណ៍យោងជាដើម។



ឈើច្រត់រាងអក្សរT

ឈើច្រត់ដែលមានជើងច្រើន



ឈើច្រត់រាងអក្សរT:
ស្រាលនិងងាយស្រួលប្រើ។
ឈើច្រត់ដែលមានជើងច្រើន:
ដោយសារតែផ្ទៃទម្រមានទំហំធំជាងឈើច្រត់រាងអក្សរT ដូច្នេះហើយ គេប្រើប្រាស់វាក្នុងករណីដែលការទ្រទម្ងន់នៅខាងដែលមានបញ្ហាគឺមិនបានគ្រប់គ្រាន់។

ប្រដាប់ទប់លំនឹងនៅពេលដើរ:
វាមានលំនឹងជាងឈើច្រត់ដោយសារតែផ្ទៃទម្ររបស់វាមានទំហំធំជាង។

ឧបករណ៍យោង មានប្រសិទ្ធភាពក្នុងការកាត់បន្ថយបន្ទុកក្នុងការមើលថែទាំរបស់អ្នកមើលថែទាំ។

① ឧបករណ៍យោងចល័តតាមពិដាន	② ឧបករណ៍យោងចល័តនៅផ្ទាល់ដី
	

3 ការអនុវត្តការមើលថែទាំពេលរំកិលឆ្លងនិងពេលផ្លាស់ទី

1) មូលដ្ឋាននៃការមើលថែទាំរាងកាយ

វាមានលក្ខណៈរួមទៅនឹងសកម្មភាពមើលថែទាំទាំងអស់។

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។

នៅពេលធ្វើការមើលថែទាំ ត្រូវពិនិត្យសុខភាពរាងកាយរបស់អ្នកប្រើប្រាស់ទុកជាមុនជានិច្ច។ បើសុខភាពមិនល្អ មិនត្រូវធ្វើទាំងបង្ខំ គឺត្រូវរាយការណ៍ទៅអ្នកជំនាញផ្នែកព្យាបាល។

② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។

នៅពេលធ្វើការមើលថែទាំ ត្រូវតែគោរពការសម្រេចចិត្តផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។ ម្យ៉ាងទៀត ការដឹងជាមុនអំពីខ្លឹមសារនៃការមើលថែទាំនឹងធ្វើឲ្យអ្នកប្រើប្រាស់អាចទុកចិត្តបាននិងយល់ព្រមទទួលជំនួយ។

③ កែសម្រួលកម្ពស់គ្រែឲ្យងាយស្រួលមើលថែទាំ។



កែសម្រួលកម្ពស់គ្រែដើម្បីកាត់បន្ថយបន្ទុកទៅលើផ្នែកចង្កេះរបស់អ្នកមើលថែទាំ។

ការពន្យល់

ការផ្តល់ជំនួយឲ្យមានភាពម្ចាស់ការ

ផ្តល់ជំនួយលើអ្វីដែលអ្នកប្រើប្រាស់មិនអាចធ្វើបាន។ ហេតុនេះ ចាំបាច់ត្រូវពិនិត្យស្ថានភាពរបស់អ្នកប្រើប្រាស់ឲ្យបានល្អ។

ក្នុងសៀវភៅនេះ គឺពន្យល់ពីចលនារបស់អ្នកមើលថែទាំ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គឺត្រូវឲ្យអ្នកប្រើប្រាស់ធ្វើអ្វីដែលគាត់អាចធ្វើបាន។

2) ការមើលថែទាំពេលប្តូរខាងពេលគេង

នៅទីនេះ យើងនឹងពន្យល់ដោយលើកឧទាហរណ៍អ្នកប្រើប្រាស់ដែលពិការមួយចំហៀងខ្លួនខាងឆ្វេង។

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។
② ពន្យល់ពីសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។
③ កែសម្រួលកម្ពស់គ្រែឲ្យងាយស្រួលមើលថែទាំ។
④ បញ្ឈរជង្គង់របស់អ្នកប្រើប្រាស់។
⑤ ឲ្យគេងផ្អៀងដោយឲ្យខាងដែលមានបញ្ហានៅខាងលើ។

⑥ រំកិលចង្កេះរបស់អ្នកប្រើប្រាស់ទៅក្រោយ។



⑦ ប្តូរទីតាំងជើងរបស់អ្នកប្រើប្រាស់ទៅទីតាំងដែលផ្តល់ផាសុកភាព។



3) ការមើលថែទាំពេលក្រោកឡើង(ពីគេងផ្អៀងខាងស្តាំទៅឥរិយាបថអង្គុយទម្លាក់ជើងទាំងពីរនៅចំហៀងគ្រែ)

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។

② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។

③ កែសម្រួលកម្ពស់គ្រែឲ្យត្រឹមកម្ពស់ដែលពេលអ្នកប្រើប្រាស់អង្គុយទម្លាក់ជើងទាំងពីរនៅចំហៀងគ្រែគឺបាតជើងទាំងពីរប៉ះនឹងកម្រាលឥដ្ឋ។

④ ឲ្យគេងផ្អៀងដោយឲ្យខាងដែលមានបញ្ហានៅខាងលើ។

⑤ រំកិលជើងទាំងពីររបស់អ្នកប្រើប្រាស់ទៅជាយគ្រែ។

⑥ ទម្លាក់ជើងទាំងពីររបស់អ្នកប្រើប្រាស់ចុះពីលើគ្រែហើយឲ្យបញ្ចូលកម្លាំងនៅកែងដៃស្តាំ។ បន្ទាប់មកលើកផ្នែកខាងលើនៃរាងកាយឡើង។



⑦ ពិនិត្យមើលសុខភាពរាងកាយនិងអារម្មណ៍របស់អ្នកប្រើប្រាស់។
⑧ ពិនិត្យមើលថាបាតជើងទាំងពីរប៉ះនឹងកម្រាលឥដ្ឋ។



4) ការមើលថែទាំពេលក្រោកឈរ (ពីឥរិយាបថអង្គុយទម្លាក់ជើងទាំងពីរនៅចំហៀងគ្រែទៅឥរិយាបថឈរ)

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។
② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។
③ ឲ្យអង្គុយសាជាថ្មីឲ្យរាក់។

④ ទាញជើងខាងដែលមិនមានបញ្ហារបស់អ្នកប្រើប្រាស់ទៅក្រោយ។ ក្នុងពេលនេះ អ្នកមើលថែទាំត្រូវស្ថិតនៅខាងដែលមានបញ្ហា។



⑤ អ្នកមើលថែទាំប្រើដៃទប់ជង្គង់ខាងដែលមានបញ្ហាដើម្បីកុំឲ្យភ្លាត់ជង្គង់។ ឲ្យអ្នកប្រើប្រាស់ពត់ផ្នែកខាងលើនៃរាងកាយបណ្ដើរឲ្យក្រោកឈរបណ្ដើរ។



⑥ ពិនិត្យមើលសុខភាពរាងកាយនិងអារម្មណ៍របស់អ្នកប្រើប្រាស់។

ការពន្យល់

ការភ្លាត់ជង្គង់

ការភ្លាត់ជង្គង់គឺជាអាការដែលនៅពេលឈរឬដើរ ជង្គង់មិនមានកម្លាំង ធ្វើឲ្យវាបត់ភ្លាត់។ វាក៏ជាមូលហេតុនាំឲ្យដួលផងដែរ។

5) ការមើលថែទាំពេលដើរសម្រាប់អ្នកប្រើប្រាស់ដែលពិការមួយចំហៀងខ្លួន

(ការដើរដោយប្រើឈើច្រត់)

ការដើរដោយប្រើឈើច្រត់គឺមានការដើរដោយ2ចលនា និងការដើរដោយ3ចលនា។

● ប្រៀបធៀប ការដើរដោយ2ចលនា និង ការដើរដោយ3ចលនា

ការដើរ	ការដើរដោយ2ចលនា	ការដើរដោយ3ចលនា
លំដាប់នៃការឈានជើង	① ឈើច្រត់និងខាងដែលមានបញ្ហា → ② ខាងដែលមិនមានបញ្ហា 	① ឈើច្រត់ → ② ខាងដែលមានបញ្ហា → ③ ខាងដែលមិនមានបញ្ហា 
លំនឹង	ទាប	ខ្ពស់



មូលហេតុដែលឈានពីជើងខាងដែលមានបញ្ហាគឺដោយសារតែចាំបាច់ត្រូវទ្ររាងកាយដោយខាងដែលមិនមានបញ្ហាដែលមានសមត្ថភាពទ្រខ្ពស់នៅពេលចាប់ផ្ដើមដើរ។

ការមើលថែទាំពេលដើរដោយប្រើឈើច្រត់

អ្នកមើលថែទាំត្រូវឈរនៅពីក្រោយខាងដែលមានបញ្ហារបស់អ្នកប្រើប្រាស់។ ត្រូវទប់ផ្នែកខាងលើនៃរាងកាយឬចង្កេះបើចាំបាច់។



(ការឡើងជណ្ដើរ)

ដើម្បីរក្សាសុវត្ថិភាព អ្នកមើលថែទាំ ត្រូវស្ថិតនៅមួយកាំខាងក្រោម(ពីក្រោយ)អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់ត្រូវឡើងជណ្ដើរតាមលំដាប់ ①ឈើច្រត់→②ជើងខាងដែលមិនមានបញ្ហា→③ជើងខាងដែលមានបញ្ហា។

បើមានបង្កាន់ដៃ ត្រូវកាន់បង្កាន់ដៃទើបមានលំនឹងល្អជាង។

(ការចុះជណ្ដើរ)

ដើម្បីរក្សាសុវត្ថិភាព អ្នកមើលថែទាំត្រូវស្ថិតនៅមួយកាំខាងក្រោម(ពីមុខ)អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់ត្រូវចុះជណ្ដើរតាមលំដាប់ ①ឈើច្រត់→②ជើងខាងដែលមានបញ្ហា→③ជើងខាងដែលមិនមានបញ្ហា។

បើមានបង្កាន់ដៃ ត្រូវកាន់បង្កាន់ដៃទើបមានលំនឹងល្អជាង។

6) ការមើលថែទាំពេលដើរសម្រាប់អ្នកប្រើប្រាស់ដែលពិការភ្នែក

ល្បឿនដើរគឺសម្របតាមល្បឿនរបស់អ្នកប្រើប្រាស់។ នៅពេលស្ថានភាពប្រែប្រួលដូចជាកន្លែងមានកម្ពស់ទាបខ្ពស់ឬកន្លែងបត់ជាដើម ត្រូវពន្យល់ប្រាប់ដោយពាក្យសម្ដីទុកជាមុន។

● ឥរិយាបថមូលដ្ឋាននៅពេលនាំផ្លូវ

7) ការមើលថែទាំចំពោះកៅអីរុញ

● រចនាសម្ពន្ធនៃកៅអីរុញនិងឈ្មោះផ្នែកនិមួយៗ



(ចំណុចត្រូវប្រុងប្រយ័ត្នពាក់ព័ន្ធនឹងកៅអីរុញ)

- នៅពេលប្រើកៅអីរុញ ត្រូវត្រួតពិនិត្យសម្ពាធខ្យល់ក្នុងកង់និងស្ថានភាពហ្វ្រាំងជាដើមទុកជាមុន។ បើសម្ពាធខ្យល់ក្នុងកង់ទាប នោះនឹងធ្វើឲ្យហ្វ្រាំងមិនដំណើរការល្អដែលនាំឲ្យគ្រោះថ្នាក់។
- នៅពេលឈប់ ត្រូវដាក់ហ្វ្រាំងជានិច្ច។ ទោះពេលមិនមានមនុស្សជិះក៏ដោយ បើកៅអីរុញរំកិលគឺគ្រោះថ្នាក់ ហេតុនេះពេលឈប់ ត្រូវដាក់ហ្វ្រាំង។

8) ការរំកិលឆ្លងពីគ្រែទៅជិះកៅអីរុញ

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។

② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។

③ កម្ពស់គ្រែត្រូវកែសម្រួលឲ្យត្រឹមកម្ពស់ដែលពេលអ្នកប្រើប្រាស់អង្គុយទម្លាក់ជើងទាំងពីរនៅចំហៀងគ្រែ គឺបាតជើងទាំងពីរប៉ះនឹងកម្រាលឥដ្ឋ។

④ ដាក់កៅអីរុញនៅខាងដែលមិនមានបញ្ហារបស់អ្នកប្រើប្រាស់ ហើយត្រូវដាក់ហ្វ្រាំង។

⑤ ឲ្យអ្នកប្រើប្រាស់ប្រើដៃខាងដែលមិនមានបញ្ហាកាន់ទម្រដៃនៅខាងដែលឆ្ងាយ។ អ្នកមើលថែទាំត្រូវការពារកុំឲ្យមានការភ្លាត់ជង្គង់ខាងដែលមានបញ្ហា។



ចំពោះការផ្លាស់ទីរបស់ជនពិការ
ជាគោលការណ៍គឺត្រូវធ្វើចលនាពីខាងដែលមិនមានបញ្ហាទៅមុន។

⑥ ឲ្យអ្នកប្រើប្រាស់ក្រោកឈរយឺតៗដោយឱនក្បាលបណ្ដើរ ហើយឲ្យបែរខ្លួនទៅរកកៅអីរុញ។

⑦ ឲ្យអ្នកប្រើប្រាស់អង្គុយឲ្យជ្រៅ។ ឲ្យដាក់ជើងលើទម្រប្រអប់ជើង។

⑧ ពិនិត្យមើលសុខភាពរាងកាយនិងអារម្មណ៍របស់អ្នកប្រើប្រាស់។

9) ការមើលថែទាំនៅពេលផ្លាស់ទីដោយកៅអីរុញ

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។
② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។
③ ដាក់ជើងរបស់អ្នកប្រើប្រាស់នៅលើទម្រប្រអប់ជើង។
④ ត្រូវប្រយ័ត្នកុំឲ្យដៃរបស់អ្នកប្រើប្រាស់គាបចូលកង់ដែលធ្វើចលនា។
⑤ ដោះហ្វ្រាំងហើយបន្ទាប់ពីប្រាប់ថានឹងរុញរួចហើយសឹមរុញកៅអីរុញ។



(ការឡើងកន្លែងទួល)

ត្រូវឈប់បន្តិចនៅមុខកន្លែងទួល ហើយប្រាប់អ្នកប្រើប្រាស់ថានឹងឡើងទួល។



ដាក់កង់ចល័តពីលើកន្លែងទួលយឺតៗ បន្ទាប់មកលើកកង់ដែលធ្វើចលនា។

(ការចុះពីកន្លែងទួល)

ត្រូវឈប់បន្តិចនៅមុខកន្លែងទួល ហើយប្រាប់អ្នកប្រើប្រាស់ថានឹងចុះទួល។ ទម្លាក់ចុះថយក្រោយដោយសៀមស្ងាត់នូវកង់ដែលធ្វើចលនា ។



ទាញកង់ដែលធ្វើចលនាឲ្យសមល្មម ហើយទម្លាក់កង់ចល័តទៅក្រោមទួលដោយយឺតៗ។

(ការចុះផ្លូវជម្រាល)

នៅពេលចុះជម្រាលដែលចោតខ្លាំង ត្រូវពន្យល់អ្នកប្រើប្រាស់ថានឹងចុះដោយបែរថយក្រោយ។



ឲ្យកៅអីរុញផ្លាស់ទីដោយបែរថយក្រោយ។



CHAPTER

2 ការមើលថែទាំនៅពេលបរិភោគអាហារ

1 អត្ថន័យនៃការបរិភោគអាហារ

ការបរិភោគអាហារគឺជាបរិភោគតាមមាត់ ស្រូបយកសារធាតុចិញ្ចឹមទៅក្នុងរាងកាយដើម្បីរក្សាសកម្មភាពនិងអាយុជីវិត។

ការបរិភោគតាមមាត់និងគ្រេបរសជាតិ នឹងផ្តល់រំញោចដល់ខួរធំហើយមានសារសំខាន់ក្នុងការបង្កើតចង្វាក់នៃការរស់នៅ។

ការបរិភោគគឺជាក្តីរីករាយនៅក្នុងការរស់នៅ ហើយក៏ក្លាយជាឱកាសប្រាស្រ័យទាក់ទងកសាងទំនាក់ទំនងរវាងមនុស្សនិងមនុស្ស។

2 ប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្តដែលទាក់ទងនឹងការបរិភោគអាហារ

មនុស្សកើតមានអារម្មណ៍ចង់ញ៉ាំដោយសារខួរក្បាលមានអារម្មណ៍ថាកំពុងឃ្លាន។

- ផ្លាស់ទីទៅតុបាយ ហើយសម្រួលឥរិយាបថ។ បន្ទាប់មកពិនិត្យបញ្ជាក់ចំណីអាហារដោយប្រើភ្នែក។ ប្រើចង្កឹះឬស្លាបព្រាជាដើមបញ្ជូនចំណីអាហារចូលទៅក្នុងមាត់។ ទំពារួចលេបចូល។
- ការបរិភោគអាហារគឺ ពិនិត្យចំណីអាហារដោយចក្ខុវិញ្ញាណនិងឃានវិញ្ញាណ ហើយទទួលអារម្មណ៍ចំពោះរសជាតិនិងការខាំទំពាដោយជីវ្ហាវិញ្ញាណនិងកាយវិញ្ញាណ។
- ការបរិភោគអាហារ គឺពាក់ព័ន្ធនឹងមុខងារជាច្រើន។

◉ លំហូរនៃការទទួលទាននិងលេបអាហារ

ដំណាក់កាលប្រមើលមើល		• ចាប់បាននូវពណ៌និងរូបរាង ក្លិនជាដើមរបស់ចំណីអាហារ។ • ទឹកមាត់ត្រូវបានបញ្ចេញ។
ដំណាក់កាលត្រៀម		• ទំពាចំណីអាហារដែលដាក់ចូលក្នុងមាត់ ហើយផ្សំលាយជាមួយទឹកមាត់បង្កើតជាដុំអាហារ(ដុំអាហារដែលបានទំពា bolus)។
ដំណាក់កាលក្នុងមាត់		• បញ្ជូនដុំអាហារដែលបានទំពាពីមាត់ទៅដើមបំពង់ខ្យល់។ • ការបញ្ជូនគឺប្រើប្រាស់អណ្តាត។
ដំណាក់កាលនៅដើមក		• កើតមានប្រតិកម្មតបពេលលេបអាហារ ហើយដុំអាហារដែលបានទំពា (bolus) នឹងឆ្លងកាត់ដើមក។ • សន្ទះខ្យល់នឹងបិទរាំងមិនឲ្យដុំអាហារដែលបានទំពា(bolus)ចូលក្នុងបំពង់ខ្យល់។
ដំណាក់កាលនៅបំពង់អាហារ		• ដុំអាហារដែលបានទំពា ត្រូវបានបញ្ជូនពីបំពង់អាហារចូលក្នុងក្រពះ។

ក្នុងលំហូរនេះ បើមានបញ្ហានៅចំណុចណាមួយនោះនឹងធ្វើឲ្យពិបាកទទួលទានចំណីអាហារដោយសុវត្ថិភាព។ គេហៅវាថា ពិការភាពផ្នែកទទួលទាននិងលេបអាហារ។

3 ការអនុវត្តការមើលថែទាំនៅពេលបរិភោគអាហារ

⦿ ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការមើលថែទាំពេលបរិភោគអាហារ

- បញ្ជាក់ឲ្យច្បាស់ពីអាហារដែលអ្នកប្រើប្រាស់ចូលចិត្តនិងមិនចូលចិត្ត។
- ប្រុងប្រយ័ត្នថាតើមានអ្វីដែលមិនអាចបរិភោគបានដោយសារតែការព្យាបាលជំងឺឬអាលែកហ្ស៊ី។
- ធ្វើឲ្យអាហារទន់ឬកាត់ហាន់ឲ្យល្អិតៗឲ្យងាយបរិភោគ ស្របទៅតាមសមត្ថភាពនៃការទំពានិងលេបអាហាររបស់អ្នកប្រើប្រាស់។
- ប្រុងប្រយ័ត្នធ្វើយ៉ាងណាឲ្យអាហារក្តៅគឺអាចបរិភោគបានដោយក្តៅៗ ហើយអាហារត្រជាក់គឺអាចបរិភោគបានដោយត្រជាក់ៗ។

(ទម្រង់នៃអាហារស្របតាមសមត្ថភាពទំពានិងលេបអាហារ)

អាហារហាន់ល្អិតៗ: អាហារដែលហាន់ល្អិតៗឲ្យងាយស្រួលបរិភោគ

អាហារហ្មត់: អាហារដែលទៅជាទម្រង់ហ្មត់

អាហារទន់: អាហារដែលគេធ្វើឲ្យទន់ដោយរក្សារូបរាងវានៅដដែល

អាហារជ្រាយ: អាហារមានភាពជ្រាយដើម្បីឲ្យអ្នកដែលមានសមត្ថភាពលេបអាហារទាប មិនឈ្លក់នឹងជាតិទឹក

1) ឥរិយាបថនៃការបរិភោគអាហារ

⦿ ឥរិយាបថនៃការបរិភោគអាហារដែលត្រឹមត្រូវ

ឲ្យចង្កេះចូលជ្រៅក្នុងកៅអី ហើយបាតជើងដាក់លើកម្រាលឥដ្ឋ។
ប្រើឥរិយាបថអោនទៅមុខបន្តិច ហើយទម្លាក់ចង្កាចុះ។

● ឥរិយាបថនៃការបរិភោគអាហារនៅលើគ្រែ

ពេលខ្លះក៏អាចមានការបរិភោគអាហារនៅលើគ្រែ ក្នុងករណីពិបាកបរិភោគអាហារដោយឥរិយាបថអង្គុយ។



- កាច់លើកបាតគ្រែដើម្បីឲ្យបានឥរិយាបថដែលងើបឡើងមួយកំណាត់។
- ក្រោយងើបឡើង អនុវត្តការបង្ហើបខ្នងដោយធ្វើឲ្យរាងកាយឃ្លាតពីពូកបន្តិចសិនរួចសឹមដាក់ផ្អែកលើពូកវិញ។
- ករណីពិបាកយកឥរិយាបថដែលងើបឡើងមួយកំណាត់ខ្លួនខាងលើ ត្រូវយកឥរិយាបថគេងផ្អៀង។

ករណីពិការមួយចំហៀងខ្លួន ត្រូវឲ្យខាងដែលមិនមានបញ្ហានៅខាងក្រោម។

● សម្ភារៈប្រើប្រាស់សម្រាប់ការបរិភោគអាហារ



ស្លាបព្រានិងសមដែលងាយកាន់



ចង្កឹះដែលមានទំពក់ថ្ពក់ជាប់នឹង

សម្ភារៈញាំអាហារដែលងាយកាន់



ស្លាបព្រានិងសមដែលងាយពត់ឲ្យកោង



ប្រដាប់កាន់ស្លាបព្រាភ្ជាប់ខ្សែក្រវាត់ថ្ពក់ដៃ

កែវមានដៃកាន់



ចានដែលងាយដួស



កម្រាលទប់កុំអោយរអិល

2) ការអនុវត្តការមើលថែទាំនៅពេលបរិភោគអាហារ

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។

② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។

③ សម្អាតដៃរបស់អ្នកប្រើប្រាស់។

④ ផ្លាស់ទីទៅតុអាហារហើយអង្គុយលើកៅអី។

អ្នកមើលថែទាំត្រូវពិនិត្យទុកជាមុនថាតើមានអ្វីដែលមិនអាចបរិភោគបានដោយសារតែការព្យាបាលជំងឺឬអាលែកហ្ស៊ីឬទេ។

⑤ ដាក់អាហារនៅចំពីមុខអ្នកប្រើប្រាស់ត្រង់កន្លែងដែលអាចមើលឃើញ។

⑥ អ្នកមើលថែទាំត្រូវអង្គុយបញ្ឆិតទៅមុខនៅខាងនៃដៃដែលអ្នកប្រើប្រាស់តែងប្រើឬខាងដែលមិនមានបញ្ហា។

● ទីតាំងរបស់អ្នកមើលថែទាំ

⑦ ពន្យល់ប្រាប់មុខម្ហូប(ម៉ឺនុយ)។

⑧ នៅដើមដំបូងនៃការបរិភោគអាហារ គឺត្រូវឲ្យញ៉ាំជាតិទឹកដូចជាទឹកតែឬសម្លជាដើម។

⑨ ធ្វើការមើលថែទាំបរិភោគអាហារដោយសម្របតាមល្បឿនបរិភោគរបស់អ្នកប្រើប្រាស់។

- អ្នកមើលថែទាំត្រូវអង្គុយមើលថែទាំដោយធ្វើយ៉ាងណាឲ្យក្រសែភ្នែកត្រូវគ្នាជាមួយអ្នកប្រើប្រាស់។
- ល្បឿននៃបញ្ជូនចំណីក្នុងបរិមាណមួយម៉ាត់ទៅមាត់អ្នកប្រើប្រាស់ គឺត្រូវកែសម្រួលដោយសួរអ្នកប្រើប្រាស់ឬសង្កេតមើលជាដើម។
- ករណីមានពិការភាព ត្រូវបញ្ចុកអាហារពីជ្រុងនៃមាត់ខាងដែលមិនមានបញ្ហា។
- ដើម្បីបង្ការការលេបចូលខុសបំពង់អាហារ នៅពេលកំពុងទំពា ត្រូវធ្វើយ៉ាងណាកុំនាំអ្នកប្រើប្រាស់និយាយ។
- ត្រូវពិនិត្យបញ្ជាក់ថាកំពុងទំពាដោយស្ថានភាពទម្លាក់ចង្កាចុះ។
- នៅពេលមើលថែទាំដោយប្រើស្លាបព្រា ត្រូវធ្វើយ៉ាងណាដកស្លាបព្រាចេញតាមទិសផ្តេក។







⑩ បញ្ជាក់ជាមួយអ្នកប្រើប្រាស់ថាតើឈប់បរិភោគអាហារឬនៅ។
⑪ ពិនិត្យបញ្ជាក់ថាតើមានសល់ចំណីអាហារក្នុងមាត់ឬទេ។
⑫ ធ្វើការថែទាំមាត់ធ្មេញ(ខ្ពុល់មាត់ ដុះធ្មេញ សម្អាតធ្មេញសិប្បនិម្មិត)។
⑬ ក្នុងរយៈពេល30នាទីក្រោយបរិភោគអាហារ ត្រូវឲ្យប្រើឥរិយាបថអង្គុយដើម្បីការពារលោកស្ទួតដោយលេបចូលខុសបំពង់អាហារ។

3) ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការមើលថែទាំពេលបរិភោគអាហារ

- ត្រូវសង្កេតមើលថាតើមានបញ្ហានៅត្រង់ល្បឿននៃការបរិភោគ ឥរិយាបថ ចលនាបរិភោគ និងស្ថានភាពជាដើមនៃការទំពានិងលេបអាហារ។
- ធ្វើយ៉ាងណាបញ្ជូនចំណីអាហារទៅក្នុងមាត់ដោយស្របតាមការចង់បានរបស់អ្នកប្រើប្រាស់។
- ចំពោះអ្នកពិការភ្នែក ត្រូវប្រើទីតាំងទ្រនិចនាឡិកា(វិធីផ្តល់ដំណឹងដោយទីតាំងទ្រនិចនាឡិកា)។ ពន្យល់ថាតើអាហារក្តៅឬត្រជាក់និងអំពីរសជាតិផងដែរ។

● ឧទាហរណ៍នៃទីតាំងទ្រនិចនាឡិកា



CHAPTER

3 ការមើលថែទាំនៅពេលបញ្ចេញចោល

1 អត្ថន័យនៃការបញ្ចេញចោល

ការបញ្ចេញចោលគឺជាការបញ្ចេញរបស់ដែលមិនចាំបាច់នៅក្នុងរាងកាយឲ្យចេញទៅខាងក្រៅនៃរាងកាយ។ របស់ដែលមិនចាំបាច់គឺមានដូចជា ទឹកនោម លាមក ញើស ឧស្ម័នកាបូនិចជាដើម។

ការបញ្ចេញចោលគឺជាប្រព័ន្ធនៃរាងកាយរបស់មនុស្សដែលចាំបាច់ក្នុងការរក្សាសុខភាព។ ម្យ៉ាងទៀត ទឹកនោមឬលាមកដែលត្រូវបានបញ្ចេញចោល គឺបង្ហាញពីស្ថានភាពសុខភាព។ ការមើលថែទាំដោយស្របនឹងមូលហេតុដែលត្រូវការការមើលថែទាំពាក់ព័ន្ធនឹងការបញ្ចេញចោល គឺមានសារសំខាន់។

ការបញ្ចេញចោលគឺជាសកម្មភាពដែលភ្ជាប់មកជាមួយនូវអារម្មណ៍ខ្មាសអៀន។ ក្នុងការមើលថែទាំនៅពេលបញ្ចេញចោល ការជួយដោយយល់អារម្មណ៍អ្នកប្រើប្រាស់គឺជារឿងសំខាន់។

2 ប្រព័ន្ធបញ្ចេញចោល

1) ប្រព័ន្ធបញ្ចេញទឹកនោម

ទឹកនោមត្រូវបានបង្កើតនៅក្នុងតម្រងនោម ហើយបន្ទាប់ពីត្រូវបានស្តុកទុកបណ្តោះអាសន្ននៅក្នុងប្លោកនោម វានឹងត្រូវបញ្ចេញចោលពីបង្ហួរនោម។ នេះហៅថា ការបញ្ចេញទឹកនោម។

នៅពេលប្លោកនោមស្តុកទឹកនោមបានប្រហែល200 - 300ml នោះនឹងមានអារម្មណ៍ "ចង់ទៅបង្គន់"។ នេះហៅថា ចំណង់នោម។

● ផ្នែកនៃរាងកាយដែលពាក់ព័ន្ធនឹងការបង្កើតទឹកនោម

ផ្នែកសំខាន់ក្នុងការកំណត់ការបញ្ចេញទឹកនោម ស្ថិតនៅ ខួរធំ ខួរកញ្ចឹងក ខួរឆ្អឹងខ្នង។



មុខងារនៃតម្រងនោម
ច្រោះពីក្នុងឈាមនូវកាកសំណល់ជាដើមដែលមិនចាំបាច់ចំពោះរាងកាយ បង្កើតបានជាទឹកនោម។

មុខងារនៃបំពង់បង្ហួរទឹកនោម
បំពង់ដែលបញ្ជូនទឹកនោមដែលត្រូវបានផលិតដោយតម្រងនោមទៅកាន់ប្លោកនោម។

ឧទាហរណ៍ចំពោះស្ត្រី

មុខងារនៃបង្ហួរនោម
ចំពោះមនុស្សប្រុសគឺវែង។
ចំពោះមនុស្សស្រីគឺខ្លី។
បង្ហួរនោមរបស់មនុស្សប្រុសគឺត្រូវបានហ៊ុមព័ទ្ធដោយក្រពេញប្រូស្តាត។

មុខងារនៃប្លោកនោម
គឺជាថង់ស្តុកទុកទឹកនោម។
វាមានចំណុះប្រហែល500ml។
នៅពេលស្តុកទុកបានប្រហែល200 - 300ml
នោះនឹងកើតមានចំណង់នោម។

2) ប្រព័ន្ធបន្ទោបង់

ជាតិទឹកនិងចំណីអាហារដែលបរិភោគតាមមាត់ នឹងត្រូវបញ្ជូនទៅក្រពះ ហើយនឹងចាប់ផ្ដើមរំលាយអាហារ។ ចំណីអាហារនិងជាតិទឹក នឹងត្រូវបញ្ជូនទៅពោះវៀនតូច ហើយសារធាតុចិញ្ចឹមនិងជាតិទឹកនឹងត្រូវបានស្រូបយក។ របស់ដែលនៅសល់ក្រោយពីការស្រូបយកនោះ នឹងក្លាយជាលាមកដែលត្រូវបញ្ចេញចោលទៅក្រៅរាងកាយ។ នេះហៅថា ការបន្ទោបង់។ នៅពេលលាមកត្រូវបានស្តុកទុកក្នុងពោះវៀន នោះនឹងមានអារម្មណ៍ "ចង់ទៅបង្គន់"។ នេះហៅថា ចំណង់បន្ទោបង់។

ចំណង់បន្ទោបង់នឹងបាត់ទៅវិញនៅពេលពេលវេលាបានកន្លងផុត។

● ផ្នែកនៃរាងកាយដែលពាក់ព័ន្ធនឹងការបង្កើតលាមក



● ឥរិយាបថនៃការបន្ទោបង់

នៅពេលប្រើឥរិយាបថទោរទៅមុខ ហើយបំបះកែងជើង នោះទ្វារធំនឹងនៅត្រង់ចំពីចុងពោះវៀនធំដែលជាច្រកចេញលាមក ដែលធ្វើឲ្យលាមកងាយចេញមកក្រៅ។

3 ទម្រង់និងបរិមាណនៃទឹកនោមនិងលាមក

1) ស្ថានភាពនៃទឹកនោម

បរិមាណនិងចំនួនដងនៃទឹកនោមគឺរងឥទ្ធិពលពីបរិស្ថាននិងជំងឺ។

● ទឹកនោមប្រក្រតីនិងទឹកនោមមិនប្រក្រតី

		ទឹកនោមប្រក្រតី	ទឹកនោមមិនប្រក្រតី
ទឹកនោម	បរិមាណ	1ថ្ងៃ 1000 - 1500ml	1ថ្ងៃ 2000 - 3000ml ឡើងទៅ (នោមច្រើន) 300 - 500ml ចុះក្រោម (នោមតិច)
	ចំនួនដង	1ថ្ងៃ 4 - 6ដង	10ដងឡើងទៅ(នោមញឹក)
	ក្លិន	គ្មានក្លិន	ក្លិនអាម៉ូញាក់ខ្លាំង
	ពណ៌	ពីពណ៌លឿងស្រាលទៅថ្លា	ល្អក់ ពណ៌ត្នោត ពណ៌ក្រហមជាដើម

2) ស្ថានភាពនៃលាមក

លាមកទទួលឥទ្ធិពលពីរបស់ដែលបរិភោគនិងជំងឺជាដើម។ ហេតុនេះ រូបរាង ពណ៌ និងចំនួនដងគឺប្រែប្រួលទៅតាមស្ថានភាពនៅពេលនោះ។

នៅពេលមើលថែទាំ សូមស្វែងយល់ទុកជាមុនពីស្ថានភាពលាមកប្រក្រតី។

● លាមកប្រក្រតី និងលាមកមិនប្រក្រតី

លាមក		លាមកប្រក្រតី	លាមកមិនប្រក្រតី
	ចំនួនដង	1ថ្ងៃ 1 - 2ដង	ករណីតិច(ទល់លាមក)
	ពណ៌	ពណ៌ត្នោតចាស់	ពណ៌ក្រហម ពណ៌ខ្មៅ ពណ៌សជាដើម

4 ឧបករណ៍សម្រាប់មើលថែទាំពេលបញ្ចេញចោល

ក្នុងការបញ្ចេញចោល មានឧបករណ៍សម្រាប់ប្រើប្រាស់ផ្សេងៗជាច្រើន។ ឧបករណ៍ត្រូវប្រើប្រាស់ឲ្យស្របតាមស្ថានភាពរបស់មនុស្ស។

● ឧបករណ៍ផ្សេងៗសម្រាប់ការបញ្ចេញចោល

ឧបករណ៍	រូបរាង	អ្នកដែលត្រូវប្រើ
បង្គន់ចល័ត		ប្រើសម្រាប់អ្នកដែលមានចំណង់នោមឬចំណង់បន្ទោបង់ប៉ុន្តែមិនអាចទៅបង្គន់បានឬនៅពេលបញ្ចេញចោលពេលយប់ជាដើម។
ដបត្រងទឹកនោម ចានបង្គន់		ប្រើសម្រាប់អ្នកដែលមានចំណង់នោមឬចំណង់បន្ទោបង់ប៉ុន្តែគេងជាប់គ្រោកមិនបានឬសុខភាពមិនល្អ និងអ្នកដែលពិបាករក្សាឥរិយាបថអង្គុយ។
ខោទឹកនោម ទ្រនាប់ទឹកនោម		ប្រើសម្រាប់អ្នកដែលមិនដឹងថាខ្លួនលេចចេញទឹកនោមឬលាមក(អសមត្ថភាពគ្រប់គ្រងការនោមឬបន្ទោបង់)ឬអ្នកដែលពិបាកបញ្ចេញចោលដោយប្រើបង្គន់ឬបង្គន់ចល័តជាដើម។

5 ផលប៉ះពាល់នៃការធ្លាក់ចុះឬបញ្ហានៃមុខងាររាងកាយទៅលើការបញ្ចេញចោល(អសមត្ថភាពគ្រប់គ្រងការបញ្ចេញចោល ទល់លាមក រាករូស)

1) អសមត្ថភាពគ្រប់គ្រងការនោម

អសមត្ថភាពគ្រប់គ្រងការនោមគឺជាការដែលនោមត្រូវបានបញ្ចេញចោលដោយមិនស្របតាមបំណងរបស់ខ្លួន។

● ប្រភេទនៃអសមត្ថភាពគ្រប់គ្រងការនោម

	ស្ថានភាព
អសមត្ថភាពគ្រប់គ្រងការនោមដោយសារស្ត្រេសពោះ	ទឹកនោមលេចចេញនៅពេលពោះទទួលរងស្ត្រេសឬសំពាធដូចជា ក្អកឬកណ្តាស់
អសមត្ថភាពគ្រប់គ្រងការនោមដោយរាន់នោមខ្លាំង	មានចំណង់នោមប៉ុន្តែទៅបង្គន់មិនទាន់ហើយលេចចេញ
អសមត្ថភាពគ្រប់គ្រងការនោមដោយលេចនោមរហូត	ដោយសារជំងឺក្រពេញប្រូស្តាតរីកធំជាដើមបណ្តាលឲ្យបំពង់ទឹកនោមត្រូវបិទជាដើមធ្វើឲ្យទឹកនោមលេចចេញម្តងបន្តិចៗ
អសមត្ថភាពគ្រប់គ្រងការនោមដោយសារផ្លិច	ទឹកនោមលេចចេញដោយគ្មានចំណង់នោមដោយសារតែរបួសខួរឆ្អឹងខ្នងជាដើម
អសមត្ថភាពគ្រប់គ្រងការនោមដោយសារមុខងាររបស់វា	លេចនោមដោយចលនានោមមិនទាន់ពេល លេចនោមដោយទៅមិនទាន់ពេលដោយសារតែជំងឺភ្លេចភ្លាំងជាដើមធ្វើឲ្យមិនស្គាល់ទីតាំងបង្គន់

2) ទល់លាមក

ទល់លាមកគឺអាការដែលស្ថានភាពចំនួនដងនៃការបន្ទោបង់និងបរិមាណលាមកថយចុះធៀបនឹងធម្មតាហើយស្ថានភាពនេះបន្តជាប់។

● ប្រភេទនៃការទល់លាមក

	ស្ថានភាព
ទល់លាមកដោយសារមុខងារ	ទល់លាមកដែលកើតឡើងដោយបណ្តាលមកពីមុខងារនៃរាងកាយ
ទល់លាមកដោយសារសរីរាង្គ	ទល់លាមកដែលកើតឡើងដោយសារមានដុំពកឬរលាកជាដើមធ្វើឲ្យផ្លូវឆ្លងកាត់របស់លាមកត្រូវបានរាំងខ្ទប់

ចំណុចសំខាន់នៃការមើលថែទាំ

- បណ្ដុះទម្លាប់បញ្ចេញចោលដែលមានភាពទៀងទាត់។
- រក្សាបរិមាណទទួលទានជាតិទឹក។
- បញ្ចូលអាហារមានជាតិសសៃទៅក្នុងរបបអាហារឲ្យបានច្រើន។
- បញ្ចូលការហាត់ប្រាណទៅក្នុងការរស់នៅ។

ប្រសិនបើស្ថានភាពទល់លាមកមិនប្រសើរឡើងទេនោះ ត្រូវរាយការណ៍ទៅអ្នកជំនាញផ្នែកព្យាបាល។

3) រាករូស

រាករូសគឺជាលាមកដែលបរិមាណជាតិទឹកក្នុងលាមកមានច្រើនធ្វើឲ្យលាមកទន់។

ចំណុចសំខាន់នៃការមើលថែទាំ

- ដោយសារជាតិទឹកត្រូវបានបាត់បង់ ហេតុនេះត្រូវបង្ការការបាត់បង់ជាតិទឹក។
- បើអាចទទួលទានតាមមាត់ ត្រូវញ៉ាំទឹកដាំពុះឬភេសជ្ជៈកីឡាដែលមានសីតុណ្ហភាពធម្មតា។
- លាមករាវនឹងប៉ះដល់ស្បែកដែលនៅជុំវិញទ្វារធំ ហេតុនេះត្រូវរក្សាអនាម័យដោយលាងសម្អាតជាដើម។

អាការរាករូសដែលបន្ទាន់ខ្លាំងគឺអាចមានការសង្ស័យថាមានជំងឺឆ្លង ហេតុនេះត្រូវរាយការណ៍ទៅអ្នកជំនាញផ្នែកព្យាបាល។

ដោយសារការបញ្ចេញចោលគឺរងឥទ្ធិពលពីភាពតានតឹងផ្នែកផ្លូវចិត្ត ហេតុនេះត្រូវយកចិត្តទុកដាក់ស្ដាប់ស្ថានភាពនិងការត្អូញប្រាប់របស់អ្នកប្រើប្រាស់។ អ្នកមើលថែទាំត្រូវសង្កេតមើលស្ថានភាពទឹកនោមនិងលាមកដែលត្រូវបានបញ្ចេញចោល។

ប្រសិនបើមានអារម្មណ៍ថារាងកាយមានភាពមិនប្រក្រតី ត្រូវរាយការណ៍ទៅអ្នកជំនាញផ្នែកព្យាបាលភ្លាមៗ។ នេះគឺជាការការពារសុខភាពរបស់អ្នកប្រើប្រាស់។

6 ដំណើរការនៃសកម្មភាពបញ្ចេញចោល

ក្នុងសកម្មភាពបញ្ចេញចោលទូទៅគឺរួមមានចលនាជាច្រើន។ សកម្មភាពបញ្ចេញចោលមានទំនាក់ទំនងជាមួយមុខងារប្រព័ន្ធប្រសាទស្មុគស្មាញនិងចលនានៃរាងកាយ។

● ដំណើរការនៃសកម្មភាពបញ្ចេញចោល



អ្នកប្រើប្រាស់ដែលត្រូវការការមើលថែទាំនៅពេលបញ្ចេញចោល គឺមានបន្ទុកផ្លូវចិត្តធ្ងន់។ ហេតុនេះចាំបាច់ត្រូវមើលថែទាំដោយត្រួតពិនិត្យថាសេចក្ដីថ្លៃថ្នូររបស់ពួកគេត្រូវបានថែរក្សា។

7 ការអនុវត្តការមើលថែនៅពេលបញ្ចេញចោល

⦿ ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការមើលថែទាំពេលបញ្ចេញចោល

- រក្សាទម្លាប់បញ្ចេញចោលរបស់អ្នកប្រើប្រាស់។
- គិតដល់អារម្មណ៍ខ្មាសអៀន។
- គិតដល់ក្លិន។
- ជ្រើសរើសវិធីសាស្ត្រនិងឧបករណ៍សម្រាប់បញ្ចេញចោលដែលសមស្រប។
- អ្នកមើលថែទាំត្រូវប្រើអៀមនិងស្រោមដៃប្រើម្ដងបោះចោលដើម្បីបង្ការជំងឺឆ្លង។

● ឧទាហរណ៍នៃបរិស្ថានបញ្ចេញចោល

បង្កាន់ដៃរាងអក្សរL
ប្រើនៅពេលក្រោកឈរ។

បង្កាន់ដៃចល័តបាន
អាចចល័តឡើងចុះបាន ហេតុនេះត្រូវប្រើ
ឲ្យសមស្របតាមស្ថានភាពអ្នកប្រើប្រាស់។



ប៊ូតុងហៅសុំជំនួយ
អាចហៅអ្នកមើលថែទាំនៅពេលមានបញ្ហា
និងពេលបញ្ចប់ការបញ្ចេញចោល។

ទ្វាររុញចំហៀង
ទោះជាអ្នកប្រើប្រាស់ដែលជិះ
កៅអីរុញក៏អាចបើកទ្វារដោយខ្លួ
នឯងបាន។

1) ការអនុវត្តការមើលថែទាំពេលបញ្ចេញចោលការមើលថែទាំនៅបង្គន់

នៅទីនេះ យើងនឹងពន្យល់ដោយលើកឧទាហរណ៍អ្នកប្រើប្រាស់ដែលពិការមួយចំហៀងខ្លួនខាងឆ្វេង។

① នាំអ្នកប្រើប្រាស់ទៅដល់បង្គន់។

② ឲ្យអ្នកប្រើប្រាស់កាន់បង្កាន់ដៃនៅខាងដែលមិនមានបញ្ហា។



③ អ្នកមើលថែទាំត្រូវនៅខាងដែលមានបញ្ហាហើយដោះខោនិងខោទ្រនាប់ចុះ។

④ អ្នកប្រើប្រាស់អង្គុយលើមាត់ចានបង្គន់ដោយកាន់បង្កាន់ដៃ។

⑤ អ្នកមើលថែទាំចាកចេញពីបង្គន់ហើយទាញទ្វារបិទ។

⑥ ចូលទៅក្នុងបង្គន់វិញបន្ទាប់ពីទទួលបានសញ្ញាពីអ្នកប្រើប្រាស់ថាបញ្ចប់រួចហើយ។

⑦ លើកខោទ្រនាប់និងខោរបស់អ្នកប្រើប្រាស់ដល់កន្លែងដែលលើកបាន។

⑧ អ្នកប្រើប្រាស់កាន់បង្កាន់ដៃរួចក្រោកឈរឡើង។





⑨ ឲ្យលើកខោទ្រនាប់និងខោឡើងដោយខ្លួនឯងប្រសិនបើឥរិយាបថឈររបស់អ្នកប្រើប្រាស់មានលំនឹងហើយ។

⑩ ពិនិត្យបញ្ជាក់ថាខោទ្រនាប់និងខោត្រូវបានលើកឡើងគ្រប់គ្រាន់ហើយ។

2) ការមើលថែទាំដោយប្រើដបត្រងទឹកនោមឬចានបង្គន់ដែលស៊កទ្រាប់

① ត្រៀមសម្ភារៈចាំបាច់។

② បាំងវាំងននដើម្បីរក្សាឯកជនភាពរបស់អ្នកប្រើប្រាស់។

③ កំណត់កម្ពស់គ្រែឲ្យសមស្របជាមួយនឹងអ្នកមើលថែទាំ។ ក្រាលទ្រនាប់ការពារទឹកជ្រាប។

④ បញ្ឈរជង្គង់អ្នកប្រើប្រាស់ លើកចង្កេះឡើង ហើយដោះខោនិងខោទ្រនាប់ចុះ។

⑤ លើកចង្កេះឡើង ស៊កចូលទ្រាប់ធ្វើយ៉ាងណាឲ្យបរិវេណទ្វារធំនៅចំកណ្តាលនៃចានបង្គន់ ហើយត្រួតពិនិត្យថាមានលំនឹងឬទេ។

គ្របត្រង់ផ្នែកពោះដោយកន្សែងជាដើមដើម្បីរក្សាឯកជនភាពរបស់អ្នកប្រើប្រាស់។

ការកាច់លើកគ្រែឡើងនឹងធ្វើឲ្យងាយផ្តល់សម្ពាធទៅលើពោះ។

⑥ លើកចង្កេះឡើង សម្អាតកន្លែងដែលកខ្វក់ ហើយដកចានបង្គន់ចេញ។

⑦ សង្កេតមើលស្បែកអ្នកប្រើប្រាស់។

⑧ ឲ្យអ្នកប្រើប្រាស់គេងផ្អៀងហើយដកទ្រនាប់ការពារទឹកជ្រាបចេញ។

⑨ លើកខោទ្រនាប់និងខោឡើង ហើយសម្រួលរៀបចំសម្លៀកបំពាក់។

⑩ សម្រួលកម្ពស់គ្រែមកដូចដើមវិញ។

⑪ ត្រួតពិនិត្យសុខភាពរាងកាយ។

⑫ សម្អាតសម្ភារៈ។

● ការបញ្ចេញចោលដោយប្រើដបត្រងទឹកនោម

ចំពោះបុរស	ចំពោះស្ត្រី
គេងផ្អៀង ដាក់ខ្នើយជាដើមកល់ខ្នង ហើយបញ្ចូលដបត្រងទឹកនោម។	ប្រើក្រដាសជូតមាត់ជាដើមដើម្បីនាំឲ្យទឹកនោមហូរចូលដបត្រងទឹកនោមដោយមិនអាចខ្ទាតចេញក្រៅ។
	

3) ការមើលថែទាំពេលប្ដូរខោទឹកនោម

① ពិនិត្យមើលសុខភាពរាងកាយរបស់អ្នកប្រើប្រាស់។

② ពន្យល់ពីគោលបំណងនិងខ្លឹមសារនៃសកម្មភាពដែលនឹងធ្វើទៅអ្នកប្រើប្រាស់ហើយសុំការយល់ព្រម។

③ ត្រៀមសម្ភារៈចាំបាច់។

④ កែសម្រួលកម្ពស់គ្រែឲ្យសមស្របជាមួយនឹងអ្នកមើលថែទាំ។

⑤ ឲ្យអ្នកប្រើប្រាស់គេងផ្អៀងហើយក្រាលទ្រនាប់ការពារទឹកជ្រាបចេញ។

⑥ ឲ្យគេងផ្ងារវិញ ហើយលើកចង្កេះឡើងរួចដោះខោចុះ។

⑦ បកស្កុតបិទខោទឹកនោម។

⑧ លាងប្រដាប់ភេទដោយទឹកក្ដៅដែលដាក់ក្នុងដបបាញ់ទឹក។
ចំពោះស្ត្រី ត្រូវលាងចេញពីបង្ហូរនោមឆ្ពោះទៅទ្វារធំ (ពោលគឺពីខាងមុខទៅខាងក្រោយ) (បង្ការជំងឺឆ្លង)។ ត្រូវលាងឲ្យបានសព្វត្រង់កន្លែងដែលស្បែកត្រួតគ្នាក៏ដោយ។

⑨ ជូតទឹកចេញដោយកន្សែងស្ងួត។

⑩ រុំខ្ចប់ខោទឹកនោមដែលប្រឡាក់ ហើយឲ្យគេងផ្អៀង។



⑪ ដាក់ខោទឹកនោមថ្មីចូលក្រោមខោទឹកនោមប្រឡាក់។ ឲ្យគេងបែរមុខទៅលើវិញ ហើយចាប់យកខោទឹកនោមប្រឡាក់ពីខាងបញ្ច្រាស់។
ចាត់ចែងខោទឹកនោមប្រឡាក់រួចហើយសឹមដោះស្រោមដៃចេញ។



⑫ បិទស្កុតដោយឲ្យសល់ចន្លោះប្រហែល2-3ម្រាមដៃលូកចូលបាននៅត្រង់ពោះនិងភ្លៅ។

⑬ លើកចង្កេះហើយទាញខោឡើង។ រៀបចំសម្រួលសម្លៀកបំពាក់និងកម្រាលគ្រែ។





⑭ ផ្លាស់ប្តូរខ្យល់អាកាសនៅក្នុងបន្ទប់។
⑮ ត្រួតពិនិត្យសុខភាពរាងកាយ។
⑯ សម្អាតសម្ភារៈ។

CHAPTER

4 ការមើលថែទាំនៅពេលរៀបចំខ្លួន

1 អត្ថន័យនៃការរៀបចំខ្លួន

ការរៀបចំខ្លួនគឺជាការរៀបចំរូបរាងឲ្យរៀបរយដូចជា លុបលាងមុខ សិតសក់ ផ្លាស់សម្លៀកបំពាក់ជាដើម។ ការរៀបចំខ្លួនមិនមែនគ្រាន់តែរក្សាអនាម័យនៃរាងកាយនោះទេ គឺវានឹងនាំឲ្យភាពម្ចាស់ការខាងផ្លូវចិត្តតាមរយៈការបង្ហាញចេញភាពជាខ្លួនឯង។ ម្យ៉ាងទៀត វាជាសកម្មភាពដែលសំខាន់ដើម្បីរក្សាទំនាក់ទំនងជាមួយអ្នកដទៃនៅក្នុងសង្គម។

2 ប្រព័ន្ធនៃរាងកាយ និងផ្លូវចិត្តដែលទាក់ទងនឹងការរៀបចំខ្លួន

ការរៀបចំខ្លួនជាវិធីមួយក្នុងការបង្ហាញចេញភាពជាខ្លួនឯង។ ការមើលថែទាំដោយគោរពទម្លាប់រស់នៅនិងគុណតម្លៃរបស់បុគ្គលនោះ គឺជារឿងចាំបាច់។ ការគាំពារការរៀបចំខ្លួននឹងអាចបំផុសចំណង់ក្នុងការរស់នៅ។

(ប្រសិទ្ធភាពនៃការរៀបចំខ្លួន)

① កែសម្រួលកម្ដៅក្នុងខ្លួន និងការពារស្បែក។

② ថែរក្សានិងលើកកម្ពស់មុខងាររាងកាយនិងផ្លូវចិត្ត។

③ អាចរស់នៅដោយសុវត្ថិភាពនិងមានផាសុកភាព។

④ មានភាពច្បាស់លាស់នៅក្នុងការរស់នៅ។

⑤ អាចបង្ហាញចេញភាពជាខ្លួនឯង។

⦿ ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការមើលថែទាំនៅពេលរៀបចំខ្លួន

